# មេរៀនព្រះអភិធម្ម
# ចិត្ត និង ចេតសិក

## I. អកុសលចិត្ត ១២ ដួង

### ក.លោភមូលចិត្ត ៨ ដួង

### ១- សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ(មិច្ឆាទិដ្ឋិទាំងអស់) មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានអ្នកដទៃបបួលដឹកនាំ ។

**មានចេតសិកកើតរួមជាមួយ ១៩ ប្រភេទគឺះ**

- **អញ្ញសមានាចេតសិក ១៣** គឺ (ផស្សោ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយំ មនសិការោ) ដែលជាសព្វចិត្តសាធារណចេតសិក ៧ និង (វិតក្កោ វិចារោ អធិមោក្ខោ វីរិយំ បីតិ ឆន្ទោ)ដែលជាបកិណ្ណកចេតសិក៦។
- **មោចតុកៈ ៤** គឺ មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចំ
-**លោតិកៈ ២** គឺ លោភោ និង ទិដ្ឋិ (វៀរមានោ)

### ២-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំពីអ្នកដទៃ ។

**មានចេតសិកកើតរួមជាមួយ ២១ ប្រភេទគឺៈ**

- **អញ្ញសមានាចេតសិក ១៣**
- **មោចតុក: ៤**
- **លោតិក: ២** (វៀរមានោ)
- **ថីទុក: ២ គឺ** ថីនំ មិទ្ធំ

## ៣-សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាក មិច្ឆាទិដ្ឋិ មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំពីអ្នកដទៃ ។

**មានចេតសិកប្រកបជាមួយ ១៩ ប្រភេទគឺៈ**

- **អញ្ញសមានាចេតសិក ១៣**
- **មោចតុក: ៤**
- **លោតិក: ២** (វៀរទិដ្ឋិ)

➢ **ចំណាំ**

លោភមូលចិត្តប្រការទី ៣ នេះមានចេតសិកប្រកបជាមួយ ១៩ ប្រភេទក្នុងកាលណាដែលមាន មានចេតសិកកើតរួមជាមួយ មានចេតសិកប្រកបជាមួយត្រឹមតែ ១៨ ប្រភេទក្នុងកាលណាដែលមិនមានមានចេតសិកកើតរួមជាមួយ ។

## ៤-សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាក មិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំពី

អ្នកដទៃ ។

**មានចេតសិកប្រកបជាមួយ ២១ ប្រភេទគឺ៖**

- **អញ្ញសមានាចេតសិក ១៣**
- **មោចតុកៈ ៤**
- **លោតិកៈ ២** (វៀរទិដ្ឋិ)
- **ថីទុកៈ ២** (ថីនំ មិទ្ធំ)

(ចិត្តដូចទឹកថ្លា ចេតសិកដូចពណ៌) បើទឹកថ្លាត្រូវពណ៌ក្រហម ឬខ្មៅលាយហើយ ទឹកថ្លានោះក៏ក្លាយជាពណ៌ក្រហមឬខ្មៅនោះទៅ។

លោភមូលចិត្តដួងទី ៤ គឺត្រេកអរដូចឃើញរបស់ជាទីស្រឡាញ់ហើយថាយើងគ្រាន់បើជាងគេ។

-លោភមូលចិត្តដួងទី ៤ នេះមានចេតសិកប្រកបជាមួយ ២១ ប្រភេទក្នុងកាលណាដែលមាន មានចេតសិកកើតរួមជាមួយ មានចេតសិកប្រកបជាមួយត្រឹមតែ២០ប្រភេទ ក្នុងកាលណាដែលមិនមាន មានចេតសិកកើតរួមជាមួយ។

-មានៈនិងទិដ្ឋិកើតរួមគ្នាមិនបាន ប៉ុន្តែនៅក្នុងកងអកុសលដូចគ្នា។ មានៈប្រៀបផ្ទឹមនឹងអ្នកដទៃ ឯទិដ្ឋិកាលណាកើតឡើងវាតែងមានការយល់ខុស ។

## ៥.ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយមិច្ឆា-ទិដ្ឋិ មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានការបបួលដឹកនាំពីអ្នកដទៃ។

**មានចេតសិកប្រកបជាមួយ ១៨ ប្រភេទគឺៈ**

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- មោចតុកៈ ៤
- លោភិកៈ ២ (វៀរមានោ)

**៦.ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ**

លោភមូលចិត្តប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំពីអ្នកដទៃ។

**មានចេតសិកប្រកបជាមួយ ២០ ប្រភេទគឺៈ**

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- មោចតុកៈ ៤
- លោភិកៈ ២ (វៀរមានោ)
- ថីទុកៈ ២ គឺ ថីនំ មិទ្ធំ

**៧-ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ**

លោភមូលចិត្តប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានការបបួលដឹកនាំ ពីអ្នកដទៃ។

**មានចេតសិកប្រកបជាមួយ ១៨ ប្រភេទគឺៈ**

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- មោចតុកៈ ៤
- លោភិកៈ ២ (វៀរ ទិដ្ឋិ)

## ៨-ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំពីអ្នកដទៃ។

**មានចេតសិកប្រកបជាមួយ ២០ ប្រភេទគឺៈ**

- **អញ្ញសមានាចេតសិក ១២** (វៀរបីតិ)
- **មោចតុកៈ ៤**
- **លោតិកៈ ២** (វៀរទិដ្ឋិ)
- **ថីទុកៈ ២ គឺ** ថីនំ មិទ្ធំ

**សំនួរ**

១- តើលោភមូលចិត្តដួងណាខ្លះ ដែលមានចេតសិកប្រកបជាមួយច្រើនជាងគេ?

២- តើលោភមូលចិត្តដួងណាខ្លះ ដែលមានចេតសិកប្រកបជាមួយតិចជាងគេ?

៣- តើបីតិចេតសិក កើតនៅក្នុងលោភមូលចិត្តដួងណាខ្លះ?

៤- តើទិដ្ឋិចេតសិក កើតនៅក្នុងលោភមូលចិត្តដួងណាខ្លះ?

៥- តើបីតិចេតសិកមាននៅក្នុងលោភមូលចិត្ត ដែលប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនាឬទេ? បើមានព្រោះហេតុអ្វី? បើមិនមានព្រោះអ្វី?

៦- ចំពោះលោភមូលចិត្តដែលមិនមានមិច្ឆាទិដ្ឋិកើតជាមួយ ហេតុអ្វីក៏ចាត់ជាអកុសលចិត្តដែរ? ចូរពន្យល់ !

**ចម្លើយ**

១- លោភមូលចិត្ត ដែលមានចេតសិកប្រកបជាមួយច្រើនជាងគេ គឺ លោភមូលចិត្តដួងទី ២ និង ដួងទី ៤។
២- លោភមូលចិត្ត ដែលមានចេតសិកប្រកបជាមួយតិចជាងគេគឺ លោភ-មូលចិត្តដួងទី ៥ និង ដួងទី៧។
៣- បីតិចេតសិក កើតនៅក្នុងលោភមូលចិត្តដួងទី១, ទី២, ទី៣, ទី៤ ។
៤- ទិដ្ឋិចេតសិក កើតនៅក្នុងលោភមូលចិត្តដួងទី១, ទី២, ទី៥, ទី៦។
៥-បីតិចេតសិកមិនកើតក្នុងលោភមូលចិត្តដែលប្រព្រឹត្តទៅជាមួយឧបេក្ខា-វេទនាទេ ព្រោះឧបេក្ខាវេទនាមានសភាពព្រងើយៗ។
៦- បានជាលោភមូលចិត្ត ដែលមិនមានមិច្ឆាទិដ្ឋិកើតជាមួយ ហើយចាត់ជាអកុសលចិត្តព្រោះមាន លោភៈ, មានៈ, អហិរិកៈ, អនោត្តប្បៈ, ឧទ្ធច្ចៈ, ថីនៈ, មិទ្ធៈ។

**-ចំណាំ**

ក្នុងលោភមូលចិត្ត ៨ដួង មានចេតសិកកើតរួមទាំងអស់ ២២ ប្រភេទ គឺ អញ្ញសមានាចេតសិក ១៣ មោចតុកចេតសិក ៤ លោតិកចេតសិក ៣ ថីទុកចេតសិក ២។

-ចេតសិកដែលកើតទៀងទាត់ក្នុងលោភមូលចិត្តទាំង ៨ ដួង មានត្រឹមតែ ១៧ ប៉ុណ្ណោះគឺ៖

- **អញ្ញសមានាចេតសិក ១២** (វៀរ បីតិ)
- **មោចតុកៈ ៤**
- **លោភចេតសិក** ១ (វៀរ ទិដ្ឋិ មានោ ថីនំ មិទ្ធំ)។

## ហេតុនាំឱ្យកើតលោភមូលចិត្តមាន ៤ យ៉ាងគឺ៖

**១- លោភបរិវារកម្មបដិសន្ធិកតា** បដិសន្ធិដោយកម្មដែលមានលោភៈជាបរិវារ។

**២- លោភឧស្សន្នភវតោចវនតា** ចុតិចាកភពដែលសម្បូរដោយលោភៈ ឬ សេចក្តីសប្បាយ។

**៣- ឥដ្ឋារម្មណសមាយោគោ** មានការជួបប្រសព្វនឹងឥដ្ឋារម្មណ៍ (ឥដ្ឋារម្មណ៍ មាន ២យ៉ាងគឺ៖ បរិកប្បឥដ្ឋារម្មណ៍១, សភាវឥដ្ឋារម្មណ៍១)។

**៤- អស្សាទទស្សនំ** មានការឃើញនូវវត្ថុជាទីពេញចិត្ត ឬជាទីសប្បាយចិត្ត។

## ការចែកលោភមូលចិត្ត ៨ ដួងដោយន័យផ្សេងៗ

**១- ដោយជាតិ** ជាអកុសលជាតិ ចេតសិកកើតជាមួយវាក៏ជាអកុសលជាតិដែរ។

**២- ដោយភូមិ** ជាកាមាវចរភូមិ (កើតបាន ៣០ ភូមិ)។

**៣- ដោយវេទនា** ជាសោមនស្សវេទនា ៤ ដួង និង ជាឧបេក្ខាវេទនា ៤ ដួង។

**៤- ដោយហេតុ** ជានហេតុ និង ជាទ្វិហេតុកចិត្ត។

**៥- ដោយសង្ខារ** ជាអសង្ខារិក ៤ ដួង និង ជាសសង្ខារិក ៤ ដួង។

**៦- ដោយសម្បយុត្ត** ជាទិដ្ឋិគតសម្បយុត្ត ៤ ដួង និង ទិដ្ឋិគតវិប្បយុត្ត ៤ ដួង។

**៧- ដោយសោភណៈ** ជាអសោភណចិត្ត។

**៨- ដោយឈាន** ជាអកុសលឈាន។

៩- **ដោយលោកិយ** ជាលោកិយចិត្ត។

១០- **ដោយកិច្ច** ធ្វើជវនកិច្ច។

១១- **ដោយអារម្មណ៍** ដឹងអារម្មណ៍ទាំង ៦ គឺ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍។

១២- **ដោយទ្វារ** ប្រព្រឹត្តទៅតាមទ្វារទាំង ៦ (ទ្វារឱ្យកើតបាប ឬ បុណ្យ នៅក្នុងទ្វារ ៣ គឺ កាយទ្វារ វចីទ្វារ មនោ-ទ្វារ)។

១៣- **ដោយវត្ថុ** អាស្រ័យនឹងហទយវត្ថុ (ក្នុងភពដែលមានខន្ធ៥)។

១៤- **ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ។

## ផលរបស់លោភមូលចិត្ត

**+បច្ចុប្បន្ន** កាលណាសត្វលោកច្រើនទៅដោយលោភចិត្តនឹងកើតទុរ្ភិក្ស ច្រើនប្រការ។

**+អនាគតជាតិ** លោភមូលចិត្តច្រើននាំសត្វទៅកើតជាប្រេត។

## ខ.ទោសមូលចិត្ត ២ ដួង

### ១- ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ

ទោសមូលចិត្តប្រព្រឹត្តទៅជាមួយ ទោមនស្សវេទនា ប្រកបជាមួយ សេចក្តីថ្នាំងថ្នាក់ មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានអ្នកដទៃ បបួលដឹកនាំ។

**មានចេតសិកប្រកបជាមួយ ២០ ប្រភេទគឺៈ**

- **អញ្ញសមានាចេតសិក ១២** (វៀរបីតិ)
- **មោចតុកៈ ៤**

- ទោចតុកៈ ៤

## ២- ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ

ទោសមូលចិត្តប្រព្រឹត្តទៅជាមួយ ទោមនស្សវេទនា ប្រកបដោយសេចក្តីថ្នាំងថ្នាក់ មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកដទៃបបួលដឹកនាំ។

**មានចេតសិកប្រកបជាមួយ ២២ ប្រភេទគឺៈ**

**-អញ្ញសមានាចេតសិក ១២** (វៀរបីតិ)

**-មោចតុកៈ ៤**

**-ទោចតុកៈ ៤**

**-ថីទុកៈ ២**

**ហេតុនាំឱ្យកើតទោសមូលចិត្តមាន ៤ យ៉ាង គឺ ៖**

**១- ទោសជ្ឈាសយតា** ភាពជាអ្នកចងនូវសេចក្តីក្រោធទុក។

**២- អគម្ភីរបកតិតា** ជាអ្នកមិនមានភាពល្អិតសុខុមជាប្រក្រតី។

**៣- អប្បសុតតា** ជាអ្នកស្តាប់ព្រះសទ្ធម្មតិចតួច។

**៤- អនិដ្ឋារម្មណសមាយោគោ** ជួបប្រសព្វនឹងអនិដ្ឋារម្មណ៍។

**ធម៌ជាហេតុលះទោសមូលចិត្តមាន ៦ យ៉ាងគឺ ៖**

**១- មេត្តានិមិត្តស្ស ឧគ្គហោ** ការរៀនយកនូវមេត្តានិមិត្ត។

**២- មេត្តាភាវនានុយោគោ** ការបំពេញព្យាយាមក្នុងមេត្តាភាវនា។

**៣-កម្មស្សកតាបច្ចវេក្ខណា** ពិចារណាឃើញថា សត្វមានកម្មជារបស់ខ្លួន។

**៤- បដិសង្ខានពហុលីកតា** ភាពជាអ្នកពិចារណាច្រើន។

**៥- កល្យាណមិត្តតា** ជាអ្នកមានកល្យាណមិត្ត។

**៦- សប្បាយកថា** មានកថាជាទីសប្បាយ។

## ការចែកទោសមូលចិត្ត ២ ដួងដោយន័យផ្សេងៗ

**១- ដោយជាតិ** ជាអកុសលជាតិ។

**២- ដោយភូមិ** កើតក្នុងកាមាវចរភូមិ ១១ ជាន់។

**៣- ដោយវេទនា** ជាទោមនស្សវេទនា ២ ដួង។

**៤- ដោយហេតុ** ជានហេតុ និង ជាទ្វិហេតុកចិត្ត។

**៥- ដោយសង្ខារ** ជាអសង្ខារិក ១ សសង្ខារិក១។

**៦- ដោយសម្បយុត្ត** ជាបដិឃសម្បយុត្ត ២ ដួង។

**៧- ដោយសោភណៈ** ជាអសោភណចិត្ត។

**៨- ដោយឈាន** ជាអកុសលឈាន។

**៩- ដោយលោកិយ** ជាលោកិយចិត្ត។

**១០- ដោយកិច្ច** ធ្វើជវនកិច្ច។

**១១- ដោយអារម្មណ៍** ដឹងអារម្មណ៍ទាំង ៦។

**១២- ដោយទ្វារ** កើតតាមទ្វារទាំង ៦។

**១៣- ដោយវត្ថុ** អាស្រ័យតែហទយវត្ថុប៉ុណ្ណោះ។

**១៤- ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ ។

## ផលនៃទោសមូលចិត្ត

ក្នុងបច្ចុប្បន្ន ប្រសិនបើសត្វលោកច្រើនដោយទោសមូលចិត្ត នឹងកើតមានសត្តន្តរាយ (អន្តរាយកើតពីសាស្ត្រាវុធ គឺចម្បាំងរាំងជល់)ក្នុងអនាគតជាតិច្រើនបដិសន្ធិក្នុងនរក។

## គ.មោហមូលចិត្ត ២ ដួង

### ១- ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ

មោហមូលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបជាមួយ វិចិកិច្ឆា (សេចក្តីសង្ស័យ)។

**មានចេតសិកប្រកបជាមួយ ១៥ ប្រភេទគឺ៖**

- **អញ្ញសមានាចេតសិក ១០** ( វៀរបីតិ អធិមោក្ខ ឆន្ទៈ )
- **មោចតុកៈ ៤**
- **វិចិកិច្ឆា ១**

### ២- ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ

មោហមូលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបជាមួយ ឧទ្ធច្ចៈ (រវើរវាយ)។

**មានចេតសិកប្រកបជាមួយ ១៥ ប្រភេទគឺ៖**

- **អញ្ញសមានាចេតសិក ១១** (វៀរ បីតិ ឆន្ទៈ)
- **មោចតុកៈ ៤**

**សេចក្តីសង្ស័យក្នុងព្រះអភិធម្ម ៨ យ៉ាងគឺ ៖**

**១- ពុទ្ធេ កង្ខតិ** សង្ស័យក្នុងព្រះពុទ្ធ គឺ ពុទ្ធគុណទាំង១០ មាន ពាក្យថា **អរហំ** ជាដើម ថាមានពិតឬហ្ន៎?

**២- ធម្មេ កង្ខតិ** សង្ស័យក្នុងព្រះធម៌ គឺ ក្នុងធម្មគុណទាំង ៦ មាន ពាក្យថា **ស្វាក្ខាតោ** ជាដើម ថាមានពិតឬហ្ន៎ ?

**៣- សង្ឃេ កង្ខតិ** សង្ស័យក្នុងព្រះសង្ឃ គឺក្នុងសង្ឃគុណទាំង ៩ មានពាក្យថា **សុប្បដិបន្នោ** ជាដើម ថាមានពិតឬហ្ន៎ ?

**៤- សិក្ខាយ កង្ខតិ** សង្ស័យក្នុងសិក្ខាបទ គឺសិក្ខាបទទាក់ទង សីល សមាធិ និង បញ្ញា ។

**៥- បុព្វន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ៥ ដែលជាអតីត ថាធ្លាប់កើតមានដែរឬទេហ្ន៎ ?

**៦- អបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ ៥ ជាអនាគត ថានឹងកើតមានទៀតឬហ្ន៎ ?

**៧- បុព្វន្តាបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ ៥ ដែលជាអតីត និង អនាគត ថាធ្លាប់កើតក្នុងអតីត ហើយនឹងកើតក្នុងអនាគតទៀតឬហ្ន៎?

**៨- បដិច្ចសមុប្បាទេ កង្ខតិ** សង្ស័យក្នុងបដិច្ចសមុប្បាទធម៌ថា អវិជ្ជាជាដើម ជាបច្ច័យឱ្យកើតបាប និង បុណ្យ ឬឱ្យកើតផលបាប ឬបុណ្យ តើពិតមែន ឬហ្ន៎ ?

## សេចក្ដីសង្ស័យក្នុងព្រះសូត្រមាន ១៦ យ៉ាងគឺ៖

### សង្ស័យក្នុងខន្ធ៥ ដែលជាចំណែកអតីត ៥ គឺ៖

**១- អហោសឹ នុ ខោ អហំ អតីតមទ្ធានំ** យើងធ្លាប់កើតមក ក្នុងអតីតកាលដែរឬហ្ន៎ ?

**២- ន នុ ខោ អហោសឹ អតីតមទ្ធានំ** យើងមិនធ្លាប់កើតមក ក្នុងអតីតកាលទេដឹងហ្ន៎ ?

**៣- កឹ នុ ខោ អហោសឹ អតីតមទ្ធានំ** យើងធ្លាប់កើតក្នុងអតីតជាអ្វីហ្ន៎ ?

**៤- កថំ នុ ខោ អហោសឹ អតីតមទ្ធានំ** ក្នុងអតីតយើងមានរូបរាងសណ្ឋានដូចម្ដេចហ្ន៎ ?

**៥- កឹ ហុត្វា កឹ អហោសឹ នុ ខោ អហំ អតីតមទ្ធានំ** អំពីអតីតកាល អាត្មាអញកើតជាជាតិអ្វី? ឬ មួយអាត្មាអញ មានសណ្ឋានទ្រង់ទ្រាយដូចម្ដេច?

**សេចក្ដីសង្ស័យក្នុខខន្ធ ៥ ដែលជាចំណែកអនាគត៥ គឺ៖**

**១- ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ** យើងនឹងកើតក្នុងកាលអនាគតឬទេហ្ន៎ ?

**២- ន នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ** យើងនឹងមិនកើតក្នុងកាលអនាគតទេដឹងហ្ន៎ ?

**៣- កឹ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ** យើងនឹងកើតក្នុងកាលអនាគតជាអ្វីហ្ន៎ ?

**៤- កថំ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ** ក្នុងអនាគតយើង នឹងមានរូបរាងសណ្ឋានយ៉ាងណាហ្ន៎ ?

**៥- កឹ ហុត្វា កឹ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ** យើងនឹងកើតជាអ្វី? ហើយតទៅនឹងកើតជាអ្វីទៀតហ្ន៎ ?

**សង្ស័យក្នុខខន្ធ ៥ ដែលជាចំណែកបច្ចុប្បន្ន ៦ គឺ៖**

**១- អហំ នុ ខោស្មិ** ឥឡូវនេះជាយើងឬហ្ន៎ ?

**២- នោ នុ ខោស្មិ** ឥឡូវនេះមិនមែនជាយើងឬហ្ន៎ ?

**៣- កឹ នុ ខោស្មិ** ឥឡូវនេះយើងជាអ្វីហ្ន៎ ?

**៤- កថំ នុ ខោស្មិ** ឥឡូវនេះយើងមានរូបរាងសណ្ឋានយ៉ាងណាហ្ន៎?

**៥- អយំ នុ ខោ សត្តោ កុតោ អាគតោ** សត្វនេះមកពីណាហ្ន៎?

**៦- សោ កុហឹ គាមី ភវិស្សតិ** សត្វនោះនឹងទៅកើតទីណាហ្ន៎?

## ការចែកមោហមូលចិត្ត ២ ដួងដោយន័យផ្សេង ៗ

**១- ដោយជាតិ** ជាអកុសលជាតិ

**២- ដោយភូមិ** ជាកាមាវចរភូមិ(កើតក្នុងភូមិទាំងអស់ វៀរអសញ្ញ-សត្តា)។

**៣- ដោយវេទនា** ជាឧបេក្ខាវេទនាទាំង ២ ដួង

**៤- ដោយហេតុ** ជានហេតុ និង ជាឯកហេតុកចិត្ត

**ពន្យល់ពាក្យដូចខាងក្រោម៖**

១- នហេតុកចិត្ត

២- សហេតុកចិត្ត

៣- អហេតុកចិត្ត

៤- ទ្វិហេតុកចិត្ត

៥- ទុហេតុកចិត្ត

៦- ឯកហេតុកចិត្ត

៧- តិហេតុកចិត្ត

**៥- ដោយសង្ខារ** ជាអសង្ខារិកចិត្ត

**៦- ដោយសម្បយុត្ត** ជាវិចិកិច្ឆាសម្បយុត្ត ១ និង ឧទ្ធច្ចសម្បយុត្ត ១

**៧- ដោយសោភណ** ជាអសោភណចិត្ត

**៨- ដោយឈាន** ជាអកុសលឈាន

**៩- ដោយលោកិយ** ជាលោកិយចិត្ត

**១០- ដោយកិច្ច** ធ្វើជវនកិច្ច

**១១- ដោយអារម្មណ៍** ដឹងអារម្មណ៍ ៦

**១២- ដោយទ្វារ** កើតតាមទ្វារទាំង ៦

**១៣- ដោយវត្ថុ** កើតក្នុងហទយវត្ថុ ក្នុងភពដែលមានខន្ធ ៥(ក្នុងភូមិ ២៦)។

**១៤- ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ

## ផលរបស់មោហមូលចិត្ត

**-ក្នុងបច្ចុប្បន្ន** កាលណាសត្វលោកច្រើនទៅដោយមោហៈ គឺសេចក្តីល្ងង់ សេចក្តីវង្វេងក្នុងកាលនោះ ច្រើនមានសេចក្តីអន្តរាយដោយរោគបៀតបៀន។

**-ក្នុងអនាគតជាតិ** ព្រោះតែមោហៈជាហេតុ សត្វលោកច្រើនទៅកើតក្នុងកំណើតតិរច្ឆាន ដែលមានតែសេចក្តីវង្វេងជានិច្ច។

- **ចំណាំ**

ចេតសិកដែលកើតប្រកបក្នុងអកុសលចិត្ត ១២ ដួងមានទាំងអស់ ២៧ គឺៈ

**- អញ្ញសមានាចេតសិក ១៣**

**- អកុសលចេតសិក ១៤**

**១- នហេតុកចិត្ត** ចិត្តដែលមិនមែនជាតួហេតុ

**២- សហេតុកចិត្ត** ចិត្តដែលប្រកបដោយហេតុកើតរួម

**៣- អហេតុកចិត្ត** ចិត្តដែលមិនមានហេតុកើតរួម

**៤- ទ្វិហេតុកចិត្ត** ចិត្តដែលមានហេតុ ២

**៥- ទុហេតុកចិត្ត** ចិត្តដែលមានហេតុ ២

**៦- ឯកហេតុកចិត្ត** ចិត្តប្រកបដោយហេតុ ១

**៧- តិហេតុកចិត្ត** ចិត្តប្រកបដោយហេតុ ៣

ចំណែកសោភណចេតសិក ២៥ ប្រភេទទៀតនោះមិនមានចេតសិកណាមួយមកប្រកបក្នុងអកុសលចិត្តទាំង ១២ នេះទេ ។

## សព្វាកុសលយោគីចេតសិក

មកពី **សព្វ+អកុសល+យោគី+ចេតសិក** ចេតសិកដែលកើតនៅក្នុងអកុសលចិត្តគ្រប់ទាំង ១២ ដួង មានត្រឹមតែ ១៤ ប្រភេទប៉ុណ្ណោះ។

-**អញ្ញសមានាចេតសិក ១០** (វៀរ អធិមោក្ខ បីតិ ឆន្ទៈ) និង មោចតុកៈ ៤។

-**អធិមោក្ខៈ** កើតនៅក្នុងអកុសលចិត្ត ១១ ប៉ុណ្ណោះ(វៀរ វិចិកិច្ឆាសម្បយុត្តចិត្ត១)។

-**បីតិ** កើតនៅក្នុងលោភមូលចិត្ត ដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ៤ ដួងប៉ុណ្ណោះ។

-**ឆន្ទោ** កើតនៅក្នុងអកុសលចិត្ត ១០ ដួងប៉ុណ្ណោះ (វៀរមោហមូលចិត្ត ២ ដួង) ។

-**លោភោ** កើតនៅក្នុងលោភមូលចិត្ត ៨ ដួងប៉ុណ្ណោះ។

-**ទិដ្ឋិ** កើតនៅក្នុងលោភមូលចិត្ត ដែលជាទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួងប៉ុណ្ណោះ។

-**មានោ** កើតនៅក្នុងលោភមូលចិត្តដែលជាទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង

ប៉ុណ្ណោះ។

**-ទោចតុកៈ ៤** កើតតែក្នុងទោសមូលចិត្ត ២ ដួង។

**-ថីទុកៈ ២** កើតនៅក្នុងសសង្ខារិកចិត្ត ៥ ដួង។

**-វិចិកិច្ឆា** កើតនៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង។

## សង្គ្រោះអកុសលចិត្ត ១២ ដួង ចូលក្នុងកម្មបថ

## អកុសលកម្មបថ ១០

### ក- កើតតាមកាយទ្វារ មាន ៣ គឺៈ

**១- បាណាតិបាត** ការសម្លាប់សត្វ

**២- អទិន្នាទាន** ការលួចទ្រព្យគេ

**៣- កាមេសុមិច្ឆាចារៈ** ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

### ខ- កើតតាមវចីទ្វារ មាន ៤ គឺៈ

**១- មុសាវាទ** ការនិយាយកុហក

**២- បិសុណាវាទ** ការនិយាយញុះញង់ ឬ ស៊កសៀត

**៣- ផរុសវាទ** ការនិយាយជេរប្រទេច

**៤- សម្ផប្បលាបវាទ** ការនិយាយរោយរាយឥតប្រយោជន៍។

### គ- កើតតាមមនោទ្វារមាន ៣ គឺៈ

**១- អភិជ្ឈា** ការសម្លឹងរំពៃ

**២- ព្យាបាទ** មានបំណងអាក្រក់ចង់ព្យាបាទ

**៣- មិច្ឆាទិដ្ឋិ** ការយល់ខុស (និយតមិច្ឆាទិដ្ឋិ )

### អធិប្បាយអកុសលកម្មបថដោយអាការៈ ៥ យ៉ាង

**១- ដោយមូល** មានលោភៈ ទោសៈ មោហៈ ជាមូល ។

**២- ដោយកម្ម** ជាកាយកម្ម វចីកម្ម មនោកម្ម ។

**៣- ដោយទ្វារ** ជាកាយទ្វារ វចីទ្វារ មនោទ្វារ ។

**៤-ដោយសាវជ្ជៈ** (ដោយទោស) ជាអប្បសាវជ្ជៈ មានទោសតិច និង មហាសាវជ្ជៈ មានទោសច្រើន ។

**៥- ដោយអង្គ** គឺអង្គនៃការប្រព្រឹត្តកន្លងកម្មបថ ។

## ១. បាណាតិបាត

ការញុំាងសត្វមានជីវិតឱ្យធ្លាក់ចុះកន្លងឈ្មោះថា **បាណាតិបាត** គឺ ការសម្លាប់សត្វ ។ ដោយវោហារ បានដល់សត្វ ដោយបរមត្ថ បានដល់ ជីវិតិន្ទ្រិយ ២ យ៉ាង គឺ រូបជីវិតិន្ទ្រិយ ១ និង នាមជីវិតិន្ទ្រិយ ១ ។ មាន វធកចេតនា (ចេតនាសម្លាប់) តែសត្វមិនបានស្លាប់ អកុសលចិត្តនោះមិន ជាកាយកម្មទេព្រោះមិនបានដាច់កម្មបថ គ្រាន់តែជ្រាបថា អកុសលចិត្ត នេះ ជាកាយទុច្ចរិតម៉្យាង។

### អាការៈមាន ៥ យ៉ាង គឺ៖

**១- ដោយមូល** សិក្ខាបទនេះកើតឡើងព្រោះ ទោសៈ និង មោហៈជា មូល។

**២- ដោយកម្ម** ជាកាយកម្មព្រោះសម្រេចដោយការធ្វើតាមផ្លូវកាយ។

**៣- ដោយទ្វារ** ជាកាយទ្វារ និង វចីទ្វារ។

**៤- ដោយសាវជ្ជៈ** សម្លាប់សត្វមានគុណច្រើន មានមនុស្សជាដើម មាន ទោសធ្ងន់ ។ សម្លាប់សត្វមានគុណតិច មានទោសស្រាល ។ សម្លាប់សត្វ មានសីល មានទោសធ្ងន់ សម្លាប់សត្វអត់សីល មានទោសស្រាល ។ សម្លាប់សត្វធំមានទោសធ្ងន់ សម្លាប់សត្វតូចមានទោសស្រាល។សម្លាប់-

សត្វមានគុណមានសរីរៈស្មើគ្នាបើកិលេស និង សេចក្តីព្យាយាមខ្លាំងមានទោសធ្ងន់ បើកិលេស និង សេចក្តីព្យាយាមខ្សោយ មានទោសស្រាល ។

**៥. ដោយអង្គ មានអង្គ ៥ គឺ៖**

**១. បាណោ** សត្វមានជីវិត

**២. បាណសញ្ញិតា** សេចក្តីដឹងថាសត្វមានជីវិត

**៣. វធកចិត្តំ** គិតនឹងសម្លាប់

**៤. ឧបក្កមោ** ព្យាយាមនឹងសម្លាប់

**៥. តេន មរណំ** សត្វស្លាប់ដោយព្យាយាមនោះ។

បើគ្រប់អង្គទាំង ៥ ហើយឈ្មោះថាដាច់កម្មបថ (ដាច់សីល) អាចឱ្យផលបដិសន្ធិក្នុងអបាយភូមិបាន។

ប្រសិនបើមិនគ្រប់អង្គ ៥ ទេ មិនដល់ភាពជាកម្មបថទេ (សីលមិនដាច់) តែជាទុច្ចរិតកម្មមិននាំឱ្យបដិសន្ធិក្នុងអបាយភូមិទេ ប៉ុន្តែឱ្យផលក្នុងបវត្តិកាល គឺ បន្ទាប់ពីបដិសន្ធិរហូតដល់ចុតិ។

**បាណាតិបាត មានប្រយោគ ៦ គឺ៖**

**១- សាហត្ថិកបយោគ** សម្លាប់ដោយដៃខ្លួនឯង

**២- អាណត្តិកបយោគ** សម្លាប់ដោយប្រើអ្នកដទៃ

**៣-និស្សគ្គិយបយោគ** សម្លាប់ដោយវត្ថុសម្រាប់ចោល ឬគ្រវែងជាដើម។

**៤-ថាវរបយោគ** សម្លាប់ដោយវត្ថុនៅនឹងមួយកន្លែង ដូចជាអន្ទាក់ អន្លង់ ចម្រូងជាដើម។

**៥- វិជ្ជាមយបយោគ** សម្លាប់ដោយវិជ្ជា រាយមន្តអាគមជាដើម ។

**៦- ឥទ្ធិមយបយោគ** សម្លាប់ដោយឫទ្ធិ សម្រេចដោយផលដែលកើតអំពី

កម្មដូចជាឫទ្ធិនាគជាដើម។

## ២.អទិន្នាទាន

ការកាន់យកនូវវត្ថុ ដែលគេមិនបានឱ្យដោយកាយ ឬ ដោយវាចា ឈ្មោះថា **អទិន្នាទាន** គឺ កាន់យកដោយថេយ្យចេតនា (ចេតនាលួច) ។

**អាការៈមាន ៥ យ៉ាងគឺ ៖**

**១-ដោយមូល**

- មានលោភៈ និង មោហៈ ជាមូលព្រោះលួចដើម្បីបានមកជារបស់ខ្លួន។
- មានទោសៈ និង មោហៈ ជាមូលព្រោះលួចមិនដើម្បីបានមកជារបស់ខ្លួនទេ តែប្រាថ្នាចង់ឱ្យម្ចាស់ទ្រព្យ ខូចខាតទ្រព្យរបស់ ។ កម្មបថទី ២ នេះមានមូលសរុប ៣ គឺ លោភៈ ទោសៈ មោហៈ។

**២- ដោយកម្ម** ជាកាយកម្ម

**៣- ដោយទ្វារ** ប្រព្រឹត្តទៅបានទ្វារពីរ គឺ កាយទ្វារ ១ និង វចីទ្វារ១។

**៤- ដោយសាវជ្ជៈ** លួចវត្ថុល្អ មានតម្លៃច្រើន មានទោសធ្ងន់ លួចវត្ថុអន់មានតម្លៃតិចមានទោសស្រាល ។ លួចវត្ថុដែលម្ចាស់របស់មានគុណច្រើនឬមានសីល មានទោសធ្ងន់ ។ លួចវត្ថុដែលម្ចាស់របស់មានគុណតិចឬមិនមានសីល មានទោសស្រាល ។ លួចវត្ថុធំ មានទោសធ្ងន់ លួចវត្ថុតូចមានទោសស្រាល។ បើវត្ថុ និង គុណនៃម្ចាស់វត្ថុស្មើគ្នា កិលេស និង ការព្យាយាមក្នុងការលួចខ្លាំង មានទោសធ្ងន់ កិលេស និង ការព្យាយាមក្នុងការលួចខ្សោយ មានទោសស្រាល ។

**៥. ដោយអង្គ មានអង្គ ៥ គឺ ៖**

**១. បរបរិគ្គហិតំ** ទ្រព្យដែលម្ចាស់គេហួងហែងរក្សា

**២. បរបរិគ្គហិតសញ្ញិតា** សេចក្ដីដឹងថាទ្រព្យនោះ មានម្ចាស់ហួងហែង-រក្សា ។

**៣. ថេយ្យចិត្តំ** គិតនឹងលួច

**៤. ឧបក្កមោ** ព្យាយាមនឹងលួច

**៥. តេន ហរណំ** លួចបានដោយព្យាយាមនោះ ។

**សិក្ខាបទនេះមានប្រយោគ ១៣ គឺ ៖**

**១. អាទិយន** លួចដោយចោទប្រកាន់យក។

**២. អវហរណ** លួចដោយឆបោកយកទ្រព្យបញ្ញើ។

**៣. ធុរនិក្ខេប** លួចដោយការដាក់ចុះធុរៈ។

**៤. ហរណ** លួចដោយការនាំទៅ។

**៥. អាណត្តិកៈ** លួចដោយបង្គាប់បញ្ជាពីអ្នកដទៃ។

**៦. សាហត្ថិកៈ** លួចដោយដៃខ្លួនឯង។

**៧. និស្សគ្គិយ** លួចដោយការគ្រវែង ឬ បោះចោល។

**៨. សំវិធាវហារ** លួចដោយការបបួលគ្នា។

**៩. សង្កេត និម្មិត្តកម្ម** លួចដោយការកំណត់ពេលវេលាឬ ធ្វើនិមិត្តប្រាប់ ។

**១០.ថេយ្យាវហារ** ការលួចដូចជាចោរ។

**១១. បសយ្ហាវហារ** លួចដោយការគំរាម កំហែងដណ្តើម ឬ ប្លន់ជាដើម។

**១២. បដិច្ឆន្នាវហារ** លួចដោយការបិទបាំងទុក។

**១៣. កុសាវហារ** លួចដោយការប្តូរស្លាក។

## ៣. កាមេសុមិច្ឆាចារៈ

ពាក្យថា **កាមេសុ** ក្នុងកាមទាំងឡាយ សំដៅដល់ការសេពមេថុន-ធម្ម ។

ពាក្យថា **មិច្ឆាចារៈ** ការប្រព្រឹត្តខុស គឺប្រព្រឹត្តលាមក ដែលរួមពាក្យទាំងពីរឃ្លាបានជា **កាមេសុមិច្ឆាចារៈ** ដែលប្រែថា ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។ បើពោលដោយលក្ខណៈ សំដៅដល់ចេតនា ជាហេតុឱ្យប្រព្រឹត្តកន្លងល្មើសក្នុងអគមនីយដ្ឋានទាំង ២០ ដែលប្រព្រឹត្តទៅតាមកាយទ្វារដោយបំណងអសទ្ធម្ម។

### អគមនីយដ្ឋាន ២០

**១. មាតុរក្ខិតា** ស្ត្រីដែលមាតារក្សា
**២. បិតុរក្ខិតា** ស្ត្រីដែលបិតារក្សា
**៣. មាតាបិតុរក្ខិតា** ស្ត្រីដែលមាតា និង បិតារក្សា
**៤. ភាតុរក្ខិតា** ស្ត្រីដែលបងប្អូនប្រុសគ្រប់គ្រងរក្សា
**៥. ភគិនីរក្ខិតា** ស្ត្រីដែលបងប្អូនស្រីគ្រប់គ្រងរក្សា
**៦. ញាតិរក្ខិតា** ស្ត្រីដែលញាតិគ្រប់គ្រងរក្សា
**៧. គោត្តរក្ខិតា** ស្ត្រីដែលត្រកូលគ្រប់គ្រងរក្សា
**៨. ធម្មរក្ខិតា** ស្ត្រីដែលសង្ឃគ្រប់គ្រងរក្សា

ស្ត្រីទាំង ៨ ពួកនេះ បើបុរសណាមួយ ទៅប្រព្រឹត្តមេថុនធម្មជាមួយហើយ រមែងត្រូវទោសកាមេសុមិច្ឆាចារៈ តែខាងបុរសប៉ុណ្ណោះ ឯស្ត្រីវិញមិនត្រូវទោសនេះឡើយ។

| | |
|---|---|
| ៩.សារក្ខា | ស្ត្រីដែលគេស្តីដណ្តឹងទុកហើយ ឬ ស្ត្រីដែលគេថែចូវទុកតាំងតែពីនៅក្នុងផ្ទៃមាតា។ |
| ១០.សបរិទណ្ឌា | ស្ត្រីដែលគេលាក់ទុកក្នុងផ្ទះ ឬ ក្នុងផ្លូវណាមួយដើម្បីធ្វើភរិយា។ |
| ១១.ធនក្កីតា | ស្ត្រីដែលគេទិញដូរដោយទ្រព្យ។ |
| ១២.ឆន្ទវាសិនី | ស្ត្រីដែលទៅនៅរួមជាមួយបុរសតាមសេចក្តីស្នេហ៍គ្រចិត្តរបស់ខ្លួន។ |
| ១៣.ភោគវាសិនី | ស្ត្រីដែលទៅនៅរួមជាមួយ និង បុរសណាមួយដោយសារឃើញគេមានភោគទ្រព្យ។ |
| ១៤.បដិវាសិនី | ស្ត្រីដែលទៅនៅរួមជាមួយបុរសណាមួយ ដោយអំណាចមានសំពត់ជាដើម។ |
| ១៥.ឱទបត្តកិនី | ស្ត្រីដែលញាតិបានរៀបចំតាមច្បាប់ប្រពៃណី រួចឱ្យលូកដៃក្នុងផ្តិលទឹកជាមួយគ្នា។ |
| ១៦.ឱភតចុម្ពជា | ស្ត្រីដែលបុរសជួយដាក់ទ្រនូលមានឧសជាដើម។ |
| ១៧. ទាសីភរិយា | ស្ត្រីដែលបុរសយកខ្ញុំស្រីរបស់ខ្លួនធ្វើជាភរិយា។ |
| ១៨. កម្មការីភរិយា | ស្ត្រីជាកម្មការិនី ដែលបុរសយកធ្វើជាភរិយា។ |
| ១៩.ធជាហដា | ស្ត្រីដែលសេនាទាហានចាប់យកបានមក ដោយអំណាចនៃទង់ជ័យ ដើម្បីធ្វើជាភរិយា។ |
| ២០.មុហុត្តិកា | ស្ត្រីដែលបុរសលាក់ទុកក្នុងកន្លែងណាមួយ ហើយបានកំណាន់ចិត្តថា នឹងទៅនៅរួមសំវាស ម្តង-ម្កាល ។ |

## ដោយអាការៈ ៥ យ៉ាង គឺ៖

**១- ដោយមូល** មានលោភៈ និង មោហៈ ជាមូល

**២- ដោយកម្ម** ជាកាយកម្ម

**៣- ដោយទ្វារ** ជាកាយទ្វារ ប៉ុណ្ណោះ

**៤- ដោយសាវជ្ជៈ** គឺ ទោស

-ប្រព្រឹត្តល្មើសលើបុគ្គលមានសីលមានគុណច្រើន មានទោសធ្ងន់ លើបុគ្គលមិនមានសីល ឬមានគុណតិច មានទោសស្រាល។

-បើមិនមានឆន្ទៈរួមគ្នាទេ មានទោសធ្ងន់ (គឺការចាប់បង្ខំ) តែបើមានឆន្ទៈត្រូវគ្នាមានទោសស្រាល បើកិលេស និង ការព្យាយាមខ្លាំង មានទោសធ្ងន់ បើកិលេស និង ការព្យាយាមខ្សោយ មានទោសស្រាល។

**៥- ដោយអង្គ មានអង្គ ៤ គឺ៖**

**១- អគមនីយវត្ថុ** វត្ថុដែលមិនគួរទាក់ទង (បានដល់ស្ត្រី ២០ ពួក)

**២- តស្មឹ សេវនចិត្តំ** គិតនឹងសេពក្នុងវត្ថុដែលមិនគួរទៅទាក់ទងនោះ។

**៣- ឧបក្កមោ** ព្យាយាមក្នុងការសេព។

**៤- មគ្គេន មគ្គប្បដិបាទនំ** ញ៉ាំងមគ្គ និង មគ្គឱ្យដល់គ្នា។

## សិក្ខាបទនេះមានប្រយោគតែមួយ គឺ៖

**សាហត្ថិកបយោគ** (ធ្វើដោយខ្លួនឯង )។

## ៤.មុសាវាទ

កាយប្រយោគ ឬ វចីប្រយោគ ប្រកបដោយចេតនាដែលប៉ងឱ្យអ្នកដទៃដឹងអ្វីមួយខុសពីការពិត ឈ្មោះថា **មុសាវាទ** ។

## ដោយអាការៈមាន ៥ យ៉ាងគឺ៖

**១-ដោយមូល**

-មាន **លោភៈ ទោសៈ** និង **មោហៈ** ជាមូលព្រោះកុហកដោយសេចក្ដីជាប់ជំពាក់ចង់បានអ្វីមួយ ឬ កុហកដើម្បីសើចលេងជាដើម។

-ដោយ **ទោសៈ** និង **មោហៈ** ជាមូលព្រោះកុហកដោយសេចក្ដី ក្រេវក្រោធ **បដិឃៈ** ថ្នាំងថ្នាក់ ដោយបំណង ឱ្យអ្នកដទៃវិនាស។

**២- ដោយកម្ម** ជាវចីកម្ម

**៣- ដោយទ្វារ** ប្រព្រឹត្តទៅបានទ្វារពីរគឺ៖

- **វចីទ្វារ** គឺការនិយាយកុហក

**-កាយទ្វារ** គឺការកុហកតាមផ្លូវកាយ ដោយធ្វើនិមិត្តសញ្ញាដូចជាញាក់ចិញ្ចើម ងក់ក្បាល ឬសរសេរសំបុត្រជាដើម ។

**៤. ដោយសាវជ្ជៈ** គឺ ទោស

-កុហកឱ្យគេខូចប្រយោជន៍ច្រើន មានទោសធ្ងន់ ខូចប្រយោជន៍តិចមានទោសស្រាល។

-មានទ្រព្យតែនិយាយថាមិនមាន ដោយបំណងមិនចង់ឱ្យមានទោសស្រាល តែបើមានបំណងចង់ឱ្យអ្នកមកខ្ចីនោះខូចប្រយោជន៍ មានទោសធ្ងន់។

-បើកិលេស និង ការព្យាយាមខ្លាំង មានទោសធ្ងន់ កិលេស និង ការព្យាយាមតិច មានទោសស្រាល ។

**ឧទាហរណ៍៖** កុហកឱ្យគេខឹង គឺកុហកឱ្យគេវិនាស។

**៥. ដោយអង្គ មានអង្គ ៤ គឺ៖**

**១. អតថំវត្ថុ** វត្ថុមិនពិត

**២. វិសំវាទនចិត្តំ** គិតនឹងពោលឱ្យខុស

**៣. តជ្ជោ វាយាមោ** ព្យាយាមនឹងពោលឱ្យខុស

**៤. បរស្ស តទត្ថវិជាននំ** ញុំាងអ្នកដទៃ ឱ្យដឹងច្បាស់នូវសេចក្តីនោះ។

**- សិក្ខាបទនេះមានប្រយោគតែមួយ** គឺ សាហត្ថិកប្រយោគ។

**៥. បិសុណាវាចា** (ញុះញង់អ្នកដទៃឱ្យបែកបាក់គ្នា )

សំដៅដល់សង្កិលិដ្ឋចេតនា គឺចេតនាសៅហ្មងរបស់អ្នកដែលមានចិត្តត្រូវទោសគឺ ទោសៈ លោភៈ បៀតបៀននិយាយញុះញង់បំបែកបំផ្លាញអ្នកដទៃដើម្បីឱ្យខ្លួនឯងបានជាទីស្រឡាញ់ ។ ឯអ្នកដទៃជាទីស្អប់ និង ដើម្បីឱ្យអ្នកដទៃកើតនូវការឈឺចាប់ ឬ សំដៅដល់ការនិយាយអែបអបបញ្ចុកបន្ស៊ុជាដើម។

**ដោយអាការៈ ៥ យ៉ាងគឺ ៖**

**១- ដោយមូល** កើតព្រោះលោភៈ និង មោហៈ ជាមូលក៏មាន កើតព្រោះទោសៈ និង មោហៈជាមូលក៏មាន តែយើងអាចនិយាយសរុបថា មានលោភៈ ទោសៈ និង មោហៈជាមូលក៏បាន ។

**២- ដោយកម្ម** ជាវចីកម្ម។

**៣- ដោយទ្វារ** ប្រព្រឹត្តទៅបានទ្វារពីរ គឺ កាយទ្វារ និង វចីទ្វារ ។

**៤-ដោយសាវជ្ជៈ** គឺ ទោស

-ពោលព្យុះញុង់បុគ្គលមានសីលមានគុណច្រើន មានទោសធ្ងន់ មានសីលមានគុណតិច មានទោសស្រាល។

-បើអ្នកដទៃបែកបាក់គ្នា ព្រោះការញុះញុង់នោះមានទោសធ្ងន់ បើមិនបែកបាក់គ្នាទេមានទោសស្រាល ។

-កិលេស និង ព្យាយាមខ្លាំង មានទោសធ្ងន់ កិលេស និង ព្យាយាមខ្សោយ មានទោសស្រាល ។

**៥- ដោយអង្គ មានអង្គ ៤ គឺ៖**

**១. ភិន្ទិតព្វោ បរោ** មានអ្នកដទៃដែលខ្លួនគប្បីញុះញុង់បំបែក។

**២. ភេទនបុរេក្ខារតា** គិតនឹងញុះញុង់បំបែកអ្នកដទៃនោះ។

**៣. តជ្ជោ វាយាមោ** ព្យាយាមដើម្បីញុះញុង់។

**៤. តស្ស តទត្ថវិជាននំ** អ្នកដទៃនោះ ដឹងនូវការញុះញុង់នោះ។

**៦. ផរុសវាចា** (ចេតនាអាក្រក់)

សំដៅដល់ចេតនាអាក្រក់កំណាចនៃអ្នកដែលនិយាយ ពាក្យអាក្រក់ មិនជាទីស្រឡាញ់ មិនធ្វើឱ្យសប្បាយចិត្ត ឬ ការជេរប្រទេចនោះឯង ដែលកើតឡើងព្រោះទោសៈ បៀតបៀនសន្តានចិត្ត។

**ដោយអាការៈ ៥ យ៉ាងគឺ ៖**

**១- ដោយមូល** មានទោសៈ និង មោហៈ ជាមូល

**២- ដោយកម្ម** ជាវចីកម្ម

**៣- ដោយទ្វារ** ជាកាយទ្វារ និង វចីទ្វារ

**៤- ដោយសារម្មណ៍:** គឺ ទោស

-ជេរបុគ្គលមានគុណច្រើន មានទោសធ្ងន់ មានគុណតិច មានទោសស្រាល ។

-កិលេស និង ការព្យាយាមខ្លាំង មានទោសធ្ងន់ កិលេស និង ការព្យាយាមខ្សោយ មានទោសស្រាល។

**៥- ដោយអង្គ** មានអង្គ ៣ គឺ ៖

**១.អក្កោសិតព្វោ បរោ** មានអ្នកដទៃ ដែលខ្លួនគប្បីជេរ។

**២.កុប្បិតចិត្តំ** មានចិត្តខឹងក្រោធ។

**៣.អក្កោសនា** បានជេរប្រទេច ។

## ៧. សម្ផប្បលាបៈ

សំដៅដល់ចេតនាពោលនូវរឿងឥតប្រយោជន៍ ឱ្យអ្នកដទៃដឹង (អនត្ថវិញ្ញាបិកាចេតនា)។

### ដោយអាការៈ ៥ យ៉ាងគឺ ៖

**១- ដោយមូល** ដោយអកុសលមូល ៣ (លោភៈ ទោសៈ មោហៈ)។

**២- ដោយកម្ម** ជាវចីកម្ម

**៣- ដោយទ្វារ** ជាកាយទ្វារ និង វចីទ្វារ

**៤- ដោយសាវជ្ជៈ** គឺ ទោស

-ប្រសិនបើសេពច្រើន (ធ្វើផងនិយាយផង) មានទោសធ្ងន់, ធ្វើតិចមានទោសស្រាល។

-ប្រសិនបើអ្នកដទៃកាន់យកនូវពាក្យដែលមិនមានប្រយោជន៍នោះ មានទោសធ្ងន់ បើមិនកាន់យកទេមានទោសស្រាល។

**៥-ដោយអង្គ មានអង្គ ២**

**១-ភារតយុទ្ធសិតាហរណាទិនិរត្ថកថា** ពាក្យឥតប្រយោជន៍មានរឿងចម្បាំងនៃភារត និង រឿងរាពណ៍លួចនាងសេដាទៅជាដើម។

**២-តថារូបីកថាកថនំ** បានពោលនូវរឿងដែលមិនមានប្រយោជន៍ មានសភាពដូច្នេះ។

## ៨. អភិជ្ឈា

ធម្មជាតិដែលសម្លឹងរំពៃ ចង់បាននូវភណ្ឌ (ទ្រព្យរបស់អ្នកដទៃ) ឱ្យបានមកជារបស់ខ្លួន ឈ្មោះថា **អភិជ្ឈា** ។ ប៉ុន្តែបើគ្រាន់តែឃើញរបស់គេថាស្រស់ល្អប៉ុណ្ណោះទេ មិនមែនជា **អភិជ្ឈា** ឡើយ គ្រាន់តែជាលោភមូលចិត្តដែលជាមនោទុច្ចរិតប៉ុណ្ណោះ។

**ដោយអាការៈ ៥ យ៉ាង គឺ ៖**

**១- ដោយមូល** មានលោភៈ និង មោហៈ ជាមូល។

**២- ដោយកម្ម** ជាមនោកម្ម។

**៣- ដោយទ្វារ** ប្រព្រឹត្តបានទាំង ៣ ទ្វារ។

**៤- ដោយសាវជ្ជៈ** ដូចសាវជ្ជៈ របស់អទិន្នាទានដែរ។

**៥-ដោយអង្គ មានអង្គ ២ គឺ៖**

**១-បរភណ្ឌំ** ទ្រព្យរបស់អ្នកដទៃ។

**២-អត្តនោ បរិណាមនំ** មានការបង្អោនទ្រព្យនោះមកជារបស់ខ្លួន ( ដោយទុច្ចរិតកម្មផ្សេងៗ )។

## ៩. ព្យាបាទ

អង្គធម៌បានដល់ទោសៈ។សភាវធម៌ដែលញុំាងប្រយោជន៍ សេចក្ដីចម្រើន និង សេចក្ដីសុខ ឱ្យវិនាសឈ្មោះថា **ព្យាបាទ**។

**ព្យាបាទ** នោះមានបំណងអាក្រក់ឱ្យគេវិនាសជា លក្ខណៈ បានដល់ ចេតនាដែលប្រព្រឹត្តទៅជាមួយនឹងសេចក្ដីក្រោធដ៏មានកម្លាំងរហូតដល់ចង់ឱ្យអ្នកដទៃវិនាស ។ សភាពដូច្នេះជាមនោកម្មបថ ។ បើគ្រាន់តែខឹងក្រោធមិនចូលចិត្ត ក៏ត្រឹមតែជាទោសមូលចិត្ត ជាអកុសលចិត្តប៉ុណ្ណោះមិនជា មនោកម្មបថឡើយ។

### ដោយអាការៈ ៥ យ៉ាងគឺ ៖

**១- ដោយមូល** មានទោសៈ និង មោហៈ ជាមូល។

**២- ដោយកម្ម** ជាមនោកម្ម។

**៣- ដោយទ្វារ** ប្រព្រឹត្តទៅបានទាំង ៣ ទ្វារ ។

**៤- ដោយសាវជ្ជៈ** ដូចគ្នានឹងផរុសវាទដែរ ។

**៥- ដោយអង្គ មានអង្គ ២ គឺ៖**

**១-បរសត្តោ** អ្នកដទៃក្រៅអំពីខ្លួន។

**២-តស្ស តំ តំ វិនាសចិន្តា** គិតចងគំនុំគុំគួននឹងអ្នកនោះ ដល់នូវសេចក្ដីវិនាសដោយហេតុនោះ។

## ១០. មិច្ឆាទិដ្ឋិ

មិច្ឆាទិដ្ឋិបានដល់ចេតនា ដែលកើតរួមនឹងសេចក្ដីយល់ឃើញខុសដ៏មានកម្លាំង ដោយការមិនកាន់យកតាមសេចក្ដីពិត ។ **មិច្ឆាទិដ្ឋិ** នោះមាន

ការវិបរិត គឺឃើញខុស ឬឃើញផ្ទុយពីការពិតជា លក្ខណៈ ដូចជាយល់ឃើញថា ទាន មិនមានផលជាដើម (**នត្ថិ ទានំ**) ជាចេតនាដែលជឿជាក់ក្នុងការឃើញខុសនោះ យ៉ាងណែនស៊ប់ ។

**ដោយអាការៈ ៥ យ៉ាង គឺ ៖**

**១- ដោយមូល** មានលោភៈ និង មោហៈ ជាមូល។

**២- ដោយកម្ម** ជាមនោកម្ម។

**៣- ដោយទ្វារ** ប្រព្រឹត្តទៅបានទាំង ៣ ទ្វារ ។

**៤- ដោយសាវជ្ជៈ** សេពច្រើន មានទោសធ្ងន់ សេពតិចមានទោសស្រាល បើជា **និយតមិច្ឆាទិដ្ឋិ** មានទោសធ្ងន់ បើជា **អនិយតមិច្ឆាទិដ្ឋិ** មានទោសស្រាល។

**៥- ដោយអង្គ មានអង្គ ២ គឺ៖**

**១-វត្ថុនោ ច គហិតាការវិបរិតតា** សភាពនៃរឿងទាំងឡាយវិបរិតចាក ពីអាការៈ ដែលគួរកាន់យក គឺ ព្រះរតនត្រ័យ ជាដើម ។

**២-យថា ច តំ គណ្ហាតិ តថាភាវេន តស្សូបដ្ឋានំ** ការប្រកាន់នូវរឿង ដោយសេចក្ដីមិនពិតនោះក៏ប្រាកដ។

**និយតមិច្ឆាទិដ្ឋិ** ប៉ុណ្ណោះដែលចាត់ជាកម្មបថ ១០ នេះ **មិច្ឆាទិដ្ឋិ** ក្រៅ-ពីនោះ មិនបានរាប់បញ្ចូលឡើយ។

**មិច្ឆាទិដ្ឋិ ១០** (ជាហេតុនៃការប្រព្រឹត្តខុសទាំងពួង)

**១-នត្ថិ ទានំ** យល់ថា ទានមិនមានផល ។

**២-នត្ថិ យិដ្ឋំ** យល់ថា ការបូជាមិនមានផល ។

**៣-នត្ថិ ហុតំ** យល់ថា សក្ការៈ ដែលបុគ្គលធ្វើហើយមិនមានផល។

**៤-នត្ថិ សុកតទុក្កតានំ កម្មានំ ផលវិបាកោ** យល់ថា ផលវិបាករបស់កម្ម ដែលសត្វធ្វើល្អ នឹងអាក្រក់មិនមាន។

**៥-នត្ថិ អយំ លោកោ** យល់ថា លោកនេះមិនមាន។

**៦-នត្ថិ បរោ លោកោ** យល់ថាលោកដទៃមិនមាន។

**៧-នត្ថិ មាតា** យល់ថាមាតាមិនមានគុណ។

**៨-នត្ថិ បិតា** យល់ថាបិតាមិនមានគុណ។

**៩-នត្ថិ សត្តា ឱបបាតិកា** យល់ថាសត្វជាឱបបាតិកៈកំណើតមិនមាន។

**១០-នត្ថិ លោកេ សមណព្រាហ្មណា សមគតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ** យល់ថា ពួកសមណៈ និង ព្រាហ្មណ៍ក្នុងលោកដែលព្រមព្រៀងប្រព្រឹត្តប្រតិបត្តិធម៌ហើយពោលថា បានធ្វើឱ្យជាក់ច្បាស់នូវលោកនេះ នឹងលោកខាងមុខមិនមាន ។

## វិនិច្ឆ័យអកុសលកម្មបថ ១០ ដោយអាការៈ ៥ យ៉ាង

### ១. ដោយធម៌

ក្នុងបណ្តាអកុសលកម្មបថទាំង ១០ នោះ អកុសលកម្មបថ ៧ ខាងដើម គឺ កាយកម្ម ៣ និង វចីកម្ម ៤ កាលបើពោលដោយអង្គធម៌ បានដល់ **ចេតនាចេតសិក** ប៉ុណ្ណោះ , ចំណែកមនោកម្ម ៣ អង្គធម៌ គឺចេតសិកដែលប្រកប និង ចេតនាដូច្នេះគឺ ៖

- **អភិជ្ឈា** អង្គធម៌ គឺ លោភចេតសិក
- **ព្យាបាទ** អង្គធម៌ គឺ ទោសចេតសិក
- **មិច្ឆាទិដ្ឋិ** អង្គធម៌ គឺ ទិដ្ឋិចេតសិក

### ២. ដោយកោដ្ឋាសៈ

អកុសលកម្មបថ ៨ គឺ កាយកម្ម ៣ វចីកម្ម ៤ និង មិច្ឆាទិដ្ឋិ គឺ ជាកម្មបថសុទ្ធ ចំណែកមនោកម្ម ២ ទៀត គឺ អភិជ្ឈា ជាលោភៈ និងព្យាបាទ ជាទោសៈ ជាកម្មបថផង ជាមូលផង។

## ៣. ដោយអារម្មណ៍

**១-បាណាតិបាត** មានសង្ខារ (ជីវិតិន្ទ្រិយ)ជាអារម្មណ៍ ។

**២-អទិន្នាទាន** មានសត្វ ឬសង្ខារជាអារម្មណ៍ ។

**៣-កាមេសុមិច្ឆាចារៈ** មានសង្ខារ(ផោដ្ឋព្វៈ) ជាអារម្មណ៍។

**៤-មុសាវាទ** មានសត្វ ឬសង្ខារជាអារម្មណ៍។

**៥-បិសុណាវាទ** មានសត្វ ឬ សង្ខារជាអារម្មណ៍។

**៦-ផរុសវាទ** មានសត្វជាអារម្មណ៍។

**៧-សម្ផប្បលាបៈ** មានសត្វ ឬសង្ខារជាអារម្មណ៍ ។

**៨-អភិជ្ឈា** មានសត្វ ឬសង្ខារជាអារម្មណ៍។

**៩-ព្យាបាទ** មានសត្វជាអារម្មណ៍។

**១០-មិច្ឆាទិដ្ឋិ** មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ (ជាបរមត្ថ)។

## ៤. ដោយវេទនា

**១-បាណាតិបាត** ប្រកបដោយវេទនា (ទោមនស្សវេទនា ឬ ទុក្ខ-វេទនា)។

**២-អទិន្នាទាន** ប្រកបដោយវេទនា ៣។

**៣-កាមេសុមិច្ឆាចារៈ** ប្រកបដោយវេទនា ២ គឺសុខវេទនា និង អទុក្ខម-សុខវេទនា។

៤-មុសាវាទ ប្រកបដោយវេទនា ៣។

៥-បិសុណាវាទ ប្រកបដោយវេទនា ៣។

៦-ផរុសវាទ ប្រកបដោយវេទនា ១ (ទុក្ខវេទនា)។

៧-សម្ផប្បលាប ប្រកបដោយវេទនា ៣។

៨-អភិជ្ឈា ប្រកបដោយវេទនា ២។

៩-ព្យាបាទ ប្រកបដោយវេទនា ១។

១០-មិច្ឆាទិដ្ឋិ ប្រកបដោយវេទនា ២ (ទុក្ខវេទនា និង ឧបេក្ខា-វេទនា)។

## ៥ . ដោយមូល

១-បាណាតិបាត មានមូល ២ គឺ ទោសៈ និង មោហៈ។

២-អទិន្នាទាន មានមូល ៣ គឺ ទោសៈ និង មោហៈ ឬលោភៈ និង មោហៈ។

៣-កាមេសុមិច្ឆាចារៈ មានមូល ២ គឺ លោភៈ និង មោហៈ។

៤-មុសាវាទ មានមូល ៣។

៥-បិសុណាវាទ មានមូល ៣។

៦-ផរុសវាទ មានមូល ២ គឺ ទោសៈ និង មោហៈ។

៧-សម្ផប្បលាបៈ មានមូល ៣។

៨-អភិជ្ឈា មានមូល ១ គឺ មោហៈ។

៩-ព្យាបាទ មានមូល ១ គឺ មោហៈ។

១០-មិច្ឆាទិដ្ឋិ មានមូល ២ គឺ លោភៈ មោហៈ។

**អកុសលចិត្តជាហេតុឱ្យកើតអកុសលកម្មបថដូច្នេះគឺ ៖**

**១-លោភមូលចិត្ត ៨** ជាហេតុឱ្យកើតអកុសលកម្មបថ ៧ គឺ កាយកម្ម ២ (វៀរបាណាតិបាត) វចីកម្ម ៣ (វៀរផរុសវាទ)និងមនោកម្ម២ (វៀរព្យាបាទ)
**២-ទោសមូលចិត្ត ២** ជាហេតុឱ្យកើតអកុសលកម្មបថ ៧ គឺ កាយកម្ម ២ (វៀរកាមេសុមិច្ឆាចារៈ)វចីកម្ម ៤និងមនោកម្ម១(វៀរអភិជ្ឈា និងមិច្ឆាទិដ្ឋិ)។
**៣-មោហមូលចិត្ត ២** មិនជាហេតុឱ្យដាច់អកុសលកម្មបថ ១០ ណាមួយទេ។

តែជាហេតុឱ្យកើតទុច្ចរិតកម្ម ១០ គឺកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ និងមនោទុច្ចរិត ៣។

## <u>វិបាករបស់អកុសលកម្មបថ</u>

| | |
|---|---|
| **១-បាណាតិបាត** | ទោសធ្ងន់ឱ្យកើតក្នុងអបាយភូមិ ទោសស្រាល កាលកើតជាមនុស្សមានអាយុខ្លី ។ |
| **២-អទិន្នាទាន** | ទោសធ្ងន់កើតក្នុងអបាយភូមិ ទោសស្រាល កាលកើតជាមនុស្សធ្វើឱ្យវិនាសទ្រព្យ។ |
| **៣-កាមេសុមិច្ឆាចារៈ** | ទោសធ្ងន់ឱ្យធ្លាក់ក្នុងអបាយភូមិ ទោសស្រាល កាលកើតជាមនុស្សមានពៀរ សត្រូវច្រើន។ |
| **៤-មុសាវាទ** | ទោសធ្ងន់ឱ្យកើតក្នុងអបាយភូមិ ទោសស្រាល កាលកើតជាមនុស្សត្រូវគេបន្លំឆបោក។ |
| **៥-បិសុណាវាទ** | ទោសធ្ងន់ឱ្យកើតក្នុងអបាយភូមិ ទោសស្រាល កាលកើតជាមនុស្សតែងបែកបាក់មិត្ត។ |

| | |
|---|---|
| **៦-ផរុសវាទ** | ទោសធ្ងន់ឱ្យកើតក្នុងអបាយភូមិ ទោសស្រាលកាលកើតជាមនុស្សនាំឱ្យឮសម្លេងមិនចូលចិត្ត។ |
| **៧-សម្ផប្បលាបៈ** | ទោសធ្ងន់ឱ្យកើតក្នុងអបាយភូមិ ទោសស្រាលធ្វើឱ្យគ្មានអ្នកជឿពាក្យសម្តី។ |
| **៨-អភិជ្ឈា** | ទោសធ្ងន់កើតក្នុងអបាយភូមិ ទោសស្រាលកើតជាមនុស្ស នាំឱ្យបាត់បង់ទ្រព្យ។ |
| **៩-ព្យាបាទ** | ទោសធ្ងន់ឱ្យកើតក្នុងអបាយភូមិ ទោសស្រាលដូចជាផរុសវាទ ដែរ ។ |
| **១០-មិច្ឆាទិដ្ឋិ** | ទោសធ្ងន់កើតក្នុងលោកន្តរនរក ទោសស្រាលកើតក្នុងអបាយភូមិ។ |

« **អដ្ឋធា លោភមូលានិ ទោសមូលានិ ច ទ្វិធា មោហមូលានិ ច ទ្វេតិ ទ្វាទសាកុសលា សិយុំ** »

អកុសលចិត្តទាំងឡាយមាន ១២ គឺ លោភមូលចិត្ត ៨ ដួង ទោសមូលចិត្ត ២ ដួង និង មោហមូលចិត្ត ២ ដួង។

## II. អហេតុកចិត្ត ១៨ ដួង

## ក. អកុសលវិបាកចិត្ត ៧ ដួង

### ១.ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ អកុសលវិបាកចិត្តំ

ចក្ខុវិញ្ញាណដែលជាអកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ( មានការឃើញរូបមិនល្អ )។

**វចនត្ថៈ** របស់ចក្ខុវិញ្ញាណ **ចក្ខុំ និស្សិតំ វិញ្ញាណន្តិ > ចក្ខុវិញ្ញាណំ** ប្រែថា វិញ្ញាណអាស្រ័យចក្ខុបសាទកើតឡើង ឈ្មោះថា **ចក្ខុវិញ្ញាណ** ។

ចក្ខុវិញ្ញាណនេះ ជាវិញ្ញាណម៉្យាងដែលអាស្រ័យនឹងចក្ខុវត្ថុ កើតឡើងដើម្បីដឹងនូវរូបារម្មណ៍ជាលក្ខណៈដូចជា **ចក្ខុនិស្សិតរូប វិជានន ចក្ខុវិញ្ញាណំ។**

## ហេតុនាំឱ្យកើតចក្ខុវិញ្ញាណមាន ៤ យ៉ាង

(អសាធារណហេតុ គឺ ហេតុមិនមានកម្មជាបច្ច័យនាំឱ្យចិត្តកើតឡើង)

- **អសម្ភិន្នត្តា ចក្ខុស្ស** ព្រោះចក្ខុប្រសាទមិនទាន់បែកធ្លាយ
- **អាបាថគតត្តា រូបានំ** ព្រោះរូបមកកាន់គន្លងនៃចក្ខុប្រសាទ
- **អាលោកសន្និស្សិតំ** អាស្រ័យពន្លឺ
- **មនសិការហេតុកំ** មានមនសិការៈជាហេតុជិត

**២. ឧបេក្ខាសហគតំ សោតវិញ្ញាណ អកុសលវិបាកចិត្តំ**

សោតវិញ្ញាណដែលជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ( មានការឮសម្លេងមិនល្អ ដូចជាសម្លេងជេរ ជ្រូកស្រែក សម្លេងឡាន ឬសម្លេងម៉ាស៊ីនខ្លាំង ៗ ជាដើម ។

## ហេតុនាំឱ្យកើតសោតវិញ្ញាណមាន ៤ យ៉ាង

- **អសម្ភិន្នត្តា សោតស្ស** ព្រោះសោតបសាទមិនទាន់បែកធ្លាយ
- **អាបាថគតត្តា សទ្ទានំ** ព្រោះសម្លេងមកកាន់គន្លងនៃសោតបសាទ
- **អាកាសសន្និស្សិតំ** អាស្រ័យអាកាស
- **មនសិការហេតុកំ** មានមនសិការៈជាហេតុជិត

**វចនត្ថៈ** របស់សោតវិញ្ញាណ **សោតំ និស្សិតំ វិញ្ញាណន្តិ** > **សោតវិញ្ញាណំ** វិញ្ញាណដែលអាស្រ័យនឹងសោតបសាទ (វត្ថុ) កើតឡើងឈ្មោះថា **សោតវិញ្ញាណ** ។ សោតវិញ្ញាណ នេះជាវិញ្ញាណម៉្យាងដែលអាស្រ័យ

នឹងសោតវត្ថុកើតឡើងដើម្បីដឹងសម្លេងជាលក្ខណៈ ដូចមានបាលីថា **សោតនិស្សិតសទ្ទវិជាននលក្ខណំ សោតវិញ្ញាណំ** ។

**៣-ឧបេក្ខាសហគតំ ឃានវិញ្ញាណ អកុសលវិបាកចិត្តំ**

ឃានវិញ្ញាណ ចិត្តដែលជាអកុសលវិបាកប្រព្រឹត្តទៅ ជាមួយឧបេក្ខាវេទនា (មានការដឹងក្លិនមិនល្អ ដូចជាក្លិនសាកសព ក្លិនលាមកជា-ដើម ) ។

**<u>ហេតុនាំឱ្យកើតឃានវិញ្ញាណមាន ៤ យ៉ាង៖</u>**

- **អសម្ភិន្នត្តា ឃានស្ស** ព្រោះឃានបសាទមិនទាន់បែកធ្លាយ
- **អាបាថគតត្តា គន្ធានំ** ព្រោះក្លិនមកកាន់គន្លងនៃឃានបសាទ
- **វាយោសន្និស្សិតំ** អាស្រ័យវាយោ (ខ្យល់)
- **មនសិការហេតុកំ** មានមនសិការៈជាហេតុជិត

**វចនត្ថៈ** របស់ឃានវិញ្ញាណ **ឃានំ និស្សិតំ វិញ្ញាណន្តិ** > **ឃានវិញ្ញា-ណំ** វិញ្ញាណដែលអាស្រ័យនឹងឃានវត្ថុកើតឡើងឈ្មោះថា**ឃានវិញ្ញាណ**។ ឃានវិញ្ញាណនេះជាវិញ្ញាណម៉្យាងដែលអាស្រ័យ នឹងឃានវត្ថុកើតឡើងដើម្បីធុំក្លិន ជាលក្ខណៈ ដូចមានបាលីថា **ឃាននិស្សិតគន្ធវិជាននលក្ខណំ ឃានវិញ្ញាណំ** ។

**៤-ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណ អកុសលវិបាកចិត្តំ**

ជិវ្ហាវិញ្ញាណដែលជាអកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (មានការដឹងរសមិនល្អ ដូចជា ល្វីងពេក ហឹរពេក ប្រៃពេក)។

**<u>ហេតុនាំឱ្យកើតជិវ្ហាវិញ្ញាណមាន ៤ យ៉ាង</u>**

- **អសម្ភិន្នត្តា ជិវ្ហាយ** ព្រោះជិវ្ហាបសាទមិនទាន់បែកធ្លាយ

- **អាបាថគតត្តា រសានំ** ព្រោះរសមកកាន់គន្លងនៃជិវ្ហាបសាទ
- **អាបោសន្និស្សិតំ** អាស្រ័យអាបោ គឺ ទឹក
- **មនសិការហេតុកំ** មានមនសិការៈជាហេតុជិត

**វចនត្ថៈ** របស់ជិវ្ហាវិញ្ញាណ **ជិវ្ហំ និស្សិតំ វិញ្ញាណន្តិ > ជិវ្ហាវិញ្ញាណំ** ជិវ្ហាវិញ្ញាណនេះ ជាវិញ្ញាណម៉្យាងដែលអាស្រ័យនឹងជិវ្ហាវត្ថុ (អណ្ដាត) កើតឡើងដើម្បីដឹងរសជាលក្ខណៈ ដូចមានបាលីថា **ជិវ្ហានិស្សិតរសវិជានន ជិវ្ហាវិញ្ញាណំ** វិញ្ញាណដែលអាស្រ័យ នឹងជិវ្ហាវត្ថុកើតឡើងឈ្មោះថា **ជិវ្ហាវិញ្ញាណ** ។

- **ចំណាំ**

រូបដែលកើតអំពីកម្មហៅថា **កម្មជរូប** មិនមែនជាកុសលវិបាក ឬ អកុសលវិបាកទេ ជានាមធម៌ តែម៉្យាង មានចិត្ត និង ចេតសិកប៉ុណ្ណោះ ។

**៥- ទុក្ខសហគតំ កាយវិញ្ញាណ អកុសលវិបាកចិត្តំ**

កាយវិញ្ញាណដែលជាអកុសលវិបាក ប្រព្រឹត្តទៅជាមួយទុក្ខវេទនា មានការដឹងផោដ្ឋព្វៈ មិនល្អ (ដូចជាក្ដៅពេក ត្រជាក់ពេក រឹងពេក ជាដើម)។

**<u>ហេតុនាំឱ្យកើតកាយវិញ្ញាណមាន ៤ យ៉ាង</u>**

**១-អសម្ភិន្នត្តា កាយស្ស** ព្រោះកាយប្រសាទមិនទាន់បែកធ្លាយ

**២-អាបាថគតត្តា ផោដ្ឋព្វានំ** ព្រោះផោដ្ឋព្វៈ មកកាន់គន្លងនៃកាយបសាទ (សំដៅដល់មហាភូតរូប ៣ ដែលគួរដល់ការប៉ះផ្ទប់ និង កាយបសាទ គឺ (**បឋវីធាតុ=** រឹង ទន់) (**តេជោធាតុ** =ក្ដៅ ត្រជាក់) (**វាយោធាតុ** កម្រើក តឹង ញ័រ)។

**៣-បឋវីសន្និស្សិតំ** អាស្រ័យបឋវី

៤.**មនសិការហេតុកំ** មានមនសិការៈជាហេតុជិត

**៦-ឧបេក្ខាសហគតំ មនោធាតុ អកុសលវិបាកចិត្តំ**

មនោធាតុដែលជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅ ជាមួយឧបេក្ខា-វេទនា (មានការទទួលដឹងនូវអារម្មណ៍ មិនល្អ ពីបញ្ចវិញ្ញាណ មានចក្ខុវិញ្ញាណ ជាដើម ) មនោធាតុដឹងអារម្មណ៍ បាន ៥ ហ្នឹងឯង។

**ឧទាហរណ៍៖**ចក្ខុវិញ្ញាណសម្បដិច្ឆន្នៈ,សោតវិញ្ញាណសម្បដិច្ឆន្នៈ។

**ហេតុនាំឱ្យកើតមនោធាតុ ៤ យ៉ាង**

- **អសម្ភិន្នត្តា បសាទស្ស** ព្រោះបសាទរូបមិនទាន់បែកធ្លាយ
- **អាបាថគតត្តា បញ្ចារម្មណានំ** មានអារម្មណ៍ ៥ មកកាន់គន្លង
- **ហទយសន្និស្សិតំ** អាស្រ័យហទយវត្ថុ
- **មនសិការហេតុកំ** មានមនសិការៈជាហេតុជិត

**៧-ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អកុសលវិបាកចិត្តំ**

មនោវិញ្ញាណធាតុដែលជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅ ជាមួយឧបេក្ខាវេទនា មានការដឹងអារម្មណ៍ មិនល្អបានទាំង ៦ (ណាមួយ)។

**ហេតុនាំឱ្យកើតមនោវិញ្ញាណធាតុ ៤ យ៉ាង**

- **អសម្ភិន្នត្តា មនស្ស** ព្រោះមនោមិនទាន់បែកធ្លាយ
- **អាបាថគតត្តា ធម្មារម្មណានំ** ព្រោះមានធម្មារម្មណ៍មកកាន់គន្លង
- **ហទយសន្និស្សិតំ** អាស្រ័យហទយវត្ថុ
- **មនសិការហេតុកំ** មានមនសិការៈជាហេតុជិត

## ចិត្តនេះធ្វើកិច្ចបានដល់នៅ ៥ គឺ៖

**១-សន្តីរណកិច្ច** កិច្ចពិចារណាអារម្មណ៍តាមបញ្ចទ្វារ ចិត្តនេះកើតខាងមុខសម្បដិច្ឆន្នកិច្ច។

**២-តទាលម្ពណកិច្ច** ធ្វើកិច្ចតោងយកអារម្មណ៍ ដែលជវនសោយហើយក្នុងទ្វារទាំង ៦។

**៣-ចុតិកិច្ច** ធ្វើកិច្ចឃ្លាតចាកភព( ស្លាប់)។

**៤-បដិសន្ធិកិច្ច** កិច្ច តភពជាតិកំណើត។

**៥-ភវង្គកិច្ច** កិច្ចរក្សាភពជាតិកំណើត។

*សន្តីរណៈ ទាក់ទងបានរូប ៧ គឺ វណ្ណរូប សទ្ទរូប គន្ធរូប រសរូប និង មហាភូតរូប ៣ ( បឋវីផោដ្ឋព្វៈ តេជោផោដ្ឋព្វៈ វាយោផោដ្ឋព្វៈ) ។

## ខ. អហេតុកកុសលវិបាកចិត្ត ៨ ដួង

### ១-ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណ កុសលវិបាកចិត្តំ

ចក្ខុវិញ្ញាណដែលជាកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខា-វេទនា ( ធ្វើទស្សនកិច្ច គឺកិច្ចឃើញរូបល្អ ដូចជាឃើញផ្កា រូបព្រះសម្មាសម្ពុទ្ធជាដើម ) ។

### ២-ឧបេក្ខាសហគតំ សោតវិញ្ញាណ កុសលវិបាកចិត្តំ

សោតវិញ្ញាណដែលជាកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខា-វេទនា (ធ្វើសវនកិច្ច ឮ សម្លេងល្អ ដូចជាសម្លេងព្រះធម៌ ជាដើម )។

### ៣-ឧបេក្ខាសហគតំ ឃានវិញ្ញាណ កុសលវិបាកចិត្តំ

ឃានវិញ្ញាណដែលជាកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខា-វេទនា ( ធ្វើឃាយនកិច្ច គឺ កិច្ចដឹងក្លិនល្អ ដូចជាក្លិនផ្កាក្រអូប ក្លិនទឹកអប់ ជាដើម ) ។

## ៤-ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណ កុសលវិបាកចិត្តំ

ជិវ្ហាវិញ្ញាណដែលជាកុសលវិបាក ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (ធ្វើសាយនកិច្ច គឺ កិច្ចដឹងរសល្អ ៗ ដូចជារសជាតិឆ្ងាញ់ រសជាតិផ្អែម ជាដើម )។

## ៥-សុខសហគតំ កាយវិញ្ញាណ កុសលវិបាកចិត្តំ

កាយវិញ្ញាណដែលជាកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសុខ-វេទនា មានការដឹងផោដ្ឋព្វៈល្អ។

## ៦-ឧបេក្ខាសហគតំ មនោធាតុ កុសលវិបាកចិត្តំ

មនោធាតុដែលជាកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខា-វេទនា (ធ្វើសម្បដិច្ឆន្នកិច្ចគឺ កិច្ចទទួលដឹងអារម្មណ៍ពីបញ្ចវិញ្ញាណ ជាអារម្មណ៍ល្អ)។

## ៧-សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុក កុសលវិបាកចិត្តំ

មនោវិញ្ញាណធាតុដែលជា អហេតុកកុសលចិត្តប្រព្រឹត្តទៅជាមួយ សោមនស្សវេទនា ធ្វើកិច្ច ២ គឺ ធ្វើសន្តីរណកិច្ច តាមបញ្ចទ្វារ និង ធ្វើ តទាលម្ពណកិច្ច តាមទ្វារទាំង ៦។ មានអារម្មណ៍ជាអតិឥដ្ឋារម្មណ៍ ប៉ុណ្ណោះ។

## ឥដ្ឋារម្មណ៍ ចែកចេញជាពីរគឺ ៖

**-មជ្ឈត្តឥដ្ឋារម្មណ៍** អារម្មណ៍ល្អថ្នាក់កណ្តាល ។

**-អតិឥដ្ឋារម្មណ៍** អារម្មណ៍ល្អក្រៃលែង ដូចជារូបព្រះសម្មាសម្ពុទ្ធ សម្លេងព្រះធម៌ ជាដើម ។

ចំណែកអារម្មណ៍មិនល្អ មានឈ្មោះហៅតែមួយប៉ុណ្ណោះគឺ អនិដ្ឋារម្មណ៍ (អារម្មណ៍មិនល្អ) ។

## ៨-ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុកកុសលវិបាកចិត្តំ

មនោវិញ្ញាណធាតុ ដែលជាអហេតុកកុសលវិបាកចិត្តប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា (ធ្វើកិច្ច ៥ យ៉ាងគឺ **សន្តីរណកិច្ច តទាលម្ពណកិច្ច ចុតិកិច្ច បដិសន្ធិកិច្ច និង ភវង្គកិច្ច** )។

- មនោធាតុ កើតតាមបញ្ចទ្វារ តែម៉្យាង។
- អកុសលចិត្ត ១២ ជាតួកម្ម តែវាអាចឱ្យទៅជាអកុសលវិបាកចិត្ត ៧ ដួងប៉ុណ្ណោះ។

-អកុសលចិត្តកើតឡើង ក៏ព្រោះមានអហេតុកកើតមុន។

-កុសលចិត្តកើតឡើងក៏ព្រោះមានអហេតុកចិត្តកើតមុនដែរ។

-អហេតុកចិត្តមានចេតសិកតិចជាងគេបំផុត។

-អហេតុកចិត្ត គឺ បុណ្យ ឬ បាប ផលិតឡើង។

-មហាវិបាកចិត្ត ជាកុសលកម្មផលិតដែរ។

-មនោវិញ្ញាណធាតុកើតតាម មនោទ្វារ ឬ បញ្ចទ្វារ។

## គ. អហេតុកកិរិយាចិត្ត ៣ ដួង

### ១- ឧបេក្ខាសហគតំ មនោធាតុ កិរិយាចិត្តំ

មនោធាតុដែលជាកិរិយាចិត្ត ប្រព្រឹត្តទៅ ជាមួយឧបេក្ខាវេទនា (ធ្វើអាវជ្ជនកិច្ច តាមបញ្ចទ្វារ មុនបញ្ចវិញ្ញាណចិត្តនេះ គឺ បើកើតតាមចក្ខុទ្វារធ្វើចក្ខុទ្វារាវជ្ជនកិច្ច គឺ វាវរកអារម្មណ៍តាមទ្វារភ្នែក )។

យើងអាចហៅកិច្ចនៃចិត្តនេះដោយសរុបតាមទ្វារទាំង ៥ ថា បញ្ចទ្វារាវជ្ជនកិច្ច គឺកិច្ចនឹករាវរកអារម្មណ៍តាមទ្វារ ៥ ។ ចិត្តនេះជាវិថីបដិបាទកមនសិការៈ គឺ ជាបាតជាគ្រឿងទ្រនៃវិថីចិត្តក្នុងបញ្ចទ្វារ។ មនោ-ធាតុ ទាំងអស់កើតតាមបញ្ចទ្វារ។

### ២-ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ

មនោវិញ្ញាណធាតុ ដែលជាអហេតុកកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា។

*ចិត្តនេះគឺជា ជវនបដិបាទកមនសិការៈ ជាបាត ជាគ្រឿងទ្រឱ្យជវនចិត្តកើតឡើង។

### ៣-សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ

មនោវិញ្ញាណធាតុ ដែលជាអហេតុកកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ជាចិត្តរបស់ព្រះអរហន្តប៉ុណ្ណោះ មិនទូទៅដល់បុថុជ្ជន ឬ សេក្ខបុគ្គលទេ ។ ចិត្តនេះធ្វើជវនកិច្ចតាមទ្វារទាំង ៦ ឬក៏យើងអាចហៅចិត្តនេះដោយខ្លី ៗ ថា **ហសិតុប្បាទចិត្ត**។

# គាថាសង្គហអហេតុកចិត្ត

**«សត្តាកុសលបាកានិ បុញ្ញបាកានិ អដ្ឋធា**

**កិរិយាចិត្តានិ តីណីតិ អដ្ឋារស អហេតុកា»**

អហេតុកចិត្តមាន ១៨ ដួង គឺ អកុសលវិបាកចិត្ត ៧ ដួង អហេតុកកុសលវិបាកចិត្ត ៨ ដួង អហេតុកកិរិយាចិត្ត ៣ ដួង។

**«បាបាហេតុកមុត្តានិ សោភណានីតិ វុច្ចរេ**

**ឯកូនសដ្ឋី ចិត្តានិ អថេកនវុតីបិ វា»**

ចិត្ត ៥៩ ដួង ឬ ៩១ ដួង ដែលផុតចាកអំពីអកុសលចិត្ត និងអហេតុក-ចិត្ត បណ្ឌិតហៅថា **សោភណចិត្ត**។

## សង្គហៈន័យនៃអហេតុកចិត្ត ១៨ មាន ៤ ន័យគឺ ៖

**ន័យទី១** ហសិតុប្បាទចិត្ត (អហេតុកកិរិយាដួងទី ៣) ១ ដួង មានចេតសិកកើតរួមជាមួយ ១២ ប្រភេទ គឺអញ្ញសមានាចេតសិក ១២ ( វៀរឆន្ទៈ )

**ន័យទី២** មនោទ្វារាវជ្ជនចិត្ត (អហេតុកកិរិយាចិត្តដួងទី ២) ១ដួង មានចេតសិកកើតរួម ១១ ប្រភេទគឺ អញ្ញសមានាចេតសិក ១១ (វៀរបីតិ ឆន្ទៈ) សោមនស្សសន្តីរណចិត្ត ១ ដួង មានចេតសិកកើតរួម ១១ ប្រភេទ គឺ អញ្ញសមានាចេតសិក ១១ (វៀរ វីរិយ ឆន្ទៈ )។

**ន័យទី ៣** បញ្ចទ្វារាវជ្ជនចិត្ត (អហេតុកកិរិយាចិត្តដួងទី ១ ) ១ដួង សម្បដិច្ឆន្នចិត្ត (វិបាកមនោធាតុ) ២ ដួង ឧបេក្ខាសន្តីរណចិត្ត ២ ដួង (គឺ អកុសលវិបាកចិត្តដួងទី ៧ និង អហេតុកកុសលវិបាកចិត្ត ដួងទី ៨ ) ដួង

នីមួយៗមានចេតសិកកើតរួមជាមួយ ១០ប្រភេទ គឺ អញ្ញសមានាចេតសិក ១០ ( វៀរ បីតិ វិរិយៈ ឆន្ទៈ )។

**ន័យទី ៤** ទ្វិបញ្ចវិញ្ញាណចិត្ត ១០ (គឺចក្ខុវិញ្ញាណចិត្ត ២ សោតវិញ្ញាណចិត្ត ២ ឃានវិញ្ញាណចិត្ត ២ ជិវ្ហាវិញ្ញាណចិត្ត ២ និង កាយវិញ្ញាណចិត្ត ២) មានចេតសិកកើតរួម ៧ហៅថា **សព្វចិត្តសាធារណ-ចេតសិក** ក្នុងដួងនីមួយៗ។

## <u>ការចែកអសោភណចិត្តដោយន័យផ្សេង ៗ</u>

**១-ដោយជាតិ** មានជាតិ ៣ គឺ

- **អកុសលចិត្ត ១២** ជាអកុសលជាតិ
- **អហេតុកវិបាកចិត្ត ១៥** ជាវិបាកជាតិ
- **អហេតុកកិរិយាចិត្ត ៣** ជាកិរិយាជាតិ

**២-ដោយភូមិ** ជាកាមាវចរភូមិ

**៣-ដោយសោភណ** ជាអសោភណចិត្តទាំងអស់ ពីព្រោះមិនមានសោភណចេតសិកណាមួយ ដូចជា សទ្ធា សតិ ហិរិ ជាដើម កើតរួមជាមួយឡើយ។

**៤-ដោយខន្ធ** ជាវិញ្ញាណខន្ធ។

**៥- ដោយលោកិយ** ជាលោកិយចិត្ត ព្រោះជាប់ក្នុងលោក។

**៦-ដោយអាយតនៈ** ជាមនាយតនៈ។

**៧-ដោយធាតុ** ជាវិញ្ញាណធាតុ ៧។

## វិញ្ញាណធាតុ ៧ គឺៈ

*ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ជាវិញ្ញាណធាតុ ៥ គឺ ចក្ខុវិញ្ញាណចិត្ត ២ (ជាចក្ខុ-វិញ្ញាណធាតុ ១) សោតវិញ្ញាណចិត្ត ២ (ជាសោតវិញ្ញាណធាតុ ១) ឃាន-វិញ្ញាណចិត្ត ២ (ជាឃានវិញ្ញាណធាតុ ១) ជិវ្ហាវិញ្ញាណចិត្ត ២ (ជាជិវ្ហា-វិញ្ញាណធាតុ ១) កាយវិញ្ញាណចិត្ត ២ (ជាកាយវិញ្ញាណធាតុ ១)។

* កិរិយាមនោធាតុ ១ វិបាកមនោធាតុ ២ ជាមនោធាតុ ៣(ជាវិញ្ញាណធាតុ-១) តាមបញ្ចទ្វារ។

* នៅសល់ ១៧ ដួងទៀត ជាមនោវិញ្ញាណ ១។

**៨-ដោយសច្ចៈ** ជាទុក្ខសច្ចៈ។

**៩- ដោយឥន្ទ្រិយ** ជាមនិន្ទ្រិយ។

**១០-ដោយវេទនា** មានវេទនា ៥។

- ចិត្ត ១ ដួងប្រកបដោយទុក្ខវេទនា (កាយវិ.អកុ)
- ចិត្ត ១ ដួងប្រកបដោយសុខវេទនា (កាយវិ.កុ)
- ចិត្ត ៦ ដួងប្រកបដោយសោមនស្សវេទនា
- ចិត្ត ២ ដួងប្រកបដោយទោមនស្សវេទនា
- ចិត្ត ២០ ដួងប្រកបដោយឧបេក្ខាវេទនា

**១១-ដោយហេតុ** ចិត្តទាំង ៣០ ដួងនេះសុទ្ធតែជា នហេតុ (មិនមែនតួហេតុ ) ទាំងអស់។

* **អហេតុកចិត្ត ១៨ ដួង** ជាចិត្តដែលមិនមានហេតុ ក្នុងបណ្ដាហេតុទាំង ៦ កើតរួមជាមួយឡើយ ទើបឈ្មោះថា **អហេតុកចិត្ត** ចំណែកអកុសលចិត្ត ១២ ជាចិត្តដែលមានហេតុកើតរួមជាមួយទើបឈ្មោះថា **សហេតុកចិត្ត** ។

- **លោភមូលចិត្ត ៨ ដួង** ក្នុងដួងនីមួយៗ មានហេតុកើតរួមជាមួយ ២ គឺ លោភចេតសិក ១ និង មោហចេតសិក ១ ។
- **ទោសមូលចិត្ត ២ ដួង** ក្នុងដួងនីមួយៗ មានចេតសិកកើតរួមជាមួយ ២គឺ ទោសចេតសិក ១ មោហចេតសិក ១ ។ ចិត្តទាំង១០នេះដែលមានហេតុកើតរួមជាមួយ ២ ហៅថា **ទុហេតុកចិត្ត**។
- **មោហមូលចិត្ត ២ ដួង** ក្នុងដួងនីមួយៗមានហេតុកើតរួមជាមួយ ត្រឹមតែ ១ ប៉ុណ្ណោះ គឺ មោហចេតសិក ។ ចិត្តដែលមានហេតុកើតរួមតែ ១ ដូច្នេះហៅថា **ឯកហេតុកចិត្ត** ។

**១២-ដោយកិច្ច** កិច្ចរបស់ចិត្តទាំងអស់មាន ១៤។

**១. បដិសន្ធិកិច្ច** កិច្ចតភពជាតិកំណើត ( គឺ ភពថ្មីតពីភពចាស់ )។

**២. ភវង្គកិច្ច** កិច្ចរក្សាភពជាតិកំណើត ( ភវង្គកិច្ច នៃចិត្តមានប្រភេទដូចចិត្តដែលធ្វើបដិសន្ធិកិច្ច គឺថានៅក្នុងភពថ្មីនៃបុគ្គលម្នាក់ ៗ បើបុគ្គលនោះបដិសន្ធិដោយចិត្តប្រភេទណា ចិត្តដែលធ្វើកិច្ចរក្សាភពជាតិកំណើតរបស់បុគ្គលនោះ ក៏មានប្រភេទដូចគ្នានៃបដិសន្ធិចិត្តរបស់បុគ្គលនោះឯង គឺមានអំណាចរក្សាជាតិកំណើតដែលកើតហើយនោះ រហូតអស់ជីវិតក្នុងអត្តភាពមួយ ។

**៣. អាវជ្ជនកិច្ច** កិច្ចនឹករាវរកអារម្មណ៍តាមទ្វារទាំង ៦ (អាវជ្ជនកិច្ចចែកជាពីរយ៉ាងគឺ បញ្ចទ្វារាវជ្ជនកិច្ច ១ មនោទ្វារាវជ្ជនកិច្ច ១)។

**៤. ទស្សនកិច្ច** កិច្ចឃើញរូប

**៥. សវនកិច្ច** កិច្ច ឮសម្លេង

**៦. ឃាយនកិច្ច** កិច្ចដឹងក្លិន

**៧. សាយនកិច្ច** កិច្ចដឹងរស
**៨. ផុស្សនកិច្ច** កិច្ចដឹងផោដ្ឋព្វៈ
**៩. សម្បដិច្ឆន្នកិច្ច** កិច្ចទទួលអារម្មណ៍តាមបញ្ចទ្វារ
**១០. សន្តីរណកិច្ច** កិច្ចពិចារណាអារម្មណ៍តាមបញ្ចទ្វារ
**១១. វោដ្ឋព្វនកិច្ច** កិច្ចកាត់ក្តីអារម្មណ៍តាមបញ្ចទ្វារ
**១២. ជវនកិច្ច** កិច្ចសោយអារម្មណ៍តាមទ្វារទាំង ៦
**១៣. តទាលម្ពណកិច្ច** កិច្ចតោងយកនូវអារម្មណ៍ដែលជវនសោយហើយ។
**១៤. ចុតិកិច្ច** កិច្ចឃ្លាតចាកភព ឬ កិច្ចដាច់ភព ( សំដៅដល់ភវង្គចិត្តចុងក្រោយបង្អស់ក្នុងអត្តភាពនីមួយៗ )។

*បដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ច កិច្ចទាំង៣ នេះ ជាកិច្ចក្រៅទ្វារទាំង ៦។

**អសោភណចិត្ត ៣០ ដួងនេះធ្វើកិច្ចផ្សេង ៗ គ្នាយ៉ាងនេះ ៖**

១. អកុសលចិត្ត ១២ និង ហសិតុប្បាទចិត្ត ១, ១៣ ដួង នេះធ្វើជវនកិច្ចតាមទ្វារទាំង ៦។
២. ចក្ខុវិញ្ញាណចិត្ត ២ ដួង ធ្វើ **ទស្សនកិច្ច**
៣. សោតវិញ្ញាណចិត្ត ២ ដួង ធ្វើ **សវនកិច្ច**
៤. ឃានវិញ្ញាណចិត្ត ២ ដួង ធ្វើ **ឃាយនកិច្ច**
៥. ជិវ្ហាវិញ្ញាណចិត្ត ២ ដួង ធ្វើ **សាយនកិច្ច**
៦. កាយវិញ្ញាណចិត្ត ២ ដួង ធ្វើ **ផុស្សនកិច្ច**
៧. វិបាកមនោធាតុ ២ ដួង ធ្វើ **សម្បដិច្ឆន្នកិច្ច**
៨. អហេតុកអកុសលវិបាកដួងទី ៧ ធ្វើកិច្ច ៥ យ៉ាងគឺ ៖

**បដិសន្ធិកិច្ច , ភវង្គកិច្ច , ចុតិកិច្ច , (ក្នុងអបាយភូមិ)** និង **សន្តីរណកិច្ច , តទាលម្ពណកិច្ច។**

៩. អហេតុកកុសលវិបាកដួង ទី ៧ ប្រកបដោយសោមនស្សវេទនា ធ្វើកិច្ច ២ គឺ **សន្តីរណកិច្ច** និង **តទាលម្ពណកិច្ច។**

១០. អហេតុកកុសលវិបាកដួងទី ៨ ធ្វើកិច្ច ៥ យ៉ាង គឺ

**បដិសន្ធិ , ភវង្គ, ចុតិ** (ក្នុងមនុស្សនិងទេវតាថ្នាក់ទាប មានសភាពជាអ្នកខ្វះបុណ្យ ដូចជា មនុស្សគ ថ្លង់ ឆ្កួត ជាដើមតាំងពីកំណើត ) **សន្តីរណកិច្ច** និង **តទាលម្ពណកិច្ច។**

១១. កិរិយាមនោធាតុ ធ្វើអាវជ្ជនកិច្ចតាមបញ្ចទ្វារ ឬ ហៅថា បញ្ចទ្វារាវជ្ជនកិច្ច។

១២. អហេតុកកិរិយាមនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខាវេទនា ធ្វើកិច្ច ២ គឺ ៖

- វោដ្ឋព្វនកិច្ច តាមបញ្ចទ្វារ។
- មនោទ្វារាវជ្ជនកិច្ច តាមមនោទ្វារ។

## III. សោភណចិត្ត ៥៩ ឬ ៩១ ដួង

### ➢ សោភណចិត្ត ៤ ប្រភេទ ៖

ក្នុងបណ្តាសោភណចិត្តទាំងអស់ចែកចេញជា ៤ ប្រភេទ ៖

**១. កាមាវចរសោភណចិត្ត ២៤ ដួង**

**២. រូបាវចរសោភណចិត្ត ១៥ ដួង**

**៣. អរូបាវចរសោភណចិត្ត ១២ ដួង**

**៤. លោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួង**

## ១.កាមាវចរសោភណចិត្ត ២៤ ដួង

**ក. កាមាវចរកុសលចិត្ត ៨ ដួង** (ឬមហាកុសលចិត្ត)

**ខ. កាមាវចរវិបាកចិត្ត ៨ ដួង** (ឬមហាវិបាកចិត្ត )

**គ. កាមាវចរកិរិយាចិត្ត ៨ ដួង** (ឬមហាកិរិយាចិត្ត )

➢ **សោភណចេតសិក ២៥**

**១. សទ្ធា** ជឿកម្មផល

**២. សតិ** សេចក្ដីរលឹកដឹង

**៣. ហិរិ** ខ្មាសបាប ខ្ពើមបាប

**៤. ឱត្តប្ប** ខ្លាចបាប

**៥. អលោភោ** មិនជាប់ជំពាក់

**៦. អទោសោ** មិនប្រទូស្ត

**៧. តត្រមជ្ឈត្តតា** សម្លឹងជាកណ្ដាល

**៨. កាយបស្សទ្ធិ** ស្ងប់កាយ

**៩. ចិត្តបស្សទ្ធិ** ស្ងប់ចិត្ត

**១០. កាយលហុតា** ស្រាលកាយ }

**១១. ចិត្តលហុតា** ស្រាលចិត្ត } បដិបក្ខ និងថីនំ , មិទ្ធំ

**១២. កាយមុទុតា** ទន់ភ្លន់កាយ }

**១៣. ចិត្តមុទុតា** ទន់ភ្លន់ចិត្ត } បដិបក្ខ និងទិដ្ឋិ , មានៈ

**១៤. កាយកម្មញ្ញតា** កាយគួរដល់ការងារ

**១៥. ចិត្តកម្មញ្ញតា** ចិត្តគួរដល់ការងារ

**១៦. កាយបាគុញ្ញតា** មានការស្ទាត់ជំនាញនៃកាយ

**១៧. ចិត្តបាគុញ្ញតា** មានការស្ទាត់ជំនាញនៃចិត្ត

**១៨. កាយុជុកតា** មានការត្រង់កាយ

**១៩. ចិត្តុជុកតា** មានការត្រង់ចិត្ត

* ទាំង ១៩ នេះហៅថា **សោភណសាធារណចេតសិក**

**២០. សម្មាវាចា** សម្តីប្រពៃ

**២១. សម្មាកម្មន្តោ** ការងារប្រពៃ

**២២. សម្មាអាជីវោ** អាជីវប្រពៃ កិរិយាចិញ្ចឹមជីវិតត្រូវ

* **ទាំង ៣ នេះ ហៅថា វិរតិចេតសិក**

**២៣. ករុណា** អាណិត
**២៤. មុទិតា** ទន់ភ្លន់
} ហៅថា អប្បមញ្ញាចេតសិក

**២៥. បញ្ញិន្ទ្រិយំ** ភារៈជាធំក្នុងការចេះដឹងបានដល់ បញ្ញាចេតសិក ។

## ក.មហាកុសលចិត្ត ៨ ដួង

## ១. សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៨ ប្រភេទគឺ ៖**

- អញ្ញសមានាចេតសិក ១៣

- សោភណចេតសិក ២៥

**២. សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ**

មហាកុសលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនាប្រកបដោយបញ្ញា មានកម្លាំងខ្សោយកើតឡើងដោយមានអ្នកដឹកនាំ។

*** មានចេតសិកប្រកបជាមួយ ៣៨ ប្រភេទ ដូចដួងទី ១ ដែរ ។**

**៣. សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ**

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយ សោមនស្សវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៧ គឺៈ**

- អញ្ញសមានាចេតសិក ១៣

- សោភណចេតសិក ២៤ (វៀរបញ្ញា)

**៤. សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ**

មហាកុសលចិត្តប្រព្រឹត្តទៅជាមួយ សោមនស្សវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកបបួលដឹកនាំ។

***មានចេតសិកកើតរួមជាមួយ ៣៧ ដូចដួងទី ៣ ។**

**៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ**

មហាកុសលចិត្តប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកបបួលដឹកនាំ ។

**មានចេតសិកកើតរួមជាមួយ ៣៧ ប្រភេទគឺ ៖**

- **អញ្ញសមានាចេតសិក ១២** (វៀរបីតិ)
- **សោភណចេតសិក ២៥**

**៦. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ**

មហាកុសលចិត្តប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកបបួលដឹកនាំ ។

***មានចេតសិកកើតរួមជាមួយ ៣៧ ដូចដួងទី ៥។**

**៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ**

មហាកុសលចិត្តប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៦ ប្រភេទគឺ៖**

- **អញ្ញសមានាចេតសិក ១២** (វៀរបីតិ)

- សោភណចេតសិក ២៤ (វៀរបញ្ញា)។

**៨. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ**

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានអ្នកបបួលដឹកនាំ។

***មានចេតសិកកើតរួម ៣៦ ប្រភេទដូចដួងទី ៧ ដែរ។**

## អត្ថរបស់កុសល ៥ យ៉ាង

**១. អរោគ្យត្ថ** ដោយអត្ថថាមិនមានរោគ ( **រាគៈ ទោសៈ មោហៈ ទិដ្ឋិ មានៈ ឥស្សា មច្ឆរិយៈ**) ជាដើម ឈ្មោះថា រោគ ព្រោះជាគ្រឿងចាក់ដោត ញាំញីនូវសន្តានចិត្តឱ្យញាប់ញ័រក្តៅក្រហាយ។

**២. សុន្ទរត្ថ** ដោយអត្ថថា ស្អាតបរិសុទ្ធល្អ។

**៣. ឆេកត្ថ** ដោយអត្ថថា ឆ្លាតវៃ ឬ មុតស្រួច ក្នុងការកំចាត់បង់នូវភាពសៅហ្មងរបស់ចិត្ត។

**៤. អនវជ្ជត្ថ** ដោយអត្ថថា មិនមានទោស។

**៥. សុខវិបាកត្ថ** ដោយអត្ថថា មានវិបាកជាសុខ។

## លក្ខណាទិចតុក្ករបស់កុសល

**១. អនវជ្ជ សុខវិបាក លក្ខណំ** មានវិបាកជាសុខដែលមិនមានទោសជាលក្ខណៈ។

**២. អកុសលវិទ្ធំសន រសំ** មានការកម្ចាត់បង់នូវអកុសល ជាកិច្ច។

**៣. វោទាន បច្ចុប្បដ្ឋានំ** មានសភាពស្អាតផូរផង់ ជាអាការៈប្រាកដ។

**៤. យោនិសោមនសិការ បទដ្ឋានំ** មានការធ្វើទុកក្នុងចិត្តតាមទំនង ហេតុផលជាហេតុជិត។

## <u>លក្ខណាទិចតុករបស់កុសលន័យម៉្យាងទៀត</u>

**១. អនវជ្ជ លក្ខណំ** មានការមិនមានទោសជាលក្ខណៈ។

**២. វោទាន ភាវ រសំ** មានសភាពស្អាតផូរផង់នៃចិត្តជាកិច្ច។

**៣. ឥដ្ឋវិបាក បច្ចុប្បដ្ឋានំ** មានវិបាកដែលជាទីប្រាថ្នា ជាផល ឬ ជាអាការៈប្រាកដ។

**៤. យោនិសោមនសិការ បទដ្ឋានំ** មានការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ជាហេតុជិត។

## ហេតុនាំឱ្យកើតបញ្ញា ៣ យ៉ាង

**១. សុតមយបញ្ញា** បញ្ញាសម្រេចដោយការស្តាប់ព្រះសទ្ធម្ម។

**២. ចិន្តាមយបញ្ញា** បញ្ញាកើតអំពីការគិតពិចារណា។

**៣. ភាវនាមយបញ្ញា** បញ្ញាកើតឡើងដោយការអប់រំចម្រើនវិបស្សនា។

## អានិសង្សនៃការស្តាប់ធម៌មាន ៥ យ៉ាងៈ

**១. អស្សុតំ សុណាតិ** រមែងបានស្តាប់នូវធម៌ដែលមិនធ្លាប់បានស្តាប់។

**២. សុតំ បរិយោទបេតិ** ធម៌ណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ជាក់ច្បាស់ ក៏ជាក់ច្បាស់ឡើង។

**៣. កង្ខំ វិហនតិ** អាចកាត់បង់នូវសេចក្តីសង្ស័យបាន។

**៤. ទិដ្ឋី ឧជុំ ករោតិ** អាចធ្វើទិដ្ឋិឱ្យត្រង់បាន។

**៥. ចិត្តមស្ស បសីទតិ** ចិត្តរបស់អ្នកស្តាប់នោះរមែងជ្រះថ្លា។

## ហេតុនាំឱ្យកើតបញ្ញា ៤ យ៉ាងផ្សេងទៀត ៖

**១. បញ្ញាសំវត្តនិក កម្មប្បនិស្សយតា** ភាពជាអ្នកមានឧបនិស្ស័យ ក្នុងការបំពេញកុសលប្រព្រឹត្តទៅព្រម ជាមួយបញ្ញា (ដូចជាការធ្វើទានរក្សាសីល-និង បង្រៀនសិល្បៈ វិជ្ជាផ្សេងៗ ដែលប្រាសចាកទោសជាដើម )។

**២. អព្យាបជ្ឈលោកូប្បត្តិតា** ភាពជាអ្នកកើតក្នុងលោកមិនមាន ការបៀតបៀន។

**៣. ឥន្ទ្រិយបរិបាកតា** មានឥន្ទ្រិយចាស់ក្លា(ឥន្ទ្រិយ ៥ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និង បញ្ញិន្ទ្រិយ )។

**៤. កិលេសទូរតា** ភាពជាអ្នកឆ្ងាយចាកកិលេស។

## ការសម្តែងមហាកុសលដោយពិស្តារ ៖

នៅក្នុងអភិធម្មត្ថសង្គហៈបាលីដីកា បានអធិប្បាយពន្យល់ថា «**កមេន បុញ្ញវត្ថូហិ គោចរាធិបតីហិ កម្មហីនាទិតោ ចេវ គណេយ្យ នយកោវិទោតិ** »

ប្រែថា **បុញ្ញវត្ថូហិ** អ្នកឈ្លាសក្នុងន័យ គប្បីរាប់កុសលចិត្តទាំងឡាយដោយបុញ្ញកិរិយាវត្ថុ ១០។

**គោចរាធិបតីហិ** ប្រែថា ដោយគោចរ( គឺអារម្មណ៍ ៦) ដោយអធិបតី ៤ ដោយកម្ម ៣ ដោយចិត្តដែលថោកទាប ជាដើមមាន ៣ តាមលំដាប់។

*គប្បីរាប់មហាកុសលចិត្តដោយពិស្តារដូច្នេះគឺ៖

១. មហាកុសលចិត្ត ៨ ដួង x បុញ្ញកិរិយាវត្ថុ ១០ = ៨០ ដួង។

២. មហាកុសលចិត្ត ៨០ ដួង x អារម្មណ៍ ៦ = ៤៨០ ដួង។

៣. មហាកុសលចិត្ត ៤៨០ ដួងចែកជា ២ គឺ

-ជាញាណសម្បយុត្តចិត្ត ២៤០ ដួង។

-ជាញាណវិប្បយុត្តចិត្ត ២៤០ ដួង។

-មហាកុសលញាណវិប្បយុត្ត ២៤០ x អធិបតី ៣ (វៀរវិមំសា) = ៧២០ ដួង។

- មហាកុសលញាណសម្បយុត្ត ២៤០ ដួង x អធិបតី ៤ = ៩៦០ ដួង

ដូច្នេះ ៧២០+៩៦០ = ១.៦៨០ ដួង។

៤. មហាកុសលចិត្ត ១.៦៨០ ដួង x កម្ម ៣ មានកាយកម្មជាដើម = ៥.០៤០ ដួង។

៥. មហាកុសលចិត្ត ៥.០៤០ដួង x ចិត្ត ៣ ប្រភេទ គឺថោកទាប កណ្តាល ប្រណិត = ១៥.១២០ ដួង។

- មហាកុសលចិត្តទាំង ១៥.១២០ ដួងនេះបើរាប់ឱ្យល្អិតល្អន់ ត្រូវនឹងកាលទេសៈ (ទីកន្លែង ឬ ប្រទេស ) បន្ថែមទៀតនឹងមានចំនួនកាន់តែច្រើនមិនងាយនឹងគណនាបាន។

## <u>បុញ្ញកិរិយាវត្ថុ ១០</u>

**១. ទានមយ** បុណ្យសម្រេចដោយការឱ្យទាន។

**២. សីលមយ** បុណ្យសម្រេចដោយការរក្សាសីល។

**៣. ភាវនាមយ** បុណ្យសម្រេចដោយការចម្រើនឱ្យចិត្តស្ងប់ (ជាឧបចារៈសមាធិ)។

**៤. អបចាយនមយ** បុណ្យសម្រេចដោយការគោរពឱនលំទោន។

**៥. វេយ្យាវច្ចមយ** បុណ្យសម្រេចដោយការជួយខ្នះខ្នែង ។

**៦. បត្តិទានមយ** បុណ្យសម្រេចដោយការចែកចំណែកបុណ្យឱ្យដល់អ្នកដទៃ។

**៧. បត្តានុមោទនាមយ** បុណ្យសម្រេចដោយការអនុមោទនាត្រេកអរនឹងបុណ្យអ្នកដទៃ កុសលរបស់អ្នកដទៃ។

**៨. ធម្មទេសនាមយ** បុណ្យសម្រេចដោយការសម្តែងធម៌។

**៩. ធម្មសវនមយ** បុណ្យសម្រេចដោយការស្តាប់ព្រះធម៌។

**១០.ទិដ្ឋុជុកម្មមយ** បុណ្យសម្រេចដោយការយល់ត្រង់ត្រឹមត្រូវ តាមហេតុផល។

- បុញ្ញកិរិយាវត្ថុចាប់តាំងពីទី ១ ដល់ទី ៩ សម្រេចដោយមហាកុសល ៨ ដួង ណានីមួយគ្រប់កាលទាំង ៣។

- ចំពោះទិដ្ឋុជុកម្ម អាចប្រព្រឹត្តទៅក្នុងមហាកុសល ៨ ដួង ណានីមួយតែមុនកាលនឹងធ្វើ និង កាលនឹងធ្វើជាខាងក្រោយ ប៉ុន្តែខណៈដែលកំពុងយល់ត្រូវអាចសម្រេចដោយមហាកុសលញាណសម្បយុត្ត ៤ ដួង ប៉ុណ្ណោះ។

## «សង្ខេបបុញ្ញកិរិយាវត្ថុ ១០ »

### បុញ្ញកិរិយាវត្ថុទាំង ១០ នេះបើបំព្រួញមកសល់ត្រឹមតែ ៣ ប៉ុណ្ណោះគឺ៖

-**ទានមយ បត្តិទានមយ** និង **បត្តានុមោទនាមយ** ទាំង៣ នេះ សង្គ្រោះចូលក្នុងទាន។

-**សីលមយ អបចាយនមយ** និង **វេយ្យាវច្ចមយ** ទាំង ៣ នេះសង្គ្រោះចូលក្នុងសីល។

-**ភាវនាមយ ធម្មទេសនាមយ** និង **ធម្មសវនមយ** ទាំង ៣ នេះសង្គ្រោះចូលក្នុងភាវនា។

- ចំពោះ **ទិដ្ឋុជុកម្ម** សង្គ្រោះចូលក្នុងបុញ្ញកិរិយាវត្ថុទាំង ៣ គឺក្នុងទាន ក៏បានក្នុងសីលក៏បាន ក្នុងភាវនាក៏បាន ។

* បុញ្ញកិរិយាវត្ថុទាំងអស់ (ក្រៅពីទិដ្ឋុជុកម្ម) បើមិនមានទិដ្ឋុជុកម្មទេ ក៏រមែងមិនសម្បូរឡើយ ។

## <u>មហាកុសល ៨០ មានអារម្មណ៍ ៦</u>

### អារម្មណ៍ ៦ នោះគឺ ៖

| | |
|---|---|
| **១.រូបារម្មណ៍** | អារម្មណ៍គឺរូប(ពណ៌) x ៨០ |
| **២. សទ្ទារម្មណ៍** | អារម្មណ៍គឺ សម្លេង x ៨០ |
| **៣. គន្ធារម្មណ៍** | អារម្មណ៍គឺ ក្លិន x ៨០ |
| **៤. រសារម្មណ៍** | អារម្មណ៍គឺ រស x ៨០ |
| **៥. ផោដ្ឋព្វារម្មណ៍** | អារម្មណ៍ គឺផោដ្ឋព្វៈ x ៨០ |

៦. ធម្មារម្មណ៍ អារម្មណ៍គឺ ធម៌ x ៨០

* ក្នុងអារម្មណ៍នីមួយ ៗ មានមហាកុសល ៨០

## សម័យនៃមហាកុសល ៥ យ៉ាង

១. ដោយការព្រមព្រៀង (នៃបច្ច័យច្រើន)

២. ដោយខណៈ (បានដល់ចក្កៈធម៌ ៤)

៣. ដោយកាល

៤. ដោយការប្រជុំ

៥. ដោយហេតុ

## ចក្កៈធម៌ ៤

១. បដិរូបទេសវាសោ កិរិយារស់នៅក្នុងប្រទេសដ៏សមគួរ (ជាពិសេសគឺកន្លែងដែលមានព្រះពុទ្ធសាសនា )។

២. សប្បុរិសូបនិស្សយោ បានចូលទៅអាស្រ័យជាមួយសប្បុរស។

៣. អត្តសម្មាបណិធិ តម្កល់ខ្លួនដោយប្រពៃ ( បានដល់ភាពជាបុគ្គលដែលសប្បុរសប្រដៅបានងាយ )។

៤. បុព្វេកតបុញ្ញតា ភាពជាបុគ្គលធ្វើបុណ្យទុកហើយក្នុងកាលមុន។

## វត្ថុជាទីសប្បាយនៃមហាកុសល

១.អាវាសជាទីសប្បាយ ដូចជាផ្ទះសម្បែងឬវត្តអារាមជាដើមដែលរៀបរយបានល្អ។

**២.ឥរិយាបថជាទីសប្បាយ** គឺការប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ស្មើល្អ។

**៣.បុគ្គលជាទីសប្បាយ** គឺបុគ្គលល្អទាំងរូបសម្បត្តិ គុណសម្បត្តិ និង បញ្ញាសម្បត្តិជាដើម។

**៤.គោចរជាទីសប្បាយ** គឺផ្លូវធ្វើដំណើររាបស្មើល្អមិនរលាក់ មិនហុយជាដើម។

**៥.កថាវត្ថុជាទីសប្បាយ** គឺការពោលវាចាជាកុសល មានទានកថា សីលកថា ជាដើម។

**៦.ឧតុជាទីសប្បាយ** គឺ អាកាសធាតុមិនក្តៅពេក មិនត្រជាក់ពេក។

**៧.ភោជនជាទីសប្បាយ** គឺអាហារមានរសជាតិល្អ និង មានអនាម័យជាដើម។

## <u>ការចែកមហាកុសលចិត្តដោយឧក្កដ្ឋៈ និង ឱមកៈ</u>
## <u>ដោយញាណសម្បយុត្តមាន៤ន័យ</u>

**ន័យទី ១**

**តិហេតុកឧក្កដ្ឋុក្កដ្ឋៈ**
- **បុព្វចេតនា** (ល្អ)
- **មុញ្ចនចេតនា** (ល្អ)
- **អបរចេតនា** (ល្អ)
- **អបរាបរចេតនា** (ល្អ)

-ពាក្យថា **ឧក្កដ្ឋុក្កដ្ឋៈ**= **ឧក្កដ្ឋៈ**(ឧក្រិដ្ឋ) + **ឧក្កដ្ឋៈ**(ឧក្រិដ្ឋ)

(**ឧក្រិដ្ឋ** = ប្រណិតក្រៃលែង)។

-**ន័យទី ២**

**តិហេតុកឧក្កដ្ឋោមកៈ**
- **បុព្វចេតនា** (ល្អ)
- **មុញ្ចនចេតនា** (ល្អ)
- **អបរចេតនា** (ល្អ)
- **អបរាបរចេតនា** (មិនល្អ)

-ពាក្យថា **ឧក្កដ្ឋោមកៈ** = **ឧក្កដ្ឋោ** (ឧក្រិដ្ឋ) + **ឱមកៈ**(មិនល្អ ឬមិនសូវល្អ)។
(ពាក្យ **បុព្វចេតនា** គឺមុនពេលធ្វើ, **មុញ្ចនចេតនា** គឺពេលកំពុងធ្វើ)។

-**ន័យទី ៣**

**តិហេតុកឱមកុក្កដ្ឋៈ**
- **បុព្វចេតនា** (ល្អ)
- **មុញ្ចនចេតនា** (ល្អ)
- **អបរចេតនា** (មិនល្អ)
- **អបរាបរចេតនា** (ល្អ)

-**ន័យទី ៤**

**តិហេតុកឱមកោមកៈ**
- **បុព្វចេតនា** (ល្អ)
- **មុញ្ចនចេតនា** (ល្អ)
- **អបរចេតនា** (មិនល្អ)
- **អបរាបរចេតនា** (មិនល្អ)

# ដោយញាណវិប្បយុត្តមាន ៤ ន័យ

**-ន័យទី ១**

**ទុហេតុកឧក្កដ្ឋកុសល៖**

- **បុព្វចេតនា** (ល្អ)
- **មុញ្ចនចេតនា** (ល្អ)
- **អបរចេតនា** (ល្អ)
- **អបរាបរចេតនា** (ល្អ)

(ពាក្យ **អបរចេតនា** គឺក្រោយពេលធ្វើហើយភ្លាម ៗ **អបរាបរចេតនា** គឺក្រោយពេលធ្វើហើយយូរៗ)។

**-ន័យទី ២**

**ទុហេតុកឧក្កដ្ឋោមក៖**

- **បុព្វចេតនា** (ល្អ)
- **មុញ្ចនចេតនា** (ល្អ)
- **អបរចេតនា** (ល្អ)
- **អបរាបរចេតនា** (មិនល្អ)

**-ន័យទី ៣**

**ទុហេតុកឱមកកុសល៖**

- **បុព្វចេតនា** (ល្អ)
- **មុញ្ចនចេតនា** (ល្អ)
- **អបរចេតនា** (មិនល្អ)
- **អបរាបរចេតនា** (ល្អ)

**-ន័យទី ៤**

**ទុហេតុកឱមកោមកៈ**

- **បុញ្ញចេតនា** (ល្អ)
- **មុញ្ចនចេតនា** (ល្អ)
- **អបរចេតនា** (មិនល្អ)
- **អបរាបរចេតនា** (មិនល្អ)

## **<u>ការចែកមហាកុសលចិត្ត ៨ ដួងដោយន័យផ្សេង ៗ</u>**

| | |
|---|---|
| **១.ដោយជាតិ** | ជាកុសលជាតិ។ |
| **២.ដោយភូមិ** | ជាកាមាវចរភូមិ (កើតបាន ៣០ ភូមិ)។ |
| **៣.ដោយវេទនា** | ជាសោមនស្សវេទនា ៤ ដួង ជាឧបេក្ខាវេទនា ៤ ដួង។ |
| **៤.ដោយហេតុ** | ជានហេតុ និង ជាសហេតុកចិត្ត។ |
| **៥.ដោយសម្បយុត្ត** | ជាញាណសម្បយុត្ត ៤ ដួង ជាញាណវិប្បយុត្ត ៤ ដួង។ |
| **៦.ដោយសង្ខារ** | ជាអសង្ខារិក ៤ ដួង ជាសសង្ខារិក ៤ ដួង។ |
| **៧.ដោយសោភណៈ** | ជាកាមាវចរសោភណចិត្ត។ |
| **៨.ដោយឈាន** | ជាអឈានចិត្ត។ |
| **៩.ដោយលោកិយ** | ជាលោកិយចិត្ត។ |
| **១០.ដោយកិច្ច** | ធ្វើជវនកិច្ចតែម្យ៉ាង។ |
| **១១.ដោយអារម្មណ៍** | ដឹងអារម្មណ៍ទាំង៦។ |
| **១២.ដោយទ្វារ** | កើតតាមទ្វារទាំង៦។ |

**១៣.ដោយវត្ថុ** កើតត្រង់ហទយវត្ថុ។

**១៤.ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ។

## ខ.មហាវិបាកចិត្ត ៨ ដួង

**១.សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញាជាអសង្ខារិក។

**មានចេតសិកកើតជាមួយ ៣៣ ប្រភេទគឺ ៖**

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២០ (វៀរវិរតិ ៣ និង អប្បមញ្ញា២)

**២.សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញាជាសសង្ខារិក។

**មានចេតសិកកើតរួមជាមួយ ៣៣ ប្រភេទគឺ ៖**

-អញ្ញសមានាចេតសិក ១៣

-សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២)។

**៣.សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកបញ្ញាជាអសង្ខារិក។

**មានចេតសិកកើតរួមជាមួយ ៣២ ប្រភេទគឺ ៖**

**-អញ្ញសមានាចេតសិក ១៣**

**-សោភណចេតសិក ១៩** (វៀរវិរតិ ៣ អប្បមញ្ញា ២ បញ្ញា ១)។

**៤.សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកបញ្ញាជាសសង្ខារិក។

**មានចេតសិកកើតរួមជាមួយ ៣២ ប្រភេទគឺ ៖**

**-អញ្ញសមានាចេតសិក ១៣**

**-សោភណចេតសិក ១៩** (វៀរវិរតិ ៣ អប្បមញ្ញា ២ បញ្ញា ១)។

**៥.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញាជាអសង្ខារិក។

**មានចេតសិកកើតរួមជាមួយ ៣២ ប្រភេទគឺ ៖**

**-អញ្ញសមានាចេតសិក ១២** (វៀរបីតិ)

**-សោភណចេតសិក ២០** (វៀរវិរតិ ៣ អប្បមញ្ញា ២)។

**៦.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា ជាសសង្ខារិក។

**មានចេតសិកកើតរួមជាមួយ ៣២ ប្រភេទគឺ ៖**

**-អញ្ញសមានាចេតសិក ១២** (វៀរបីតិ)

**-សោភណចេតសិក ២០** (វៀរវិរតិ ៣ អប្បមញ្ញា ២)។

**៧.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា ជាអសង្ខារិក។

**មានចេតសិកកើតរួមជាមួយ ៣១ ប្រភេទគឺ ៖**

**-អញ្ញសមានាចេតសិក ១២** (វៀរបីតិ)

**-សោភណចេតសិក ១៩** ( វៀរវិរតិ ៣ អប្បមញ្ញា ២ បញ្ញា១ )។

**៨.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ**

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា ជាសសង្ខារិក។

**មានចេតសិកកើតរួមជាមួយ ៣១ ប្រភេទគឺ ៖**

-**អញ្ញសមានាចេតសិក ១២** (វៀរបីតិ)

-**សោភណចេតសិក ១៩** (វៀរវិរតិ ៣ អប្បមញ្ញា ២ បញ្ញា១)។

**មហាវិបាកចិត្តទាំង ៨ ដួងធ្វើកិច្ច ៤ យ៉ាងគឺ ៖**

**១.បដិសន្ធិកិច្ច** កិច្ចតភពជាតិកំណើត។

**២.ភវង្គកិច្ច** កិច្ចរក្សាភពជាតិកំណើត។

**៣.ចុតិកិច្ច** កិច្ចឃ្លាតចាកភព។

**៤.តទាលម្ពណកិច្ច** កិច្ចតោងយកនូវអារម្មណ៍ដែលជវនសោយហើយ។

## អានិសង្សរបស់តិហេតុកកុសល

-**ន័យទី១ (តិហេតុកឧក្កដ្ឋុក្កដ្ឋ:)** ឱ្យនូវវិបាក ១៦ ដួង គឺមហាវិបាកចិត្ត ៨ ដួង អហេតុកកុសលវិបាកចិត្ត ៨ ដួង ហើយមានអានិសង្សខ្ពស់បំផុតអាចឱ្យកើតក្នុងមនុស្ស និង ទេវតាដែលសម្បូរបុណ្យបរិបូរណ៍ដោយមនុស្សសម្បត្តិ សួគ៌សម្បត្តិ។ ម៉្យាងទៀត រមែងជាអ្នកមានបញ្ញា អាចសម្រេចមគ្គផលនិព្វាន និង ឈានសមាបត្តិបានក្នុងជាតិដែលខ្លួនកើតហើយនោះ តាមសមគួរដល់ឧបនិស្ស័យ ចាត់ជាបុគ្គលប្រណិតក្រៃលែងមានសេចក្ដីសុខតាំងពីក្មេង ដល់ចាស់។

-**ន័យទី២ (តិហេតុកឱក្កដ្ឋោមកៈ)** ការឱ្យនូវផលក៏ដូចនឹងន័យទី១ដែរ ប៉ុន្តែមិនល្អរហូតទេ តែងមិនល្អក្នុងពេលជាខាងក្រោយ។

-**ន័យទី៣ (តិហេតុឱមកុក្កដ្ឋ:)** នាំឱ្យវិបាកបដិសន្ធិជាទុហេតុកបុគ្គល និងនាំឱ្យមានវិបាកក្នុងបវត្តិកាល ១២ ដួងគឺ៖

មហាវិបាកញាណសម្បយុត្តចិត្ត ៤ ដួង និង អហេតុកកុសលវិបាកចិត្ត ៨ ដួង។ ក្នុងជីវិតរស់នៅមានសេចក្ដីសុខខ្លះ ៗ ជាអន្លើ ៗ ឡើងចុះៗ វ័យក្មេងមិនល្អ ពេញវ័យល្អ និង វ័យចាស់មិនល្អ ហើយប្រកបការងារអ្វីៗ មិនសូវឆ្លាតវៃ នឹងមិនអាចសម្រេចមគ្គផល ឬឈានសមាបត្តិបានឡើយ ព្រោះអាស្រ័យវិបាកបដិសន្ធិ ដែលមិនប្រកបដោយបញ្ញា។

-**ន័យទី៤ (តិហេតុកឱមកោមកៈ)** នាំឱ្យមានវិបាកដូចគ្នានឹងន័យទី ៣ដែរ គ្រាន់តែក្នុងបវត្តិកាលមិនសូវមានសេចក្ដីសុខជាប់តគ្នា គឺថាក្នុងវ័យក្មេង មិនល្អ ពេលពេញវ័យល្អ វ័យកណ្ដាលមិនល្អ វ័យចាស់មិនល្អ។

## <u>អានិសង្សរបស់ទុហេតុកកុសល</u>

-**ន័យទី១** (ទុហេតុកឧក្កដ្ឋុក្កដ្ឋៈ) នាំឱ្យមានវិបាកបដិសន្ធិ ជាមនុស្ស ឬទេវតាជាទុហេតុកបុគ្គល។

### ក្នុងបវត្តិកាល នាំឱ្យមានវិបាកចិត្ត ១២ ដួងគឺៈ

មហាវិបាកញាណវិប្បយុត្តចិត្ត ៤ ដួង និង អហេតុកកុសលវិបាកចិត្ត ៨ដួង។ ជីវិតរស់នៅក្នុងអត្តភាពនោះ ជាអ្នកបរិបូរណ៌ដោយសម្បត្តិ មាន សេចក្ដីសុខតាំងពីក្មេងដល់ចាស់ ប៉ុន្តែមិនអាចសម្រេចគុណធម៌ជាន់ខ្ពស់ ណាមួយបានឡើយ ព្រោះខ្វះឧបនិស្ស័យនៃបញ្ញា។

-**ន័យទី២ (ទុហេតុកឧក្កដ្ឋោមកៈ)** មានសេចក្ដីដូចន័យទី ១ ដែរ គ្រាន់តែ មានសេចក្ដីសុខមិនជាប់តគ្នារហូត គឺ ល្អពីក្មេង ដល់ពេលចាស់មិនល្អ។

-**ន័យទី៣ (ទុហេតុកឱមក្កុក្កដ្ឋៈ)** នាំឱ្យមានបដិសន្ធិជាមនុស្ស ឬទេវតា ជាន់ទាបៗ ដោយអហេតុកកុសលវិបាក (ដួងទី ៨)។ ក្នុងបវត្តិកាលមាន

ត្រឹមតែអហេតុកកុសលវិបាក ៨ ដួងប៉ុណ្ណោះ ហើយមានសេចក្តីសុខតិច ជាងន័យទី២ទៅទៀត មិនអាចសម្រេចគុណវិសេសណាមួយបានឡើយ។

-**ន័យទី៤ (ទុហេតុកឱមកោមកៈ)** មានការឱ្យផលដូចន័យទី ៣ ដែរ គ្រាន់តែសេចក្តីសុខកាន់តែអន់ទន់ទាបទៅ អាចថាជាបុគ្គលមានសតិមិន បរិបូរណ៌ ឆ្កួត ល្ងីល្ងើ គ ថ្លង់ ខ្វាក់ខ្វិន ពិការ តាំងពីកំណើត។

មហាវិបាកទាំង ៨ ដួងនេះ មិនមែនជាកុសល មិនមែនជា អកុសល មិនមែនជាកម្មបថ មិនមែនជាបុញ្ញកិរិយាវត្ថុ ព្រោះមិនអាចញ៉ាំង វិញ្ញត្តិរូបឱ្យកើតឡើងបាន និង មិនអាចនាំឱ្យមានវិបាកឡើយ។

## កុសលឱ្យផលផ្សេង ៗ គ្នា ៧ យ៉ាងគឺ ៖

**១.មានអាយុវែង** ព្រោះមិនសម្លាប់សត្វ។

**២.មិនមានរោគ** ព្រោះមិនបៀតបៀនសត្វ។

**៣.មានសម្បុរស្រស់ថ្លា** ព្រោះមិនមានសេចក្តីក្រោធ។

**៤.មានសក្តិធំ** ព្រោះមិនច្រណែនមិនប្រទូស្ត។

**៥.មានភោគសម្បត្តិច្រើន** ព្រោះឱ្យទាន មានបាយ ទឹក សំពត់ស្លៀក ដណ្តប់ ទីជម្រកជាដើម។

**៦.កើតក្នុងត្រកូលខ្ពង់ខ្ពស់** ព្រោះមិនរឹងត្អឹង មិនមើលងាយគេ មានតែការ គោរពរាប់អាន។

**៧.មានបញ្ញាច្រើន** ព្រោះចូលទៅរកសមណៈជាពហុស្សូត អ្នកស្ងប់រម្ងាប់ ស្តាប់និងសិក្សាធម៌។

## ការចែកមហាវិបាកចិត្ត ៨ ដួងដោយន័យផ្សេង ៗ

**១.ដោយជាតិ** ជាវិបាកជាតិ។
**២.ដោយភូមិ** ជាកាមាវចរភូមិ (កើតនៅសុគតិភូមិ ៧ ជាន់)។
**៣.ដោយវេទនា** ជាសោមនស្សវេទនា ៤ ដួង និង ជាឧបេក្ខាវេទនា ៤ ដួង។
**៤.ដោយហេតុ** ជានហេតុ និង ជាសហេតុកចិត្ត។
**៥.ដោយសម្បយុត្ត** ជាញាណសម្បយុត្ត ៤ ដួង ជាញាណវិប្បយុត្ត ៤ ដួង។
**៦.ដោយសង្ខារ** ជាអសង្ខារិក ៤ ដួង ជាសសង្ខារិក ៤ ដួង។
**៧.ដោយសោភណៈ** ជាកាមាវចរសោភណចិត្ត។
**៨.ដោយឈាន** ជាអឈានចិត្ត។
**៩.ដោយលោកិយ** ជាលោកិយចិត្ត។
**១០.ដោយកិច្ច** មហាវិបាកចិត្តធ្វើកិច្ច ៤ យ៉ាងគឺៈ **បដិសន្ធិ ភវង្គ ចុតិ** និង **តទាលម្ពណកិច្ច**។
**១១.ដោយអារម្មណ៍** ជាចិត្តមានអារម្មណ៍ទាំង៦។
**១២.ដោយទ្វារ** កើតតាមទ្វារទាំង ៦(ណាមួយ) និង ជាទ្វារវិមុត្តិ។
**១៣.ដោយវត្ថុ** កើតត្រង់ហទយវត្ថុ។
**១៤.ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ។

## មហាវិបាកចិត្ត ៨ ដួងនេះមានឈ្មោះហៅច្រើនយ៉ាងៈ

**១.កាមាវចរវិបាកចិត្ត** ព្រោះកើតតែក្នុងកាមភូមិប៉ុណ្ណោះ។
**២.កាមសោភណវិបាក** ព្រោះមានសោភណចេតសិកកើតរួមជាមួយ និង ជាកាមាវចរសោភណចិត្តផង។

**៣.សហេតុកវិបាក** ព្រោះប្រកបដោយហេតុ គឺ អលោភៈ អទោសៈ អមោហៈ (បញ្ញា)។

**៤.មហាវិបាក** ព្រោះវិបាកដែលកើតបានច្រើនអនេកតាមចំនួននៃមហា-កុសលចិត្តដែលគុណទុកហើយនោះ។

**ភាមាវចរវិបាកចិត្តទាំងអស់មាន ២៣ ដួង គឺះ**

**១.អកុសលវិបាកចិត្ត ៧ ដួង**

**២.អហេតុកកុសលវិបាកចិត្ត ៨ ដួង**

**៣.មហាវិបាកចិត្ត ៨ ដួង**

## គ.មហាកិរិយាចិត្ត ៨ ដួង

មហាកិរិយាចិត្តមិនមែនជាកុសលផង មិនមែនអកុសលផង ទាំងមិនមែនជាវិបាកផង គឺជាអព្យាកតចិត្ត ដែលមានត្រឹមតែការធ្វើប៉ុណ្ណោះ ដូចជាដើមឈើដែលគ្រាន់តែចេញផ្កា តែមិនអាចចេញផ្លែបាន ព្រោះមានឫសដាច់អស់ហើយ។

**១.សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនាប្រកប ដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានការបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៥ ប្រភេទគឺ ៖**

-អញ្ញសមានាចេតសិក ១៣

-សោភណសាធារណចេតសិក ១៩

-អប្បមញ្ញាចេតសិក ២

-បញ្ញាចេតសិក ១

**២.សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញាមានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៥ ប្រភេទគឺ ៖**

-អញ្ញសមានាចេតសិក ១៣

-សោភណសាធារណចេតសិក ១៩

-អប្បមញ្ញាចេតសិក ២

-បញ្ញាចេតសិក ១

**៣.សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកបញ្ញាមានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានការបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៤ ប្រភេទគឺ ៖**

-អញ្ញសមានាចេតសិក ១៣

-សោភណសាធារណចេតសិក ១៩

-អប្បមញ្ញាចេតសិក ២

**៤.សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាក បញ្ញាមានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៤ ប្រភេទដូចទី ៣ ដែរ។**

**៥.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយ បញ្ញាមានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានការបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៤ ប្រភេទគឺ ៖**

-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

-សោភណសាធារណចេតសិក ១៩

-អប្បមញ្ញាចេតសិក ២

-បញ្ញាចេតសិក ១

**៦.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយ បញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៤ ប្រភេទគឺ ៖**

-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

-សោភណសាធារណចេតសិក ១៩

-អប្បមញ្ញាចេតសិក ២

-បញ្ញាចេតសិក ១

**៧.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៣ ប្រភេទគឺ ៖**

-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

-សោភណសាធារណចេតសិក ១៩

-អប្បមញ្ញាចេតសិក ២

**៨.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ**

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

**មានចេតសិកកើតរួមជាមួយ ៣៣ ប្រភេទគឺ ៖**

-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

-សោភណសាធារណចេតសិក ១៩

-អប្បមញ្ញាចេតសិក ២

**មហាកិរិយាចិត្ត ៨ ដួងនេះមានឈ្មោះហៅច្រើនយ៉ាង ៖**

**១.កាមាវចរកិរិយាចិត្ត** ព្រោះបង្អោនទៅដឹងកាមារម្មណ៍ (មាន-

បញ្ចកាមគុណជាអារម្មណ៍)។

**២.កាមសោភណកិរិយាចិត្ត** ព្រោះមានសោភណចេតសិក កើតរួមជាមួយផង។

**៣.សហេតុកកិរិយាចិត្ត** ព្រោះប្រកបដោយហេតុ។

**៤.មហាកិរិយាចិត្ត** ព្រោះច្រើនទៅដោយអារម្មណ៍ និង ទ្វារដូចមហាកុសលចិត្តដែរ។

## ការចែកមហាកិរិយាចិត្ត ៨ ដួងដោយន័យផ្សេងៗ

**១.ដោយជាតិ** ជាកិរិយាជាតិ។

**២.ដោយភូមិ** ជាកាមភូមិ កើតបាន ២៦ភូមិ(វៀរអបាយភូមិ៤ និង អសញ្ញសត្តាភូមិ)។

**៣.ដោយវេទនា** ជាសោមនស្សវេទនា ៤ ដួង ជាឧបេក្ខាវេទនា ៤ ដួង។

**៤.ដោយហេតុ** ជានហេតុ និង ជាសហេតុកចិត្ត។

**៥.ដោយសម្បយុត្ត** ជាញាណសម្បយុត្ត ៤ ដួង ជាញាណវិប្បយុត្ត ៤ ដួង។

**៦.ដោយសង្ខារ** ជាអសង្ខារិក ៤ ដួង និង ជាសសង្ខារិក ៤ ដួង។

**៧.ដោយសោភណៈ** ជាកាមាវចរសោភណចិត្ត។

**៨.ដោយឈាន** ជាអឈានចិត្ត។

**៩.ដោយលោកិយ** ជាលោកិយចិត្ត។

**១០.ដោយកិច្ច** មហាកិរិយាចិត្តធ្វើជវនកិច្ចតែម្យ៉ាង។

**១១.ដោយអារម្មណ៍** មានអារម្មណ៍ទាំង ៦។

**១២.ដោយទ្វារ** កើតតាមទ្វារទាំង ៦។
**១៣.ដោយវត្ថុ** កើតត្រង់ហទយវត្ថុ។
**១៤.ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ។

## ២.រូបាវចរឈានចិត្ត ១៥ ដួង

ពាក្យថា **ឈាន** សំដៅដល់សេចក្តីពីរយ៉ាងគឺ៖

១.សំដៅដល់ការសម្លឹងពិចារណាដុតកម្តៅសភាវធម៌ដែលជាបដិបក្ខ ដូចជានីវរណៈធម៌ ជាដើមឱ្យអស់ទៅ។

២.សំដៅដល់ចិត្តដែលចុះតាំងណែនក្នុងអារម្មណ៍នៃកម្មដ្ឋាន មានបឋវីកសិណជាដើម ដោយអំណាចនៃអប្បនាសមាធិនោះឯង ទើបហៅថា **ឈាន**។

ពាក្យថា **រូបជ្ឈាន** មានន័យថា ឈានដែលបានមកអំពីការសម្លឹង នូវបឋវីកសិណជាដើម ដូចនេះហើយទើបហៅថា **រូបជ្ឈាន ឬរូបាវចរឈាន**។

រូបជ្ឈាន ដែលជាកុសល ហៅថា **រូបាវចរកុសលចិត្ត**។

រូបជ្ឈាន ដែលជាវិបាក ហៅថា **រូបាវចរវិបាកចិត្ត**។

រូបជ្ឈាន ដែលជាកិរិយា ហៅថា **រូបាវចរកិរិយាចិត្ត**។

រូបាវចរចិត្តនោះក្នុងព្រះអភិធម្មបានកំណត់ថាមាន ១៥ ដួង ដែលចែកជាកុសល ៥ ដួង ជាវិបាក ៥ ដួង ជាកិរិយា ៥ ដួង រួមទាំងអស់១៥ ដួងដែលនឹងសម្តែងដូចតទៅនេះ៖

### ក.រូបាវចរកុសលចិត្ត ៥ ដួង

**១.វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈានកុសល-ចិត្តំ**

បឋមជ្ឈានកុសលចិត្ត ប្រកបព្រមដោយ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

**មានចេតសិកប្រកបជាមួយ ៣៥ ប្រភេទគឺ ៖**

**-អញ្ញសមានាចេតសិក ១៣**

**-សោភណសាធារណចេតសិក ១៩**

**-អប្បមញ្ញាចេតសិក ២**

**-បញ្ញាចេតសិក ១**

***សួរថា** បើចេតសិកកើតរួមក្នុងចិត្តនោះដល់ទៅ ៣៥ ប្រភេទ ឯណោះ ហេតុដូចម្ដេចទើបព្រះអង្គសម្ដែងតែធម៌ ៥ នេះ ថាជាអង្គឈាន?

***ឆ្លើយថា** ព្រោះធម៌ ៥ នេះ មានកិច្ច(គឺតួនាទី)សម្លឹងពិចារណាអារម្មណ៍ និង បដិបក្ខដោយត្រង់ចំពោះកាមឆន្ទៈនីវរណៈ ជាដើមគឺ ៖

**១.ឯកគ្គតា** ជាបដិបក្ខ និង កាមឆន្ទៈ

**២.បីតិ** ជាបដិបក្ខ និង ព្យាបាទ

**៣.វិតក្កៈ** ជាបដិបក្ខ និង ថីនៈ មិទ្ធៈ

**៤.សុខៈ** ជាបដិបក្ខ និង ឧទ្ធច្ចកុក្កុច្ចៈ

**៥.វិចារៈ** ជាបដិបក្ខ និង វិចិកិច្ឆា។

**២.វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយជ្ឈានកុសលចិត្តំ**

ទុតិយជ្ឈានកុសលចិត្ត ប្រកបព្រមដោយ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

**មានចេតសិកប្រកបជាមួយ ៣៤ ប្រភេទ គឺ ៖**

**-អញ្ញសមានាចេតសិក ១២** ( វៀរ វិតក្ក )

-សោភណសាធារណចេតសិក ១៩

-អប្បមញ្ញាចេតសិក ២

-បញ្ញាចេតសិក ១

**៣.បីតិ សុខេកគ្គតា សហិតំ តតិយជ្ឈានកុសលចិត្តំ**

តតិយជ្ឈានកុសលចិត្ត ប្រកបព្រមដោយ បីតិ សុខៈ ឯកគ្គតា ។

**មានចេតសិកប្រកបជាមួយ ៣៣ ប្រភេទគឺ ៖**

-អញ្ញសមានាចេតសិក ១១ (វៀរ វិតក្ក វិចារ)

-សោភណសាធារណចេតសិក ១៩

-អប្បមញ្ញាចេតសិក ២

-បញ្ញាចេតសិក ១

**៤.សុខេ កគ្គតា សហិតំ ចតុត្ថជ្ឈានកុសលចិត្តំ**

ចតុត្ថជ្ឈានកុសលចិត្ត ប្រកបព្រមដោយ សុខៈ ឯកគ្គតា ។

**មានចេតសិកប្រកបជាមួយ ៣២ ប្រភេទគឺ៖**

-អញ្ញសមានាចេតសិក ១០ (វៀរ វិតក្ក វិចារ បីតិ)

-សោភណសាធារណចេតសិក ១៩

-អប្បមញ្ញាចេតសិក ២

-បញ្ញាចេតសិក ១

**៥.ឧបេក្ខេកគ្គតា សហិតំ បញ្ចមជ្ឈាន កុសលចិត្តំ**

បញ្ចមជ្ឈានកុសលចិត្ត ប្រកបព្រមដោយ ឧបេក្ខា និង ឯកគ្គតា ។

**មានចេតសិកប្រកបជាមួយ ៣០ ប្រភេទគឺ៖**

-អញ្ញសមានាចេតសិក ១០ (វៀរ វិតក្ក វិចារ បីតិ)

-សោភណសាធារណចេតសិក ១៩

-បញ្ញាចេតសិក ១

- **បឋមជ្ឈានកុសលចិត្តកាលកើតឡើងនឹងមានវិថីចិត្តយ៉ាងនេះគឺ ៖**

**១.ភវង្គចិត្ត** ជាមហាវិបាកញាណសម្បយុត្ត។

**២.ភវង្គចលនៈ** ជាមហាវិបាកញាណសម្បយុត្ត។

**៣.ភវង្គុប្បច្ឆេទៈ** ជាមហាវិបាកញាណសម្បយុត្ត។

**៤.មនោទ្វារាវជ្ជនៈ** ជាអហេតុកកិរិយាចិត្ត។

**៥.បរិកម្ម** ជាមហាកុសលញាណសម្បយុត្ត។

**៦.ឧបចារៈ** ជាមហាកុសលញាណសម្បយុត្ត។

**៧.អនុលោម** ជាមហាកុសលញាណសម្បយុត្ត។

**៨.គោត្រភូ** ជាមហាកុសលញាណសម្បយុត្ត។

**៩.បឋមជ្ឈានកុសលចិត្ត** ជារូបាវចរកុសលចិត្ត។

**១០.ភវង្គចិត្ត** ជាមហាវិបាកញាណសម្បយុត្ត។

**មហាកុសលជវនខណៈទី ១** ជាបរិកម្មនៃអប្បនាសមាធិ។ អារម្មណ៍តាំងណែនព្រោះតែតាំងអប្បនាចិត្ត គឺថាបើមហាកុសលដែលជាបរិកម្មមិនកើតឡើងទេ ខណៈចិត្តបន្ទាប់តទៅ និង អប្បនាសមាធិ គឺឈានចិត្តក៏កើតឡើងមិនបានឡើយ។

**មហាកុសលជវនខណៈទី ២**ជាឧបចារៈព្រោះចូលទៅជិតអប្បនា-សមាធិ។

**មហាកុសលជវនខណៈទី ៣** ជាអនុលោមព្រោះជា ឧបចារៈដល់អប្បនាសមាធិ ។

**មហាកុសលជវនខណៈទី ៤** ជាគោត្រភូ ព្រោះឆ្លងកាមាវចរភូមិដើម្បីឡើងដល់រូបាវចរភូមិ។

*កាលដែលមហាកុសលជវនខណៈទី ៤ រលត់ហើយ ជវនវិថីខណៈបន្ទាប់ទៅទើបជារូបាវចរបឋមជ្ឈានកុសលចិត្ត។

- **ទុតិយជ្ឈានកុសលចិត្ត**

កាលព្រះយោគាវចរ(អ្នកត្រាច់ប្រព្រឹត្តធម៌ ឬ ព្រះយោគី គឺអ្នកមានធម៌ហ្វឹកហាត់ព្យាយាមចូលបឋមជ្ឈានរហូតស្ទាត់ជំនាញល្អ ដល់ព្រមដោយវសីទាំង ៥ គឺ៖

**១.អាវជ្ជនវសី** ជំនាញក្នុងការនឹករក គឺថាព្រះយោគាវចរចូលឈាន នឹងចេញចាកឈានរហូតស្ទាត់ជំនាញ ហើយហ្វឹកហាត់ដោយពិចារណាថានឹករកអ្វីហ្ន៎ ទើបឈានអាចកើតឡើងបានឆាប់រហ័សហ្វឹកហាត់ដោយវិធីយ៉ាងនេះរឿយៗ រហូតទាល់តែស្ទាត់ជំនាញ។

**២.សមាបជ្ជនវសី** ជំនាញក្នុងការចូលកាន់ឈាន គឺឱ្យឈានចិត្តកើតបានក្នុងស្ថានទី និង ខណៈតាមដែលខ្លួនប្រាថ្នា។

**៣.អធិដ្ឋានវសី** ជំនាញក្នុងការឱ្យឈានតាំងនៅមាំ គឺជំនាញក្នុងការឱ្យឈានកើតរលត់បន្តគ្នាមិនឱ្យមានភវង្គ គឺថាឱ្យឈានតាំងនៅមាំយូរ ៗ ឬឆាប់ , តិច ឬ ច្រើន ក្នុងស្ថានទី និង ខណៈតាមដែលខ្លួនប្រាថ្នា។

**៤.វុដ្ឋានវសី** ជំនាញក្នុងការចេញចាកឈាន គឺថាបើចង់ចេញចាកឈាន ក្នុងវេលាណា ក៏ចេញបានក្នុងវេលានោះ មិនយឺតយូរឡើយ។

**៥.បច្ចវេក្ខណវសី** ជំនាញក្នុងការពិចារណាអង្គឈាន គឺកាលបើចេញចាកអំពីឈានហើយ ពិចារណាដើម្បីលះនូវអង្គឈាន ដែលគ្រោតគ្រាតចេញ ដើម្បីឱ្យអប្បនាសមាធិតាំងនៅមាំក្រៃលែងឡើង ។ រមែងពិចារណាឃើញថា វិតក្កៈនេះជាអង្គឈានដែលគ្រោតគ្រាតជាងវិចារៈ ព្រោះកៀកកិត នឹងកាមារម្មណ៍ ។ ដូច្នេះកាលនឹងឡើងកាន់ទុតិយជ្ឈាន ទើបលោកសម្លឹងបដិភាគនិមិត្ត ដើម្បីឱ្យចិត្តជាអប្បនាសមាធិដោយមិនមានវិតក្កៈតទៅ ក៏ព្យាយាមឧស្សាហ៍រហូតដល់ឈានចិត្តដែលមិនមានវិតក្កៈកើតឡើង ប៉ុន្តែគង់នៅមាន វិចារៈ បីតិ សុខៈ និង ឯកគ្គតា។

កាលទុតិយជ្ឈានចិត្តកើតឡើងនោះ ក៏ត្រូវមានវិថីចិត្តដែលកើតមុន គឺ មហាកុសលញាណសម្បយុត្តចិត្ត ដែលជាបរិកម្ម ឧបចារៈ អនុលោម និង គោត្រភូ ដូចគ្នា នឹងបឋមជ្ឈានចិត្តដែរ។

- **តតិយជ្ឈានកុសលចិត្ត**

កាលដែលព្រះយោគាវចរ ជំនាញក្នុងទុតិយជ្ឈានបានល្អប្រកបដោយវសី ៥ ហើយ ក៏សម្លឹងនូវបដិភាគនិមិត្តឡើងកាន់ឈានទី ៣ ដោយពិចារណាឃើញវិចារៈជាអង្គឈានគ្រោតគ្រាតកៀកកិតនឹងវិតក្កៈ ដែលធ្វើឱ្យវិនាសឈានបានងាយ ។ កាលឃើញទោសនៃវិចារហើយ ក៏ចូលឈាន សម្លឹងបដិភាគនិមិត្តដើម្បីឱ្យអប្បនាសមាធិកើតឡើងដោយមិនមានវិចារៈរហូតដល់តតិយជ្ឈានកើតមានទំនងដូចឈានមុនៗ ដែរ។

- **ចតុត្ថជ្ឈានកុសលចិត្ត**

កាលដែលយោគាវចរ ជំនាញក្នុងតតិយជ្ឈានបានល្អប្រកបដោយវសី ៥ ហើយក៏សម្លឹងបដិភាគនិមិត្តឡើងកាន់ឈានទី ៤ ដោយពិចារណាឃើញបីតិជាអង្គឈានគ្រោតគ្រាត។ ដើម្បីឱ្យចិត្តប្រណិតក្រៃលែងឡើង ទើបសម្លឹងបដិភាគនិមិត្តដើម្បីចម្រើនអប្បនាសមាធិ រហូតដល់មិនមានបីតិកើតរួមជាមួយ។ វិថីចិត្តដែលមុនចតុត្ថជ្ឈានកើតឡើងមានទំនងដូចឈានមុនៗ ដែរ។

➢ **បញ្ចមជ្ឈានកុសលចិត្ត**

កាលព្រះយោគាវចរ ជំនាញក្នុងចតុត្ថជ្ឈានបានល្អព្រមដោយវសី ៥ ហើយ ក៏ពិចារណាឃើញទោសរបស់សុខថា មានសភាពគ្រោតគ្រាតជាងឧបេក្ខា ព្រោះសុខនោះញាប់ញ័រ មិនតាំងមាំដូចឧបេក្ខាវេទនាទេ ទើបសម្លឹងបដិភាគនិមិត្តចម្រើនអប្បនាសមាធិដើម្បីលះសុខ រហូតដល់បញ្ចមជ្ឈានកើតឡើងប្រកបដោយអង្គ ២ គឺ ឧបេក្ខា និង ឯកគ្គតា។

*មហាកុសលញាណសម្បយុត្តដែលធ្វើបរិកម្ម ឧបចារ អនុលោម និង គោត្រភូ ដែលកើតមុនបញ្ចមជ្ឈាននោះកើតព្រមនឹងឧបេក្ខាវេទនា ព្រោះឈានទី៥នេះ មានឧបេក្ខា និង ឯកគ្គតា ជាអង្គឈាន។ ចំណែកឈាន៤ខាងដើម មហាកុសលនោះកើតព្រមនឹងសោមនស្សវេទនា។ម្យ៉ាងទៀត មហាកុសលញាណសម្បយុត្តចិត្ត ដែលកើតក្នុងរវាងការចម្រើនសមថភាវនានោះ ពេលខ្លះក៏កើតនឹងសោមនស្សវេទនា ពេលខ្លះក៏កើតព្រមនឹងឧបេក្ខាវេទនា ។

## ការចែករូបាវចរកុសលចិត្ត ៥ ដួងដោយន័យផ្សេងៗ

**១.ដោយជាតិ** ជាកុសលជាតិ។

**២.ដោយភូមិ** ជារូបាវចរភូមិកើតបាន ២២ ភូមិ(វៀរអបាយភូមិ ៤ អសញ្ញសត្តាភូមិ ១ អរូបភូមិ ៤)។

**៣.ដោយវេទនា** ជាសោមនស្សវេទនា ៤ដួង (បឋមជ្ឈាន ទុតិយ-ជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន) ជាឧបេក្ខាវេទនា ១ (បញ្ចមជ្ឈាន)។

**៤.ដោយហេតុ** ជានហេតុ និង ជាតិហេតុកចិត្ត។

**៥.ដោយសម្បយុត្ត** ជាញាណសម្បយុត្ត។

**៦.ដោយសង្ខារ** ជាសសង្ខារិក។

**៧.ដោយសោភណៈ** ជារូបាវចរសោភណចិត្ត។

**៨.ដោយឈាន** ជារូបាវចរឈាន។

**៩.ដោយលោកិយ** ជាលោកិយចិត្ត។

**១០.ដោយកិច្ច** ធ្វើជវនកិច្ច។

**១១.ដោយអារម្មណ៍** មានធម្មារម្មណ៍ជាអារម្មណ៍។

**១២.ដោយទ្វារ** ដឹងអារម្មណ៍តាមមនោទ្វារ។

**១៣.ដោយវត្ថុ** អាស្រ័យហទយវត្ថុ។

**១៤.ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ។

## ខ.រូបាវចរវិបាកចិត្ត ៥ ដួង

បាលី និង ប្រែ ដូចគ្នានឹងរូបាវចរកុសលចិត្តទាំងអស់ គ្រាន់តែប្តូរពីពាក្យ «**កុសលចិត្តំ**» មកជា «**វិបាកចិត្តំ**» ប៉ុណ្ណោះ។

**ចេតសិកកើតរួមជាមួយក៏ដូចគ្នានឹងរូបាវចរកុសលចិត្តទាំងអស់ផងដែរ។**

# **អធិប្បាយ**

កាមាវចរវិបាកតែងដូចគ្នាខ្លះ មិនដូចគ្នាខ្លះ នឹងកុសលចិត្តនៃខ្លួន ។ ដូច្នេះហើយទើបវិបាក នៃកាមាវចរកុសលចិត្តនោះ លោកមិនបានចែកវិបាកឱ្យស្របតាមដូចគ្នា នឹងកុសលរបស់ខ្លួនឡើយ។

ចំណែករូបាវចរវិបាកចិត្តនេះ តែងស្របដូចគ្នានឹងកុសលរបស់ខ្លួន ប្រៀបដូចជាស្រមោលទាំងឡាយមានស្រមោល ដំរី សេះ និង ដើមឈើជាដើម ព្រោះហេតុនោះទើបលោកចែករូបាវចរវិបាកនេះឱ្យស្របតាមកុសលរបស់ខ្លួន។

ម្យ៉ាងទៀតកាមាវចរកុសលតែងឱ្យវិបាកក្នុងកាលខ្លះក៏បាន គ្រាសម័យខ្លះក៏បាន ។ ចំណែករូបាវចរកុសល តែងឱ្យវិបាកក្នុងភពទី ២ តែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនេះហើយទើបលោកចែកឱ្យស្របគ្នានឹងកុសលរបស់ខ្លួនគឺ៖

**១-បឋមជ្ឈានកុសលចិត្ត** ឱ្យផលជាបឋមជ្ឈានវិបាកចិត្ត បដិសន្ធិក្នុងបឋមជ្ឈានភូមិ។

**២-ទុតិយជ្ឈានកុសលចិត្ត** ឱ្យផលជាទុតិយជ្ឈានវិបាកចិត្ត បដិសន្ធិក្នុងទុតិយជ្ឈានភូមិ។

**៣-តតិយជ្ឈានកុសលចិត្ត** ឱ្យផលជាតតិយជ្ឈានវិបាកចិត្ត បដិសន្ធិនៅទុតិយជ្ឈានភូមិ។

**៤-ចតុត្ថជ្ឈានកុសលចិត្ត** ឱ្យផលជាចតុត្ថជ្ឈានវិបាកចិត្ត បដិសន្ធិនៅ តតិយជ្ឈានភូមិ។

**៥-បញ្ចមជ្ឈានកុសលចិត្ត** ឱ្យផលជាបញ្ចមជ្ឈានវិបាកចិត្ត បដិសន្ធិ

នៅ ចតុត្ថជ្ឈានភូមិ។

* បុគ្គលដែលបដិសន្ធិ ក្នុងរូបាវចរភូមិ គឺបដិសន្ធិដោយរូបាវចរវិបាកចិត្ត ជារូបព្រហ្ម ។ រូបព្រហ្មបុគ្គលនោះតែងមានចក្ខុបសាទ និង សោតបសាទ ល្អតែមិនមានឃានបសាទ ជិវ្ហាបសាទ និង កាយបសាទទេ ។ គប្បីជ្រាប ថា ការកើតឡើងនៃចក្ខុវិញ្ញាណ និង សោតវិញ្ញាណរបស់ព្រហ្មនោះ មិន មែនជាវិបាកនៃរូបាវចរកុសល ៥ ដួងទេ គឺជាវិបាករបស់មហាកុសលចិត្ត និង អកុសលចិត្តប៉ុណ្ណោះ។

រូបាវចរវិបាកចិត្ត ៥ដួងនេះ ធ្វើកិច្ចបដិសន្ធិនៅក្នុងរូបព្រហ្មទាំង១៥ (វៀរអសញ្ញសត្តាភូមិ) គឺ៖

**១- បារិសជ្ជាភូមិ**
**២-បុរោហិតាភូមិ**
**៣-មហាព្រហ្មាភូមិ**
— បដិសន្ធិដោយបឋមជ្ឈានវិបាក ។

**៤-បរិត្តាភាភូមិ**
**៥-អប្បមាណាភាភូមិ**
**៦-អាភស្សរាភូមិ**
— បដិសន្ធិដោយទុតិយជ្ឈានវិបាក (ចតុក្កន័យ) ឬដោយទុតិយជ្ឈានវិបាក និងតតិយជ្ឈានវិបាក(បញ្ចកន័យ)។

**៧-បរិត្តសុភាភូមិ**
**៨-អប្បមាណសុភាភូមិ**
**៩-សុភកិណ្ហាភូមិ**
— បដិសន្ធិដោយតតិយជ្ឈានវិបាក(ចតុក្កន័យ) ឬដោយចតុត្ថជ្ឈានវិបាក (បញ្ចកន័យ)។

**១០-វេហប្ផលាភូមិ** >បដិសន្ធិដោយចតុត្ថជ្ឈានវិបាក (ចតុក្កន័យ)ឬដោយបញ្ចមជ្ឈានវិបាក (បញ្ចកន័យ)។

**១១- អវិហាភូមិ**
**១២- អតប្បាភូមិ**
**១៣-សុទស្សាភូមិ**
**១៤-សុទស្សីភូមិ**
**១៥-អកនិដ្ឋាភូមិ**

ទាំង ៥ ភូមិនេះជាព្រហ្មសុទ្ធាវាសនៃព្រះអនាគាមី បដិសន្ធិដោយ ចតុត្ថជ្ឈានវិបាក(ចតុក្កន័យ) ឬ បញ្ចមជ្ឈានវិបាក(បញ្ចកន័យ)។

## ការចែករូបាវចរវិបាកចិត្ត ៥ ដួងដោយន័យផ្សេងៗ

| | |
|---|---|
| **១-ដោយជាតិ** | ជាវិបាកជាតិ |
| **២- ដោយភូមិ** | ជារូបភូមិ |
| **៣-ដោយវេទនា** | ៤ ដួងខាងដើម ( បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន)ជាសោមនស្សវេទនា ១ ដួងខាងចុង (បញ្ចមជ្ឈាន)ជាឧបេក្ខាវេទនា។ |
| **៤-ដោយហេតុ** | ជានហេតុ និង តិហេតុកចិត្ត។ |
| **៥-ដោយសម្បយុត្ត** | ជាញាណសម្បយុត្ត។ |
| **៦-ដោយសង្ខារ** | ជាសសង្ខារិកចិត្ត។ |
| **៧-ដោយសោភណៈ** | ជារូបាវចរសោភណចិត្ត។ |
| **៨-ដោយឈាន** | ជាផលនៃកុសលឈាន។ |
| **៩-ដោយលោកិយ** | ជាលោកិយចិត្ត។ |

**១០-ដោយកិច្ច** មានកិច្ច ៣ គឺ បដិសន្ធិកិច្ច ១ ភវង្គកិច្ច១ ចុតិកិច្ច ១។

**១១-ដោយអារម្មណ៍** រូបាវចរកុសលឈានមានអារម្មណ៍ណាជាកម្មដ្ឋាន រូបាវចរវិបាកចិត្តក៏មានអារម្មណ៍នោះដែរ។

**១២-ដោយទ្វារ** ជាទ្វារវិមុត្តិចិត្ត។

**១៣-ដោយវត្ថុ** អាស្រ័យហទយវត្ថុ។

**១៤-ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ។

## គ.រូបាវចរកិរិយាចិត្ត ៥ ដួង

ទាំងបាលី ទាំងប្រែ និង ចេតសិកដែលកើតរួមជាមួយ ដូចគ្នា នឹងរូបាវចរកុសលចិត្តទាំងអស់គ្រាន់តែប្តូរពីពាក្យថា **«កុសលចិត្តំ»** មកជា **«កិរិយាចិត្តំ»**ប៉ុណ្ណោះ។

-រូបាវចរកិរិយាចិត្ត ជាចិត្តរបស់ព្រះខីណាស្រពគឺជារូបាវចររបស់ព្រះខីណាស្រពជាកិរិយាមិនមែនជាកុសល មិនមែនជាអកុសល មិនមែនជាវិបាក ជាទិដ្ឋធម្មសុខវិហារ(នៅជាសុខក្នុងបច្ចុប្បន្ន) គឺដើម្បីនៅជាសុខក្នុងបច្ចុប្បន្ននេះតែប៉ុណ្ណោះ។

## ការចែករូបាវចរកិរិយាចិត្ត ៥ ដួងដោយន័យផ្សេងៗ

**១-ដោយជាតិ** ជាកិរិយាជាតិ។

**២- ដោយភូមិ** ជារូបភូមិ។

**៣-ដោយវេទនា** ជាសោមនស្សវេទនា ៤ ដួង ជាឧបេក្ខាវេទនា ១ ដួង។

**៤-ដោយហេតុ** ជានហេតុ និង ជាតិហេតុកចិត្ត។

**៥-ដោយសម្បយុត្ត** ជាញាណសម្បយុត្ត។
**៦-ដោយសង្ខារ** ជាសសង្ខារិកចិត្ត។
**៧-ដោយសោភណ** ជារូបាវចរសោភណចិត្ត។
**៨-ដោយឈាន** ជារូបាវចរកិរិយាឈានចិត្ត។
**៩-ដោយលោកិយ** ជាលោកិយចិត្ត។
**១០-ដោយកិច្ច** ធ្វើជវនកិច្ចតែម្យ៉ាង។
**១១-ដោយអារម្មណ៍** មានធម្មារម្មណ៍ជាអារម្មណ៍។
**១២-ដោយទ្វារ** ជាមនោទ្វារ។
**១៣-ដោយវត្ថុ** អាស្រ័យហទយវត្ថុ។
**១៤-ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ។

## ៣.អរូបាវចរចិត្ត ១២ ដួង

### ក.អរូបាវចរកុសលចិត្ត ៤ ដួង

**- អាកាសានញ្ចាយតន កុសលចិត្តំ**
**- វិញ្ញាណញ្ចាយតន កុសលចិត្តំ**
**- អាកិញ្ចញ្ញាយតន កុសលចិត្តំ**
**- នេវសញ្ញានាសញ្ញាយតន កុសលចិត្តញ្ចេតិ ឥមានិ ចិត្តានិបិ អរូបាវចរកុសលចិត្តានិ នាម ។**

ប្រែថា៖
-អាកាសានញ្ចាយតន កុសលចិត្ត ១
-វិញ្ញាណញ្ចាយតន កុសលចិត្ត ១

-អាកិញ្ចញ្ញាយតន កុសលចិត្ត ១
-នេវសញ្ញានាសញ្ញាយតន កុសលចិត្ត ១
ចិត្ត ៤ ដួងនេះ ឈ្មោះថា **អរូបាវចរកុសលចិត្ត** ។

## អធិប្បាយអាកាសានញ្ចាយតនៈ

**អាកាសានញ្ចាយតនៈ** មកពី <**អាកាស+អានញ្ច+អាយតនៈ** មានន័យថា ជាអាយតនៈ(ជាទីកើត) ដែលអាកាសមិនមានទីបំផុត គឺថា **អាកាសានញ្ច** នោះឯង ជាអាយតនៈ (គឺជាទីកើត) នៃឈាននោះព្រម ដោយសម្បយុត្តធម៌ដោយអត្ថថា ជាទីតាំងនៅដូច **ទេវាយតនៈ**ទីអាស្រ័យ នៅនៃពួកទេវតា។

**ឈាន** ឈ្មោះថា អាកាសានញ្ចាយតនៈ ព្រោះអត្ថថា មានអាកាស មិនមានទីបំផុត ជាទីកើតកុសលចិត្ត ដែលសម្បយុត្តជាមួយ **អាកាសានញ្ចាយតនៈ**នោះ ឈ្មោះថា **អាកាសានញ្ចាយតនកុសលចិត្ត** ។

## អាកាសមាន ៤ ប្រការ គឺ ៖

**១-អជដាកាស** បានដល់ អាកាស (មេឃ)
**២-បរិច្ឆិន្នាកាស** បានដល់ អាកាសកសិណ
**៣-កសិណុគ្ឃាដិមាកាស** បានដល់អាកាសដែលអាស្រ័យមកពី កសិណ ៩ (វៀរអាកាសកសិណ)។
**៤-បរិច្ឆេទាកាស** បានដល់អាកាសរូប។

**អាកាសានញ្ចាយតនៈ** បានដល់ **កសិណុគ្ឃាដិមាកាស** ប៉ុណ្ណោះ មិនបានសំដៅដល់អាកាសកសិណទេ។

## វិធីចម្រើនអាកាសានញ្ចាយតនជ្ឈាន(ទី១)

ព្រះយោគីបុគ្គលដែលនឹងចម្រើនអរូបកម្មដ្ឋានឱ្យកន្លងនូវ រូបជ្ឈាននោះ ដំបូងត្រូវបានរូបាវចរបញ្ចមជ្ឈាន ព្រមទាំងមានការជំនាញក្នុងវសី៥សិន ក៏ឃើញទោសរបស់រូបជ្ឈាន ដោយប្រការផ្សេងៗ។

លោកមិនត្រឹមតែឃើញទោសរបស់ រូបជ្ឈាន ប៉ុណ្ណោះទេ រមែងឃើញទោសនៃរូបរាងកាយផងដែរថា មានរូបហើយក៏ត្រូវតែមានទុក្ខទោស លំបាកកាយមានការទទួលនូវអាជ្ញា និង រោគា ព្យាធិផ្សេង ៗ ជាដើម។បើមិនមានរូបរាងកាយទេនោះ ទុក្ខទោសទាំងឡាយ មានព្យាធិជាដើម រមែងមិនមាន។ ឯការដែលនឹងចាកផុតរូបរាងកាយទៅបានក៏ត្រូវចម្រើនឈានមិនមានរូបហៅថា«**អរូបជ្ឈាន**» ជាអារម្មណ៍យ៉ាងនេះ៖

កាលណាព្រះយោគីបុគ្គលឃើញទោសនៃរូប និង វិធីដែលនឹងរួចចាកពីរូបយ៉ាងនេះហើយក៏ចូលរូបជ្ឈានទី ៥ ធ្វើឱ្យកើតឡើងសិន។

កាលចេញពីឈានពិចារណាឃើញទោសនៃរូបជ្ឈានកម្មដ្ឋាន ដែលជាអារម្មណ៍ហើយ ក៏ចូលឈាននោះ ផ្សាយពង្រីកនិមិត្ត (រូបកម្មដ្ឋាន)នោះឱ្យមិនមានទីបំផុត គឺ ផ្សាយចេញទៅបានដល់ ១ ចក្រវាឡ ។ ដោយការផ្សាយពង្រីកទៅៗ នូវរូបនិមិត្តនៃរូបកម្មដ្ឋាន ដែលជាអារម្មណ៍ច្រើនប៉ុណ្ណាក៏មិនមានទីបំផុត អាកាសដែលល្ហល្ហេវនោះ មិនមានការកើត មិនមានការវិនាសរកទីបំផុតមិនបាន។ការឃើញសេចក្តីមិនមានទីបំផុតនៃអាកាសក៏បើកសញ្ញា គឺមិនដាក់ចិត្តទៅក្នុងរូបនិមិត្តដែលជាអារម្មណ៍នោះ យកចិត្តទុកដាក់តែសភាពនៃអាកាសមិនមានទីបំផុត (**អាកាសោ អនន្តោ** )។ ក្នុងខណៈដែលចិត្តគិតដល់អាកាសមិនមានទីបំផុតនេះ ពេលនោះនូវមានរូប-និមិត្តដែលពង្រីកផ្សាយទៅដែរ ទាំងឧបចារសមាធិ ក៏កើតឡើងជា

លំដាប់ ។ កាលដាក់ចិត្តដល់អាកាសមិនមានទីបំផុតរឿយៗទៅ ទីបំផុត អប្បនាសមាធិ ក៏កើតឡើង ដោយមានអាកាសដែលមិនមានទីបំផុតនោះ ជាអារម្មណ៍ ។ អាកាសដែលមិនមានទីបំផុតនេះ ជាទីតាំងឱ្យកើតបឋម-អរូបជ្ឈានទី ១ ហៅថា **អាកាសានញ្ចាយតនកុសលចិត្ត** ជា**កសិណុគ្ឃាដិ-មាកាសបញ្ញត្តិ** ដែលបានបើករូបកសិណចេញហើយ ជាអារម្មណ៍។

កាលអប្បនាវិធី ដែលជាអាទិកម្មិក អរូបជ្ឈានរបស់មន្ទបុគ្គល (អ្នក-ដឹងយឺត) នឹងកើតឡើងនោះវិថីចិត្តរមែងកើតតាមលំដាប់យ៉ាងនេះគឺ ៖

-***ភវង្គចិត្ត*** ជាមហាវិបាកញាណសម្បយុត្ត<br>
-***ភវង្គចលនៈ*** ជាមហាវិបាកញាណសម្បយុត្ត<br>
-***ភវង្គុបច្ឆេទៈ*** ជាមហាវិបាកញាណសម្បយុត្ត<br>
} ចិត្តផុតវិថី។

-**មនោទ្វារាវជ្ជនៈ** ជាអហេតុកកិរិយាចិត្ត

-**បរិកម្ម**<br>
-**ឧបចារៈ**<br>
-**អនុលោម**<br>
-**គោត្រភូ**<br>
} ជាមហាកុសលចិត្តប្រកបដោយ ឧបេក្ខាវេទនា ញាណសម្បយុត្ត ២ដូង។

- **បឋមអរូបជ្ឈាន** គឺ អាកាសានញ្ចាយតនកុសលចិត្ត។
- ***ភវង្គចិត្ត*** ជាមហាវិបាកញាណសម្បយុត្ត ។

## អាទិកម្មិកអរូបជ្ឈានវិថីរបស់មន្ទបុគ្គល

-***ភវង្គចិត្ត*** ជាមហាវិបាកញាណសម្បយុត្ត<br>
-***ភវង្គចលនៈ*** ជាមហាវិបាកញាណសម្បយុត្ត<br>
-***ភវង្គុបច្ឆេទៈ*** ជាមហាវិបាកញាណសម្បយុត្ត<br>
} ចិត្តផុតវិថី។

**-មនោទ្វារាវជ្ជនៈ** ជាអហេតុកកិរិយាចិត្ត

**-បរិកម្ម**

**-ឧបចារៈ**

**-អនុលោម** } ជាមហាកុសល ឧបេក្ខាញាណសម្បយុត្ត ២ ដួង។

**-គោត្រភូ**

- **បឋមអរូបជ្ឈាន** គឺជាអាកាសានញ្ចាយតនកុសលចិត្ត។
- **ភវង្គចិត្ត** ជាមហាវិបាកញាណសម្បយុត្ត ។

## អាទិកម្មិកអរូបជ្ឈានវិថីរបស់តិក្ខបុគ្គល

**-ភវង្គចិត្ត** ជាមហាវិបាកញាណសម្បយុត្ត

**-ភវង្គចលនៈ** ជាមហាវិបាកញាណសម្បយុត្ត } ចិត្តផុតវិថី។

**-ភវង្គុបច្ឆេទៈ** ជាមហាវិបាកញាណសម្បយុត្ត

**-មនោទ្វារាវជ្ជនៈ** ជាអហេតុកកិរិយាចិត្ត

**-ឧបចារៈ**

**-អនុលោម** } ជាមហាកុសល ឧបេក្ខាញាណសម្បយុត្ត ២ ដួង។

**-គោត្រភូ**

- **បឋមអរូបជ្ឈាន** គឺ អាកាសានញ្ចាយតនកុសលចិត្ត។
- **ភវង្គចិត្ត** ជាមហាវិបាកញាណសម្បយុត្ត។

## វិញ្ញាណញ្ចាយតនចិត្ត

**វិញ្ញាណញ្ចាយតនៈ** < វិញ្ញាណ +អានញ្ច+ អាយតនៈ

**មានន័យថា** ជាអាយតនៈមួយកន្លែងដែលវិញ្ញាណមិនមានទីបំផុត ។ វិញ្ញាណនោះឯងរកទីបំផុតមិនបានទើបឈ្មោះថា **វិញ្ញាណញ្ច** បានដល់អរូបវិញ្ញាណទី ១។

ម្យ៉ាងឈ្មោះថា **វិញ្ញាណញ្ច** ព្រោះអត្ថថា ដែលត្រូវអរូបវិញ្ញាណទី២ គប្បីដល់គឺគប្បីសម្រេច ។ ដូច្នេះវិញ្ញាណញ្ចាយតនៈ ព្រោះអត្ថថា **វិញ្ញាណញ្ច** នោះជាអាយតនៈព្រោះជាទីតាំងនៃអរូបជ្ឈានទី ២ គឺ**វិញ្ញាណ-ញ្ចាយតនជ្ឈាន**។

## វិញ្ញាណញ្ចាយតនជ្ឈាន ( ទី ២ )

**វិញ្ញាណញ្ចាយតនជ្ឈាន** ព្រះយោគីបុគ្គលកាលជំនាញក្នុង អាកា-សានញ្ចាយតនឈានហើយមានបំណងនឹងចម្រើននូវអរូបជ្ឈានទី ២ ត្រូវធ្វើវសី ៥ ឱ្យស្ទាត់ហើយ ពិចារណាឃើញទោសនៃ**អាកាសានញ្ចាយតន-ជ្ឈាន** ឃើញសេចក្តីស្ងប់ប្រណិតរបស់វិញ្ញាណញ្ចាយតនជ្ឈាន ហើយក៏ចូលឈានទាញយកបឋមអរូបជ្ឈាន ជាអារម្មណ៍ដោយបង្អោនដោយសភាពរបស់វិញ្ញាណ ដែលមានអាកាសមិនមានទីបំផុតជាអារម្មណ៍ថា គឺវិញ្ញាណមិនមានទីបំផុត( **វិញ្ញាណំ អនន្តំ**) រហូតដល់អរូបជ្ឈានទី ២ កើតឡើងដែលមានអាកាសានញ្ចាយតនចិត្ត ជាអារម្មណ៍។ នេះឯងឈ្មោះថា វិញ្ញាណញ្ចាយតនជ្ឈាន ឬ ថាទុតិយអរូបជ្ឈានចិត្ត។

## អប្បនាវិធី នៃ ទុតិយអរូបជ្ឈាន

-**ភវង្គចិត្ត** ជាមហាវិបាកញាណសម្បយុត្ត
-**ភវង្គចលនៈ** ជាមហាវិបាកញាណសម្បយុត្ត
-**ភវង្គុបច្ឆេទៈ** ជាមហាវិបាកញាណសម្បយុត្ត
(ចិត្តផុតវិថី។)
-**មនោទ្វារាវជ្ជនៈ** ជាអហេតុកកិរិយាចិត្ត
-**បរិកម្ម**
-**ឧបចារៈ**
-**អនុលោម**
-**គោត្រភូ**
(ជាមហាកុសល ឧបេក្ខាញាណសម្បយុត្ត ២ ដួង។)
- **ទុតិយអរូបជ្ឈាន** គឺ វិញ្ញាណញ្ចាយតនកុសលចិត្ត។
- **ភវង្គចិត្ត** ជាមហាវិបាកញាណសម្បយុត្ត ។

## អាកិញ្ចញ្ញាយតនជ្ឈាន (ទី៣)

**អាកិញ្ចញ្ញាយតនៈ** មានន័យថា ជាអាយតនៈមួយកន្លែងដែលវិញ្ញាណសូម្បីបន្តិចបន្តួចក៏រមែងមិនមាន។

ព្រះយោគីបុគ្គលកាលបំណង នឹងធ្វើសមាធិឱ្យតាំងមាំប្រណិតឡើង ៗ ដោយការចូលអាកិញ្ចញ្ញាយតនជ្ឈាននោះ គឺ ត្រូវចូលវិញ្ញាណញ្ចាយតនជ្ឈានរហូតជំនាញនូវ វសីទាំង ៥ ។ កាលចេញពីឈានហើយក៏ពិចារណាឃើញទោសរបស់វិញ្ញាណញ្ចាយតនជ្ឈានថា បើដាច់ការចូលឈាននេះជានិច្ចហើយ ឈាននេះអាចវិនាសត្រឡប់ទៅតាំងនៅអាកាសានញ្ចាយតនជ្ឈានវិញ ឯសមាធិដែលកើតពីវិញ្ញាណញ្ចាយតនជ្ឈាននេះក៏នៅគ្រោតគ្រាតមិនប្រណិតស្មើនិងអាកិញ្ចញ្ញាយតនជ្ឈានដែរ ទើបដាក់ចិត្តដល់សភាពនៃសេចក្តីមិនមានអ្វីរបស់អរូបជ្ឈានទី ១ ជាអារម្មណ៍

ប្រៀបដូចជាសាលាធំ ជាទីប្រជុំនៃសង្ឃ ធ្វើសង្ឃកម្ម ដែលជាអាម្មណ៍ របស់អរូបជ្ឈានទី ២ នោះ ឥឡូវនេះព្រះសង្ឃធ្វើសង្ឃកិច្ចស្រេចហើយ ក៏ចេញពីសាលាទាំងអស់មិនមានសេសសល់ ចិត្តក៏បង្អោនទៅក្នុងសភាពដែលមិនមានអ្វីទៀតឡើយ **(នត្ថិ កិញ្ចិ = មិនមានអ្វីៗ)**រហូតអរូបជ្ឈានចិត្តកើតឡើង ដោយមាន **នត្ថិភាវបញ្ញត្តិ** ជាអារម្មណ៍។ អរូបជ្ឈានចិត្តនេះឈ្មោះថា **អាកិញ្ចញ្ញាយតនជ្ឈាន** ឬ **តតិយអរូបជ្ឈាន** (អាកិញ្ចញ្ញា-យតនកុសលចិត្ត)។

*វិថីចិត្តដែលកើតមុនអរូបជ្ឈានទី ៣ នេះ ដូចគ្នានឹងបឋមអរូបជ្ឈាន ឬ ទុតិយអរូបជ្ឈានវិថីដែរ ផ្សេងតែត្រង់ពាក្យថា **អាកិញ្ចញ្ញាយតន-កុសលចិត្ត** ប៉ុណ្ណោះ។

## នេវសញ្ញានាសញ្ញាយតនជ្ឈាន( ទី ៤ )

**នេវសញ្ញានាសញ្ញាយតនៈ** < **នេវ+សញ្ញា+ន+ន+សញ្ញា+អាយតនៈ** មានន័យថា ជាអាយតនៈមួយកន្លែងដែលតែងមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ព្រោះមិនមានសញ្ញាគ្រោតគ្រាត មានតែសញ្ញាល្អិត ។ នេវសញ្ញានាសញ្ញានោះឯង ជាអាយតនៈ ព្រោះសង្គ្រោះចូលក្នុងមនាយតនៈ និង ធម្មាយតនៈ ព្រោះហេតុនោះទើបឈ្មោះថា «**នេវសញ្ញា-នាសញ្ញាយតនជ្ឈាន**»។

នេវសញ្ញានាសញ្ញាយតនៈនោះឯង ជាអាយតនៈជាទីតាំងនៃឈានព្រមទាំងសម្បយុត្តធម៌ដោយជានិស្សយប្បច្ច័យ ជាដើម ដូច្នោះហើយទើបឈ្មោះថា «**នេវសញ្ញានាសញ្ញាយតនជ្ឈាន**»។

ព្រះយោគីបុគ្គល អ្នកចម្រើនអរូបជ្ឈានទី៤នោះត្រូវជំនាញអរូបៈជ្ឈានទី ៣ ព្រមទាំង វសី ៥ រួចហើយចម្រើនអរូបជ្ឈានទី ៤ ដែលជាឈានប្រណិតបំផុត ដោយពិចារណាឃើញនូវអរូបជ្ឈានទី ៣ នេះថាជាធម៌ស្ងប់ប្រណិត ប៉ុន្តែមិនទាន់ស្ងប់ប្រណិតបំផុតទេ។ ដូច្នេះដើម្បីនឹងចម្រើនអរូបជ្ឈានទី ៤ ត្រូវចូលអរូបជ្ឈានទី ៣ សិន លុះចេញហើយក៏យកចិត្តទុកដាក់ពិចារណាសេចក្តីស្ងប់ប្រណិត **ឯតំ សន្តំ ឯតំ បណីតំ** នៃសញ្ញាក្នុងអាកិញ្ចញ្ញាយតនជ្ឈាន មិនមែនសញ្ញាដទៃទៀតទេ (វេទនាជាដើមក្នុងទីនេះក៏ស្ងប់ប្រណិតដូចគ្នា) ។ ការដែលប្រើសញ្ញាស័ព្ទព្រោះសញ្ញាចេតសិកនេះជាតួចាំនិមិត្តតាំងអំពីការចម្រើនរូបជ្ឈានដំបូង ចម្រើនទៅរហូតដល់អរូបជ្ឈានទី៤ កើត។ កាលណាឈាននេះកើតក៏មានឈ្មោះថា **នេវសញ្ញានាសញ្ញាយតនៈ** ឬ **ចតុត្ថារូបជ្ឈាន** គឺ នេវសញ្ញា ។

*វិថីចិត្តដែលកើតមុនអរូបជ្ឈានទី ៤ ក៏មានន័យដូចសេចក្តីដែលបានពោលរួចមកហើយ។

## ខ.អរូបាវចរវិបាកចិត្ត ៤ ដួង

អរូបាវចរវិបាកចិត្ត៤ដួង ជាផលរបស់អរូបាវចរកុសលចិត្ត គឺ អាកាសានញ្ចាយតនកុសល មានអាកាសមិនមានទីបំផុតជាអារម្មណ៍ អាកាសានញ្ចាយតនវិបាកចិត្ត ក៏មានអាកាសមិនមានទីបំផុតជាអារម្មណ៍ដូចគ្នាដែរ ឯអរូបជ្ឈានទី ២ ទី ៣ ទី ៤ ក៏មានន័យយ៉ាងនេះដែរ។

## អរូបាវចរវិបាកចិត្ត ៤ ដួង

**-អាកាសានញ្ចាយតន វិបាកចិត្តំ**

**-វិញ្ញាណញ្ចាយតន វិបាកចិត្តំ**

**-អាកិញ្ចញ្ញាយតនវិបាកចិត្តំ**

**-នេវសញ្ញានាសញ្ញាយតន វិបាកចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរវិបាកចិត្តានិ នាម។**

ប្រែថា៖

-អាកាសានញ្ចាយតនវិបាកចិត្ត ១

-វិញ្ញាណញ្ចាយតនវិបាកចិត្ត ១

-អាកិញ្ចញ្ញាយតនវិបាកចិត្ត ១

-នេវសញ្ញានាសញ្ញាយតន វិបាកចិត្ត ១

**ចិត្តទាំង ៤ ដួងនេះ ឈ្មោះថា អរូបាវចរវិបាកចិត្ត។**

ពេលដែលអរូបាវចរវិបាកចិត្តដួងណាមួយនឹងកើតឡើងនោះ មិនបានកើតជាវិថីដូចអរូបាវចរកុសលចិត្តទេ គឺថាមុនចុតិចិត្តនឹងកើតឡើងនោះអរូបាវចរកុសលដួងណាមួយកើតឡើងមុនរួច ទើបចុតិ។កាលចុតិចិត្តរលត់ហើយ អរូបាវចរវិបាកចិត្តដួងណាមួយក៏កើតឡើង ធ្វើកិច្ចបដិសន្ធិតអំពីចុតិចិត្តនោះទាន់ពេលភ្លាម។

អរូបាវចរកុសលចិត្តដែលកើតមុនចុតិចិត្តមានអារម្មណ៍អ្វី អរូបាវចរវិបាកចិត្ត ដែលកើតបន្ទាប់អំពីចុតិចិត្តនោះ ក៏មានអារម្មណ៍នោះដូចនឹងកុសលរបស់ខ្លួនដែរ។ ឯអរូបាវចរវិបាកចិត្ត ៣ ដួងផ្សេងទៀត ក៏មានន័យដូចគ្នានេះដែរ។

អរូបាវចរកុសលចិត្ត ធ្វើជវនកិច្ចតែម្យ៉ាងចំណែកអរូបាវចរវិបាកចិត្តនោះ ធ្វើកិច្ច ៣ យ៉ាងគឺ ៖

**១-បដិសន្ធិ** ធ្វើកិច្ចបដិសន្ធិជាអរូបព្រហ្មបុគ្គលក្នុងអរូបភូមិ ៤ ប៉ុណ្ណោះ។

**២-ភវង្គកិច្ច** ធ្វើកិច្ចរក្សាភពជាតិកំណើតឱ្យតាំងនៅដរាបរហូតស្មើអាយុនៃ
សង្ខារក្នុងភពនោះៗ។

**៣-ចុតិកិច្ច** ធ្វើកិច្ចឃ្លាតចាកអំពីភពនោះ ៗ ក្នុងវារៈដែលអស់អាយុនៃ
សង្ខារ ។

-អរូបាវចរវិបាកចិត្ត ៤ ដួង ជាចិត្តកើតឡើងដោយមិនអាស្រ័យវត្ថុទាំង ៦ ណាមួយឡើយ ហើយមានចំពោះតែអរូបព្រហ្មប៉ុណ្ណោះ។

-ក្នុងអរូបព្រហ្មបុគ្គលទាំង ៤ ព្រហ្មបុគ្គលក្នុងអាកាសានញ្ចាយតនភូមិ មានអាយុ ២ម៉ឺនមហាកប្ប, ព្រហ្មបុគ្គលក្នុងវិញ្ញាណញ្ចាយតនភូមិ មានអាយុ ៤ ម៉ឺនមហាកប្ប, ព្រហ្មបុគ្គលក្នុងអាកិញ្ចញ្ញាយតនភូមិ មានអាយុ ៦ ម៉ឺនមហាកប្ប,ព្រហ្មបុគ្គលក្នុងនេវសញ្ញានាសញ្ញាយតនភូមិ មានអាយុ ៨ ម៉ឺន ៤ ពាន់មហាកប្ប។

## គ. អរូបាវចរកិរិយាចិត្ត ៤ ដួង

អរូបាវចរកិរិយាចិត្ត ៤ ដួងនេះ កើតមានដល់ព្រះអរហន្តតែមួយពួកប៉ុណ្ណោះ បុថុជ្ជនក្តី ព្រះសេក្ខបុគ្គលក្តី កាលបើចម្រើនអរូបជ្ឈានទី៤ អរូបជ្ឈានចិត្តនេះ តែងតែជាកុសល មិនមែនជាអរូបាវចរកិរិយាចិត្តឡើយ។

## អរូបាវចរកិរិយាចិត្ត ៤ ដួង

**-អាកាសានញ្ចាយតនកិរិយាចិត្តំ**

**-វិញ្ញាណញ្ចាយតនកិរិយាចិត្តំ**

**-អាកិញ្ចញ្ញាយតនកិរិយាចិត្តំ**

**-នេវសញ្ញានាសញ្ញាយតនកិរិយាចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរកិរិយាចិត្តានិ នាម។**

ប្រែថា៖

-អាកាសានញ្ចាយតនកិរិយាចិត្ត ១

-វិញ្ញាណញ្ចាយតនកិរិយាចិត្ត ១

-អាកិញ្ចញ្ញាយតនកិរិយាចិត្ត ១

-នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ១

ចិត្តទាំង ៤ ដួងនេះឈ្មោះថា **អរូបាវចរកិរិយាចិត្ត**។

អរូបាវចរកិរិយាចិត្ត ៤ ដួងនេះ មានអង្គឈានស្មើគ្នា និង ដូចគ្នា គឺ ឧបេក្ខា និង ឯកគ្គតា តែមានអារម្មណ៍ផ្សេងគ្នា ប្រព្រឹត្តបានតាមបែបដូចគ្នា និង អរូបាវចរកុសលចិត្តដែរ ។ កាលអរូបាវចរកិរិយាចិត្តរបស់ព្រះអរហន្ត កើតឡើង វិថីចិត្តដែលកើតមុនរមែងប្រព្រឹត្តទៅយ៉ាងនេះគឺ៖

**-ភវង្គចិត្ត**
**-ភវង្គចលនៈ**
**-ភវង្គុប្បច្ឆេទៈ**
} ជាមហាវិបាកញាណសម្បយុត្ត (ចិត្តផុតវិថី)។

**-មនោទ្វារាវជ្ជនៈ** ជាអហេតុកកិរិយាចិត្ត

**-បរិកម្ម**
**-ឧបចារៈ**
**-អនុលោម**
**-គោត្រភូ**
} មហាកិរិយា ឧបេក្ខាញាណសម្បយុត្ត ២ ដួង។

**-អរូបាវចរកិរិយាចិត្ត**

**-ភវង្គចិត្ត** ជាមហាវិបាកញាណសម្បយុត្ត។

- ➢ វិថីចិត្តនេះសម្រាប់មនុស្សបុគ្គល ចំណែក តិក្ខបុគ្គលមិនមានបរិកម្ម ទេ។

***អរូបាវចរចិត្តទាំង១២ ដួងនេះគឺ៖**

អរូបាវចរកុសលចិត្ត ៤ដួង ,អរូបាវចរវិបាកចិត្ត ៤ ដួង អរូបាវចរកិរិយាចិត្ត- ៤ ដួង។

## ចិត្តទាំងអស់នេះមានចេតសិកកើតរួម ៣០ គឺ៖

**-អញ្ញសមានាចេតសិក ១០** (វៀរ វិតក្កៈ វិចារៈ បីតិ)

**-សោភណសាធារណចេតសិក ១៩**

**-បញ្ញាចេតសិក ១** (វៀរ វិរតិ ៣ អប្បមញ្ញា ២)

## ការចែកអរូបាវចរចិត្ត ១២ ដួងដោយន័យផ្សេងៗ

| | |
|---|---|
| **១-ដោយជាតិ** | ជាកុសលជាតិ ៤ ដួង ជាវិបាក ៤ ដួង ជាកិរិយា ៤ ដួង។ |
| **២-ដោយភូមិ** | ជាអរូបាវចរភូមិទាំង ១២ ដួង។ |
| **៣-ដោយវេទនា** | ជាឧបេក្ខាវេទនាទាំង ១២ ដួង។ |
| **៤-ដោយហេតុ** | ជានហេតុ និង ជាតិហេតុកចិត្ត។ |
| **៥-ដោយសម្បយុត្ត** | ជាញាណសម្បយុត្តទាំង ១២ ដួង។ |
| **៦-ដោយសង្ខារ** | ជាសសង្ខារិកចិត្តទាំង ១២ ដួង។ |
| **៧-ដោយសោភណៈ** | ជាអរូបាវចរសោភណចិត្ត។ |
| **៨-ដោយឈាន** | ជាបញ្ចមជ្ឈាន (បញ្ចកន័យ) ទាំង ១២ ដួង។ |

**៩-ដោយលោកិយ** ជាលោកិយចិត្តទាំង ១២ ដួង។

**១០-ដោយកិច្ច** អរូបាវចរកុសលចិត្ត ៤ ដួង និង អរូបាវចរកិរិយា ៤ ដួង(ធ្វើជវនកិច្ច) អរូបាវចរវិបាក ៤ ដួង (ធ្វើកិច្ច ៣ គឺ បដិសន្ធិ ភវង្គ ចុតិ)។

**១១-ដោយអារម្មណ៍** មានធម្មារម្មណ៍ ជាអារម្មណ៍ទាំង ១២ ដួង។

**១២-ដោយវត្ថុ** អរូបាវចរកុសលចិត្ត ៤ ដួង និង អរូបាវចរកិរិយាចិត្ត៤ដួង ដែលកើតក្នុងបញ្ចវោការភូមិ អាស្រ័យហទយវត្ថុ បើកើតក្នុងចតុវោការភូមិ មិនចាំបាច់អាស្រ័យវត្ថុក៏កើតឡើងបានដែរ។

**១៣-ដោយទ្វារ** អរូបាវចរកុសល ៤ ដួង និង អរូបាវចរកិរិយាចិត្ត ៤ ដួង ដឹងអារម្មណ៍តាម មនោទ្វារ ចំណែកអរូបាវចរវិបាកចិត្ត ៤ ដួងជាទ្វារវិមុត្តិ។

**១៤-ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ។

**-ចំណាំ** ក្នុងភូមិជាទីកើត ៣១ ភូមិនោះអរូបាវចរកុសលចិត្ត៤ដួង និង អរូបាវចរកិរិយាចិត្ត ៤ ដួង កើតបាន ២៦ ភូមិ(វៀរអបាយភូមិ ៤ អសញ្ញសត្តាភូមិ ១) ចំណែកអរូបាវចរវិបាកចិត្ត ៤ ដួង កើតបានចំពោះតែក្នុងអរូបព្រហ្មភូមិ ៤ ប៉ុណ្ណោះ។

## ៤.លោកុត្តរលោកុត្តរចិត្ត ៨ ដួង

ពាក្យថា **លោកុត្តរ < លោក +ឧត្តរៈ** ប្រែថា លើសអំពីលោក ឬ ផុតអំពីលោក **មានន័យថា** ជាចិត្តមានអារម្មណ៍ផុតពីសភាវធម៌ដែលមាន

នៅក្នុងលោក ឬថា ជាចិត្តដែលមានអំណាចទទួលអារម្មណ៍ក្រៅពីលោក ឬផុតចាកលោកបាន ។ អារម្មណ៍នោះបានដល់ព្រះនិព្វាន ។

ក្នុងចិត្ត ៨៩ នោះ ចិត្តដែលអាចទទួលព្រះនិព្វានជាអារម្មណ៍បានប្រាកដមានតែ ៨ ដួង ប៉ុណ្ណោះ។ ក្រៅពីនោះសូម្បីមានចិត្តខ្លះអាចទទួលព្រះនិព្វានជាអារម្មណ៍បានក៏មិនប្រាកដ ព្រោះហេតុដូច្នោះហើយទើប ហៅថាចិត្ត ៨ ដួង នោះថា **លោកុត្តរចិត្ត** ។

ក្នុងលោកុត្តរចិត្ត ៨ ដួងចែកចេញជា ២ ប្រភេទគឺ មគ្គចិត្ត ៤ ឈ្មោះថា លោកុត្តរកុសលចិត្ត និង ផលចិត្ត ៤ ឈ្មោះថា **លោកុត្តរវិបាក-ចិត្ត** មិនមានលោកុត្តរកិរិយាចិត្តឡើយ ។

## ក.លោកុត្តរកុសលចិត្ត ៤ ដួង

**-សោតាបត្តិមគ្គចិត្តំ**

**-សកទាគាមិមគ្គចិត្តំ**

**-អនាគាមិមគ្គចិត្តំ**

**-អរហត្តមគ្គចិត្តញ្ចេតិ ឥមានិ ចត្តារិបិ លោកុត្តរកុសលចិត្តានិ នាម។**

ប្រែថា

-សោតាបត្តិមគ្គចិត្ត ១ ដួង

-សកទាគាមិមគ្គចិត្ត ១ ដួង

-អនាគាមិមគ្គចិត្ត ១ ដួង

-អរហត្តមគ្គចិត្ត ១ ដួង

**ចិត្តទាំង ៤ ដួងនេះឈ្មោះ លោកុត្តរកុសលចិត្ត ។**

### ➢ សោតាបត្តិមគ្គចិត្ត

ពាក្យថា **សោតាបត្តិមគ្គចិត្ត < សោតៈ+អាបត្តិ +មគ្គៈ +ចិត្ត**

**-សោតៈ** ប្រែថា ក្រសែ គឺថាអរិយមគ្គមានអង្គ ៨ បណ្ឌិតហៅថា សោតៈ (ក្រសែ) ដែលហូរតម្រង់ទៅ គឺចូលកាន់ព្រះនិញ្វាន ឬ ដូចជាក្រសែទឹកដែលហូរទៅកាន់មហាសមុទ្រគឺព្រះនិញ្វាន។

**-អាបត្តិ** ប្រែថា ការដល់ហើយ គឺការសម្រេចតាំងពីខាងដើម ជាការសេពគ្រាដំបូង នូវសោតៈនោះ។

**-មគ្គ** ដោយអត្ថថា ការស្វែងរកព្រះនិញ្វាន ឬ ការទៅសម្លាប់កិលេសទាំងឡាយ ។

**-មគ្គចិត្ត** គឺចិត្តសម្បយុត្តដោយមគ្គនោះ។

*មគ្គចិត្ត ដែលបានសម្រេចក្រសែដំបូង ឈ្មោះថា **សោតាបត្តិ-មគ្គចិត្ត** បានដល់មគ្គចិត្តរបស់ព្រះអរិយបុគ្គលដំបូង ដែលនៅមានបដិសន្ធិទៀតយ៉ាងច្រើន ក៏ ៧ ជាតិទៀតនៅក្នុងលោកនេះ។

## ➢ សកទាគាមិមគ្គចិត្ត

ពាក្យថា **សកទាគាមិមគ្គចិត្ត < សកឹ+ អាគាមី+ចិត្ត**

**-សកឹ** ប្រែថា ១ ដង, ១ វារៈ

**-អាគាមី** ប្រែថា ត្រឡប់មក

**-សកទាគាមិមគ្គចិត្ត** គឺមគ្គចិត្តដែលញុំាងឱ្យបុគ្គលត្រឡប់មកកាន់កាម-លោកម្តងទៀត បានដល់មគ្គចិត្តរបស់ព្រះអរិយបុគ្គលទី ២ ដែលត្រឡប់មកបដិសន្ធិ ក្នុងកាមភូមិម្តងទៀតប៉ុណ្ណោះ។

## ➢ អនាគាមិមគ្គចិត្ត

ពាក្យថា **អនាគាមិមគ្គចិត្ត** <ន+អាគាមី+មគ្គ +ចិត្ត

**អនាគាមិមគ្គចិត្ត** គឺមគ្គចិត្តដែលញ៉ាំងឱ្យបុគ្គលមិនចាំបាច់ត្រឡប់មកកាន់កាមលោក សូម្បីតែម្តងទៀតទេ បានដល់មគ្គចិត្តរបស់ព្រះអរិយបុគ្គលទី ៣ ដែលមិនត្រូវត្រឡប់មកបដិសន្ធិក្នុងកាមលោក។

### ➢ អរហត្តមគ្គចិត្ត

ពាក្យថា **អរហត្តមគ្គចិត្ត < អរហត្ត+មគ្គ+ចិត្ត** ឈ្មោះថាព្រះអរហន្ត ដោយអត្ថថា គួរដល់ការបូជាវិសេស ព្រោះភាពជាទក្ខិណេយ្យបុគ្គលដ៏កំពូល ។ ម្យ៉ាងទៀត ឈ្មោះថា **អរហន្ត** ព្រោះមិនមានការត្រឡប់មក ក្នុងការធ្វើបាបទៀតទេ បានដល់ព្រះអរិយបុគ្គលទី ៤។ ភាវៈនៃបុគ្គលទី ៤ នោះ ឈ្មោះថាអរហត្ត ។

ពាក្យថា **អរហត្ត** នោះជាឈ្មោះនៃផលទី ៤ ។

មគ្គ ដែលជាហេតុនៃអរហត្តនោះ ឈ្មោះថា អរហត្តមគ្គ។ចិត្តដែលសម្បយុត្តដោយអរហត្តមគ្គនោះ ឈ្មោះថា **អរហត្តមគ្គចិត្ត** ។

-ក្នុងមគ្គចិត្ត ៤ដួងនោះ ចាត់ថាលោកុត្តរកុសលព្រោះជាកុសលដែលធ្វើឱ្យឆ្លងផុតចាកលោក ៣ គឺ **កាមលោក ១ រូបលោក ១ អរូប-លោក ១ ។**

**កាមលោក** បានដល់ កាមភូមិ ១១ ភូមិ
**រូបលោក** បានដល់ រូបភូមិ ១៦ ភូមិ
**អរូបលោក** បានដល់ អរូបភូមិ ៤ ភូមិ
**រួមទាំងអស់ ជា ៣១ ភូមិ ។**

-ការឆ្លងផុតលោកនោះ មានប្រការដូច្នេះគឺ ៖

**មគ្គចិត្តដួងទី ១** ហៅថា បឋមមគ្គ គឺសោតាបត្តិមគ្គចិត្ត។

**មគ្គចិត្តដួងទី ២** ហៅថា ទុតិយមគ្គ គឺ សកទាគាមិមគ្គចិត្ត ចិត្ត២ដួងនេះធ្វើឱ្យផុតចាកកាមលោក គឺ អបាយភូមិទាំង ៤។

**មគ្គចិត្តដួងទី ៣** ហៅថា តតិយមគ្គ គឺអនាគាមិមគ្គចិត្ត ចិត្ត១ដួងនេះធ្វើឱ្យផុតចាកពីកាមលោក ទាំង ១១ ភូមិ។ មគ្គចិត្តដួងទី ៤ ហៅថា ចតុត្ថមគ្គគឺអរហត្តមគ្គចិត្ត ចិត្ត១ដួងនេះ ធ្វើឱ្យផុតចាកលោកទាំង៣១ភូមិ ។

-ដែលហៅថា លោកុត្តរកុសលព្រោះជាកុសលដែលធ្វើឱ្យឆ្លងផុតពីបុថុជ្ជនទៅជាព្រះអរិយបុគ្គលដោយប្រការដូច្នេះគឺ៖

-**មគ្គចិត្តដួងទី ១** ធ្វើឱ្យទៅជាព្រះសោតាបន្នបុគ្គល

-**មគ្គចិត្តដួងទី ២** ធ្វើឱ្យទៅជាព្រះសកទាគាមិបុគ្គល

-**មគ្គចិត្តដួងទី ៣** ធ្វើឱ្យទៅជាព្រះអនាគាមិបុគ្គល

-**មគ្គចិត្តដួងទី ៤** ធ្វើឱ្យទៅជាព្រះអរហន្ត

-ដែលហៅថា លោកុត្តរកុសល ព្រោះជាកុសលដែលកើតឡើងមានព្រះនិព្វានជាលោកុត្តរធម៌ជាអារម្មណ៍ ហើយការដែលលោកុត្តរកុសលចិត្ត ៤ ដួងនេះកើតឡើងបាន ក៏ព្រោះមានព្រះនិព្វានជាអារម្មណប្បច្ច័យ ទើបកើត។

-ដែលហៅថា លោកុត្តរកុសល ព្រោះជាកុសលដែលមានអំណាចប្រសើរ លើសលោកិយកុសលទាំងឡាយ អាចរំលត់អកុសលឱ្យដាច់ជាសមុច្ឆេទបានគឺ ព្រោះហេតុតែមានព្រះនិព្វានជាអារម្មណ៍នោះឯង។

-លោកុត្តរកុសលពោលគឺ មគ្គចិត្ត ៤ដួង តាមសេចក្តីផ្សេងគ្នានៃការប្រកបរបស់អដ្ឋង្គិកមគ្គមានសោតាបត្តិមគ្គជាដើម គឺដោយអំណាចការលះសំយោជនៈបាន ។ ការដែលលះសំយោជនៈបានផ្សេង ៗ គ្នា ក៏ព្រោះឥន្ទ្រិយ ៥ មានសទ្ធាជាដើម មានកម្លាំងផ្សេងៗគ្នាគឺ ឥន្ទ្រិយ ៥ របស់សោតាបត្តិមគ្គ មិនចាស់ក្លា របស់សកទាគាមិមគ្គចាស់ក្លា របស់អនាគាមិមគ្គ ចាស់ក្លាជាង របស់អរហត្តមគ្គ ចាស់ក្លាជាទីបំផុតនោះឯង ។

## ខ.លោកុត្តរវិបាកចិត្ត ៤ ដួង

**-សោតាបត្តិផលចិត្តំ**

**-សកទាគាមិផលចិត្តំ**

**-អនាគាមិផលចិត្តំ**

**-អរហត្តផលចិត្តញ្ចេតិ ឥមានិ ចត្តារិបិ លោកុត្តរវិបាកចិត្តានិ នាម ។**

ប្រែថា៖

-សោតាបត្តិផលចិត្ត ១

-សកទាគាមិផលចិត្ត ១

-អនាគាមិផលចិត្ត ១

-អរហត្តផលចិត្ត ១

**ចិត្តទាំង ៤ ដួងនេះឈ្មោះថា លោកុត្តរវិបាកចិត្ត ។**

**សួរថា** ហេតុអ្វីលោកុត្តរវិបាកក៏មាន ៤ ប្រការ?

**ឆ្លើយថា** ព្រោះជាផលរបស់លោកុត្តរកុសលនោះៗគឺអាស្រ័យមគ្គចិត្ត ជាហេតុ ជាបច្ច័យឱ្យកើតឡើងព្រោះហេតុនោះទើបហៅថា ផលចិត្ត ។ ផលចិត្តនេះមិនបានមាននាទីប្រហារនូវកិលេសណាមួយដូចជាមគ្គចិត្តទេ ប៉ុន្តែ

មានព្រះនិព្វានជាអារម្មណ៍ និង ប្រកបព្រមដោយពោធិបក្ខិយធម៌ទាំង៣៧ ប្រការដូចគ្នា។

-លោកុត្តរចិត្តនោះ មិនមានកិរិយាចិត្តទេ ព្រោះមគ្គចិត្តកើតឡើងមួយដងក៏ប្រហារកិលេសដាច់ជាសមុច្ឆេទ ដូច្នេះមគ្គចិត្តកើតឡើងប្រហារកិលេសបានហើយនឹងមិនកើតឡើងជាលើកទី ២ ទៀតឡើយ។

ចំណែកផលចិត្តកើតបានច្រើនដង គឺដែលជាផលសមាបត្តិ មានព្រះនិព្វានជាអារម្មណ៍ក៏ដើម្បីសេចក្ដីនៅជាសុខក្នុងភពបច្ចុប្បន្ន ព្រោះហេតុនេះទើបលោកុត្តរចិត្ត ដែលជាកិរិយាមិនមាន ។

-លោកុត្តរចិត្ត ៨ ដួងដោយសង្ខេបគឺ មគ្គចិត្ត ៤ ដួង និង ផលចិត្ត ៤ ដួងនេះ។

**មានចេតសិកកើតរួម ៣៦ ប្រភេទដូចគ្នាស្មើគ្នា គ្រប់ដួងគឺ៖**

**-អញ្ញសមានាចេតសិក ១៣**

**-សោភណចេតសិក ២៣** (វៀរអប្បមញ្ញា ២)

**លោកុត្តរចិត្តបែបពិស្តារ៖**

លោកុត្តរចិត្ត មាន ២ ន័យ គឺបែបសង្ខេបមាន ៨ ដួង និង បែបពិស្តារមាន ៤០ដួង។

**លោកុត្តរចិត្តបែបពិស្តារ ៤០ ដួង** សម្ដែងដោយតាមអង្គឈាន គឺថាធ្វើលោកុត្តរចិត្តដួងនីមួយៗ ជា ៥ យ៉ាង ដោយតាមសេចក្ដី ខុសគ្នានៃការប្រកបជាមួយអង្គឈាន គឺ៖

**-បឋមជ្ឈានមានអង្គ ៥** មានសោតាបត្តិមគ្គចិត្ត ១

**-ទុតិយជ្ឈានមានអង្គ ៤** មានសោតាបត្តិមគ្គចិត្ត ១

**-តតិយជ្ឈានមានអង្គ ៣** មានសោតាបត្តិមគ្គចិត្ត ១

**-ចតុត្ថជ្ឈានមានអង្គ ២** មានសោតាបត្តិមគ្គចិត្ត ១

**-បញ្ចមជ្ឈានមានអង្គ ២** មានសោតាបត្តិមគ្គចិត្ត ១

ដូច្នេះ សោតាបត្តិមគ្គចិត្ត មាន៥ , សោតាបត្តិផលចិត្ត ក៏មាន ៥, សកទាគាមិមគ្គចិត្ត មាន ៥ , សកទាមិផលចិត្ត ក៏មាន៥,អនាគាមិមគ្គចិត្ត ក៏មាន ៥, អនាគាមិផលចិត្ត ក៏មាន ៥។

អរហត្តមគ្គ ក៏មាន ៥, អរហត្តផល ក៏មាន ៥ ដូចគ្នា រួមជាមគ្គចិត្ត ២០ដួង និង ផលចិត្ត ២០ ដួង រួមទាំង ២ ក៏ជាលោកុត្តរចិត្ត ៤០ ដួងដោយពិស្តារ។

លោកុត្តរចិត្តដោយពិស្តារ ៤០ ដួង ទើបមានសង្គហៈ ៥ ន័យ ដោយអំណាចនៃអង្គឈានដូចតទៅនេះ៖

**-ន័យទី១** លោកុត្តរបឋមជ្ឈានចិត្ត ៨ ដួង មានចេតសិកកើតរួមជាមួយ ៣៦ ប្រភេទ៖

**-អញ្ញសមានាចេតសិក ១៣**

**-សោភណចេតសិក ២៣** (វៀរអប្បមញ្ញា ២)។

**-ន័យទី ២** លោកុត្តរទុតិយជ្ឈានចិត្ត ៨ ដួង មានចេតសិកកើតរួមជាមួយ ៣៥ ប្រភេទ៖

**-អញ្ញសមានាចេតសិក ១២** (វៀរវិតក្ក)

**-សោភណចេតសិក ២៣** (វៀរអប្បមញ្ញា ២)

**-ន័យទី៣** លោកុត្តរតតិយជ្ឈានចិត្ត ៨ ដួងមានចេតសិកកើតរួមជាមួយ ៣៤ ប្រភេទ៖

**-អញ្ញសមានាចេតសិក ១១** (វៀរ វិតក្ក វិចារ)

**-សោភណចេតសិក ២៣** (វៀរ អប្បមញ្ញា ២)

**-ន័យទី ៤** លោកុត្តរចតុត្ថជ្ឈានចិត្ត ៨ ដួងមានចេតសិកកើតរួមជាមួយ ៣៣ ប្រភេទ៖

**-អញ្ញសមានាចេតសិក ១០** (វៀរ វិតក្ក វិចារ បីតិ)

**-សោភណចេតសិក ២៣** (វៀរ អប្បមញ្ញា ២)

**-ន័យទី ៥** លោកុត្តរបញ្ចមជ្ឈានចិត្ត ៨ ដួង មានចេតសិកកើតរួមជាមួយ ៣៣ ប្រភេទ៖

**-អញ្ញសមានាចេតសិក ១០** (វៀរ វិតក្ក វិចារ បីតិ)

**-សោភណចេតសិក ២៣** (វៀរ អប្បមញ្ញា)

## ការចែកលោកុត្តរចិត្ត ៨ ដួងដោយន័យផ្សេងៗ

**១-ដោយជាតិ** ជាកុសលជាតិ ៤ ដួង ជាវិបាក ៤ ដួង។

**២-ដោយភូមិ** ជាលោកុត្តរភូមិទាំង ៨ ដួង។

**៣-ដោយវេទនា** ជាសោមនស្សវេទនា និង ឧបេក្ខាវេទនា។

**៤-ដោយហេតុ** ជានហេតុ និង ជាតិហេតុកចិត្ត។

**៥-ដោយសម្បយុត្ត** ជាញាណសម្បយុត្តទាំង ៨ ដួង។

**៦-ដោយសង្ខារ** ជាសសង្ខារិកចិត្តទាំង ៨ ដួង។

**៧-ដោយសោភណៈ** ជាសោភណចិត្ត។

**៨-ដោយឈាន** ជាឈានចិត្ត។

**៩-ដោយលោកិយ** ជាលោកុត្តរចិត្ត។

**១០-ដោយកិច្ច** ធ្វើជវនកិច្ច ។

**១១-ដោយអារម្មណ៍** មានព្រះនិព្វានជាអារម្មណ៍ ជាធម្មារម្មណ៍។

**១២-ដោយទ្វារ** ជាមនោទ្វារ។

**១៣-ដោយវត្ថុ** វៀរសោតាបត្តិមគ្គចិត្ត ១ ដួង ដែលអាស្រ័យហទយវត្ថុ។ លោកុត្តរចិត្តសល់ ៧ ដួងទៀតអាស្រ័យហទយវត្ថុក្នុងបញ្ចវោការភព និង មិនអាស្រ័យហទយវត្ថុក្នុងចតុវោការភព។

**១៤-ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ។

## ការចែកចិត្ត ៨៩ ដួង ឬ ១២១ ដួងដោយន័យផ្សេងៗ

**១- ដោយជាតិ**

-អកុសលចិត្ត ១២ ដួង ជាអកុសលជាតិ

-កុសលចិត្ត ២១ ដួង ឬ ៣៧ ដួង ជាកុសលជាតិ

-វិបាកចិត្ត ៣៦ដួង ឬ ៥២ ដួង ជាវិបាកជាតិ

-កិរិយាចិត្ត ២០ ដួង ជាកិរិយាជាតិ ។

**២- ដោយភូមិ**

-កាមាវចរចិត្ត ៥៤ ដួង ជាកាមភូមិ

-រូបាវចរចិត្ត១៥ ដួង ជារូបាវចរភូមិ

-អរូបាវចរចិត្ត ១២ ដួង ជាអរូបាវចរភូមិ

-លោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួង ជាលោកុត្តរភូមិ

**៣- ដោយវេទនា**

-សុខសហគតចិត្ត ១ ដួង ជាសុខវេទនា។

-ទុក្ខសហគតចិត្ត ១ ដួង ជាទុក្ខវេទនា។

-សោមនស្សហគតចិត្ត ៦២ ដួង ជាសោមនស្សវេទនា។

-ឧបេក្ខាសហគតចិត្ត ៥៥ ដួង ជាឧបេក្ខាវេទនា ។

-ទោមនស្សសហគតចិត្ត ២ ដួង ជា ទោមនស្សវេទនា។

**៤- ដោយហេតុ**

-ចិត្ត ៨៩ ដួង ឬ ១២១ ដួង ជានហេតុ , ចិត្តមិនមានហេតុប្រកប ១៨ ដួង ជា អហេតុកចិត្ត , ចិត្តដែលមានហេតុប្រកប ៧១ ឬ ១០៣ ដួង ជាសហេតុកចិត្ត។

**៥- ដោយសម្បយុត្ត**

ជាញាណសម្បយុត្ត ៤៧ ដួង ឬ ៧៩ ដួង, ជាញាណវិប្បយុត្ត ៣៤ ដួង,ជាទិដ្ឋិគតសម្បយុត្ត ៤ ដួង ជាបដិឃសម្បយុត្ត២ ដួង, ជាវិចិកិច្ឆា-សម្បយុត្ត១ដួង, ឧទ្ធច្ចសម្បយុត្ត ១ ដួង។

**៦-ដោយសង្ខារ** ជាអសង្ខារិក ៣៧ដួង ជាសសង្ខារិក៥២ដួង ឬ៨៤ដួង។

**៧-ដោយសោភណ** ជាអសោភណចិត្ត ៣០ដួង ជាសោភណចិត្ត ៥៩ ឬ ៩១ដួង។

**៨- ដោយឈាន** ជាកាមាវចរចិត្ត ៥៤ ដួង ជាអឈានចិត្ត ចិត្តនៅសល់ ៦៧ ដួងជាឈានចិត្ត។

**៩- ដោយលោកិយ** ចិត្ត ៨១ ដួង ជាលោកិយចិត្ត, ៨ ឬ ៤០ ដួងជា លោកុត្តរចិត្ត។

**១០-ដោយកិច្ច** ចិត្ត ៨៩ ដួង ឬ ១២១ ដួង ធ្វើកិច្ចបាន ១៤ កិច្ច។

**១១-ដោយអារម្មណ៍** ចិត្ត ៨៩ ដួង ឬ ១២១ ដួងមានអារម្មណ៍ ៦។

**១២-ដោយទ្វារ** ចិត្ត ៨៩ដួង ឬ ១២១ដួង អាស្រ័យទ្វារ ៦ និង ទ្វារវិមុត្តិ(កាលធ្វើ បដិសន្ធិកិច្ច,ភវង្គកិច្ច,ចុតិកិច្ច)។

**១៣-ដោយវត្ថុ** ចិត្ត ១១៧ ដួង កើតត្រង់វត្ថុ ៦, ចិត្ត ៤ ដួងមិន អាស្រ័យវត្ថុ។

**១៤- ដោយវិញ្ញាណធាតុ** ចិត្ត៨៩ ដួង ឬ ១២១ ដួង ជាវិញ្ញាណធាតុ ៧។

## ក្រុមធម្មទាន

១.ភិក្ខុ **លទ្ធធម្មោ ជា គីមសាន** អ្នកកែសម្រួល

២.សាមណេរ **សុតប្បញ្ញោ យាន ខែមរិន** អ្នកវាយអត្ថបទ

៣.សាមណេរ **អគ្គបញ្ញោ ណាង សុភក្រ័** អ្នកវាយអត្ថបទ

## អ្នកជួយត្រួតពិនិត្យខ្លឹមសារ និង អក្ខរាវិរុទ្ធ

១.ភិក្ខុ **បធានជោតោ ម៉ាន់ សុភាព**

១.សាមណេរ **សាសនរក្ខិតោ សុខ ចន្ថា**

២.សាមណេរ **នន្ទធម្មោ ហែល សុភាន់**

៣.សាមណេរ **វជិរមេធា តាំង ពេជ្រ**

៤. សាមណេរ **វីរិយធម្មោ ឈឹម វ៉ាឌី**

៥.សាមណេរ **បសន្នធម្មោ ជា ហុន**

៦.សាមណេរ **អារទ្ធវីរិយោ ឌីឡា ឡៃ**

៧.សាមណេរ **ពុទ្ធរក្ខិតោ ត្លង ចិន្តា**

៨.សាមណេរ **ធម្មរក្ខិតោ អៀន សុវណ្ណា**

៩.សាមណេរ **ចិត្តរក្ខិតោ ពៅ មេន**

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានរមែងឈ្នះអស់ទានទាំងពួង

## នាមពុទ្ធបរិស័ទចូលរួមឧបត្ថម្ភបោះពុម្ពសៀវភៅ

១- ឧបាសិកា ឃី គឹមលាង ព្រមទាំង កូនចៅ (USA)................៩៣០$

២-ឧបាសិកា ឡុង សារុន ព្រមទាំងកូនចៅ(USA)........................២០០$

៣-ឧបាសិកា ថ្លាង ភ្នំពេជ្រ ព្រមទាំង ភរិយា គុណ្ណារីលូ(USA)...១០០$

៤-ឧបាសិកា ឃឹម ស៊ី (USA)..................................................១០០$

៥.ឧបាសក ឡាង សុភ័ក្រ និង ភរិយា (USA) ................................១០០$

៦-ឧបាសិកា ហង់ សេង ព្រមទាំងកូន ចៅ (USA).....................៧០$

៧-ឧបាសិកា លៀវ គឹមរួច (USA).............................................៥០$

៨-ឧបាសិកា នុត សូផាត (USA) ...............................................៥០$

៩-ឧបាសិកា សន សារុន (USA)................................................៥០$

១០-ឧបាសិកា ទេស សឿន (USA)..............................................៣០$

១១-ឧបាសិកា ឃីវ សុខ (USA)..................................................២០$